ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការប្រើប្រាស់ដីធ្លី សង្កាត់ស្ទឹងវែង

## ឆ្នាំ ២០០៩-២០២២

## ក្រុង ខេមរភូមិន្ទ ខេត្ត កោះកុង



រៀបចំដោយៈ គណៈកម្មាធិការផែនការ និងថវិកា/ក្រុមប្រឹក្សាឃុំ/សង្កាត់

គាំទ្រដោយៈ ក្រុមសម្របសម្រួលស្រុក និងសម្របសម្រួលផែនការប្រើប្រាស់ដីធ្លីថ្នាក់ស្រុក

ខែ ធ្នូ ឆ្នាំ ២០០៩

## មាតិកា


**អារម្ភកថា** ........................................ ១

**សេចក្តីផ្តើម** ........................................ ២

**ជំពូក ១ : ព័ត៌មាន និងទិន្នន័យសម្រាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងសង្កាត់**

**១.១ ស្ថានភាពទូទៅ** ........................................ ៣

១.១.១ ទីតាំងរដ្ឋបាល ........................................ ៣

១.១.២ ប្រជាសាស្ត្រ ........................................ ៤

១.១.៣ ភាពគ្មានដីធ្លី ........................................ ៥

១.១.៤ ស្ថានភាពសេដ្ឋកិច្ច ........................................ ៧

១.១.៥ ស្ថានភាពអប់រំ និងសិក្សាធិការ ........................................ ៨

១.១.៦ ស្ថានភាពសុខាភិបាល ........................................ ១០

១.១.៦.១ ផ្នែកសុខាភិបាល ........................................ ១០

១.១.៦.២ ការផ្គត់ផ្គង់ទឹកស្អាត ........................................ ១១

**១.២ ស្ថានភាពភូមិសាស្ត្រ** ........................................ ១២

១.២.១ ទីតាំងភូមិសាស្ត្រ ........................................ ១២

១.២.២ អាកាសធាតុ ........................................ ១៣

១.២.៣ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន ........................................ ១៥

១.៣ **ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន** ........................................ ១៧

១.៣.១ ស្ថានភាពនៃការប្រើប្រាស់ដី ........................................ ១៧

១.៣.២ ស្ថានភាពនៃការកាន់កាប់គ្រប់គ្រងដី ........................................ ១៨

១.៣.៣ ផលិតកម្មកសិកម្ម ........................................ ១៨

១.៣.៤ ធនធានធម្មជាតិ ........................................ ២០

១.៣.៤.១ ធនធានព្រៃឈើ ........................................ ២០

១.៣.៤.២ ធនធានជលផល ........................................ ២១

**១.៤ ទីផ្សារ និងខ្សែសង្វាក់ផលិតផល** ........................................ ២១

១.៤.១ ទីផ្សារ និង តម្លៃកសិផល ផលអនុផលព្រៃឈើ និងនេសាទ ........................................ ២១

៤.២ ខ្សែសង្វាក់ និងចរាចរផលិតផល ........................................ ២២

១.៤.៣ ឱកាស ឧបសគ្គ ........................................ ២២

## ជំពូក ២ ៖ ការវិភាគពីតំរូវការសំរាប់អនាគត ឧបសគ្គ និងសក្តានុពល


២.១ តំបន់រសើប ........ ២៣

២.២ ការប្រឈម/ឧបសគ្គ ........ ២៣

២.៣ កំណត់តំរូវការនៃការអភិវឌ្ឍន៍ និងគោលដៅយុទ្ធសាស្រ្តសង្កាត់ស្ទឹងវែង ........ ២៤

២.៣.១ គោលដៅនៃការអភិវឌ្ឍន៍ ........ ២៤

២.៣.២ យុទ្ធសាស្រ្តនៃការអភិវឌ្ឍន៍ ........ ២៤

**២.៤ តំរូវការសំរាប់អនាគត** ........ ២៤

២.៤.១ ប្រជាសាស្រ្ត ........ ២៤

២.៤.១.១ អត្រាកំណើន ........ ២៤

២.៤.១.២ ការធ្វើចំណោលប្រជាសាស្រ្ត ........ ២៦

២.៤.២ តំរូវការដីសំរាប់លំនៅដ្ឋាន ........ ២៧

២.៤.៣ តំរូវការដីកសិកម្ម ........ ២៧

២.៤.៤ តំរូវការដីសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ........ ២៨

២.៤.៥ តំរូវការដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធសង្គម ........ ២៨

២.៤.៥.១ តំរូវការសាលារៀន ........ ២៩

២.៣.៥.២ សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត ........ ៣០

២.៤.៥.៣ ផ្នែកវប្បធម៌ និងសាសនា ........ ៣១

២.៤.៥.៤ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងប្រព័ន្ធធារាសាស្រ្ត ........ ៣១


## ជំពូក ៣ ៖ ផែនការប្រើប្រាស់ដីអនាគត


៣.១ ស្ថានភាពដី ( សក្តានុពលដី និងតំរូវការដី) ........ ៣៥

៣.១.១ ស្ថានភាពដីទូទៅ និង សក្តានុពល ........ ៣៥

៣.១.២ តំរូវការដីតាមប្រភេទ ........ ៣៥

៣.២ ការបែងចែកដីតាមតំរូវការប្រើប្រាស់ ........ ៣៧

៣.២.១ ការវិភាគអន្តរអំពើ ........ ៣៧

៣.២.២ ផែនទីប្រើប្រាស់ដីពេលអនាគត ........ ៣៩

៣.២.៣ បរិយាយការប្រើប្រាស់តាមក្បាលដី ........ ៣៩

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ១ : ការពិពណ៌នាអំពី ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

ឧបសម្ព័ន្ធ ២ : ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដីចុប្បន្ន

ឧបសម្ព័ន្ធ ៣ : បញ្ហាពាក់ពន្ធ័ក្នុងការប្រើប្រាស់ដី

ឧបសម្ព័ន្ធ ៤ : ក្របខណ្ឌអភិវឌ្ឍន៍

ឧបសម្ព័ន្ធ ៥ : បញ្ជីគម្រោង

ឧបសម្ព័ន្ធ ៦ : ផែនទីប្រើប្រាស់ដីលំអិត នៅក្នុងសង្កាត់

ឧបសម្ព័ន្ធ ៧ : ផែនទីប្រើប្រាស់ដីសាមញ្ញ នៅក្នុងសង្កាត់

ឧបសម្ព័ន្ធ ៨ : ផែនទីប្រើប្រាស់ដីនៅពេលអនាគត នៅក្នុងសង្កាត់ឆ្នាំ ២០០៩-២០០២

# អារម្ភកថា

សៀវភៅផែនការប្រើប្រាស់ដីនៅក្នុងសង្កាត់ស្ទឹងវែងសំរាប់ឆ្នាំ ២០០៩-២០២២ នេះត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សា សង្កាត់ស្ទឹងវែង មានការចូលរួមពី គ.ផ.ថ ជាច្រើន និងមានការចូលរួមជួយពីក្រុមសំរបសំរួលរៀបចំផែនការប្រើប្រាស់ដីក្នុងក្រុងខេមរភូមិន្ទ សហការចូលរួមសំរាប់សំរបសំរួលពីក្រុមអ្នកសំរបសំរួលរៀបចំផែនការប្រើប្រាស់ដីខេត្តកោះកុង និងគាំទ្របច្ចេកទេសពីក្រុមការងារសមាសភាគរៀបចំដែនដីរបស់អគ្គនាយកដ្ឋានរៀបចំផែនការដី និង នគរូបនីយកម្មនៃក្រសួង ដ ន ស ក្រោមការជួយឧបត្ថម្ភថវិកាពីអង្គការ DANIDA/DFID-NZaid តាមរយៈស្ថានទូតដាណឺម៉ាកប្រចាំនៅក្នុងប្រទេសកម្ពុជា ។ផែនការប្រើប្រាស់ដីដែលបានកសាងឡើងនេះមានសារៈសំខាន់ណាស់ក្នុងការជួយចង្អុលបង្ហាញទិសដៅដល់ការអភិវឌ្ឍន៍សង្កាត់អោយឆ្លើយតបទៅនឹងតំរូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋដើម្បីបង្កើនកំរិតជីវភាពរស់នៅអោយកាន់តែប្រសើរឡើង និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

ក្រុមប្រឹក្សាសង្កាត់ស្ទឹងវែង សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួង ដ.ន. ស និង អង្គការ DANIDA /DFID-NZaid តាមរយៈស្ថានទូតដាណឺជាប្រចាំនៅក្នុងប្រទេសកម្ពុជា ដែលបានផ្តល់ថវិកាជំនួយសំរាប់ដំណើការរៀបចំផែនការប្រើប្រាស់ដីនេះ តាំងពីការចាប់ផ្តើមរហូតបញ្ចប់ ។ ជាមួយនេះដែរ ក៏សូមថ្លែងអំណរគុណផងដែរដល់ក្រុមការងាររបស់មន្ទីរ ដ.ន.ស ខេត្តកោះកុង ដែលជួយសំរបសំរួលក្នុងការរៀបចំផែនការប្រើប្រាស់ដី ហើយផែនការនេះក៏អាចនឹងមិនទទួលបានភាពជោគជ័យផងដែរដរាបណា គ្មានការចូលរួមពីអាជ្ញាធរដែនដីក្រុងការិយាល័យពាក់ព័ន្ធនានាជុំវិញក្រុងខេមរភូមិន្ទ និងអាជ្ញាធរដែនដីខេត្ត មន្ទីរពាក់ព័ន្ធនានាជុំវិញ ខេត្តកោះកុង ។

ក្រុមប្រឹក្សាសង្កាត់ស្ទឹងវែង ក៏មិនអាចបំភ្លេចបានផងដែរនូវការជួយគាំទ្រ បង្ហាត់បង្ហាញទាំងទ្រឹស្តីនិងបច្ចេកទេសអនុវត្តផ្ទាល់លើការរៀបចំផែនការប្រើប្រាស់ដី ពីក្រុមការងារសំរបសំរួលផែនការប្រើប្រាស់ថ្នាក់ក្រុងថ្នាក់ខេត្ត និងថ្នាក់ជាតិរបស់សមាសភាគ រៀបចំដែនដី និងនគរូបនីយកម្ម ។

យើងទាំងអស់គ្នាសង្ឃឹមថា សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ និងបានយល់ដឹងអំពីស្ថានភាព និងតំរូវការព្រមទាំងបញ្ហាប្រឈមទាំងឡាយពាក់ព័ន្ធនឹងការប្រើប្រាស់ដី ដែលរាំងស្ទះដល់ដំណើរការអភិវឌ្ឍន៍សង្កាត់ស្ទឹង វែង ហើយនឹងបង្ហាញនូវទឹកចិត្តសប្បុរសធម៌ដ៏ថ្លៃថ្លាតាមរយៈការចូលរួមផ្តល់នូវសំភារៈ និងថវិកាសំរាប់គាំទ្រដល់ការអនុវត្តផែនការប្រើប្រាស់ដីនេះ ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍មូលដ្ឋានស្រមគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ។

ធ្វើនៅស្ទឹងវែង, ថ្ងៃទី...២៦...ខែ...៥......ឆ្នាំ ២០០៩

**ចៅសង្កាត់**

**សុប ហ៊ុំសេន**

# សេចក្តីផ្តើម

កន្លងទៅថ្មីៗនេះ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ទីផ្សារអចលនៈទ្រព្យ ជាពិសេសតំលៃដីធ្លីមានការកើនឡើងគួរអោយកត់សំគាល់និយាយរួមទីផ្សារដីធ្លីនៅក្នុងសង្កាត់ស្ទឹងវែងក៏បានឡើងថ្លៃយ៉ាងខ្ពស់ដែលមិនអាចនឹកស្មានដល់។ ដោយសារការកើនឡើង នៃតំលៃដីនេះបានធ្វើអោយមានការកើតឡើងនូវបញ្ហាជាច្រើនដូចជា : ការកាប់រានទន្ទ្រានព្រៃឈើតំបន់ការពារកសាងសង់សំណង់នៅលើទីតាំងមិនសមស្របការកាប់ឈើខុសច្បាប់ការឈូសឆាយ ការហ៊ុំព័ទ្ធដីព្រៃការរំលោភយកដីរបស់រដ្ឋ..។ បញ្ហានេះប៉ះពាល់ ដល់ការការពារអភិរក្សសត្វព្រៃ ព្រៃឈើ និងធនធានធម្មជាតិទេសចរណ៍ធម្មជាតិ ជាពិសេសប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជា ពលរដ្ឋ និងការរីកចំរើននៃទីក្រុងថែមទៀត។

ការកសាងផែនការប្រើប្រាស់ដី ត្រូវបានចាត់ទុកជាមូលដ្ឋានគតិយុត្តិមួយសំរាប់ការអភិវឌ្ឍន៏ និងការប្រើប្រាស់ដីក្នុងគោលបំណងបំរើផលប្រយោជន៏សាធារណៈ។ ការរៀបចំផែនការមានប្រសិទ្ធភាពគឺជាមធ្យោបាយដ៏ប្រពៃបំផុតដើម្បីឆ្លើយតបទៅនឹងតំរូវការអភិវឌ្ឍន៏ និងកិច្ចការពារបរិស្ថាន។ ដូចនេះផែនការនេះគឺជាគន្លឹះមួយដែលរួមចំណែកដល់ការអភិវឌ្ឍន៏ប្រកបដោយចីរភាពរបស់រាជរដ្ឋាភិបាលដែលជួយដល់ការអភិវឌ្ឍន៏ចាំបាច់មួយចំនួនទៅលើទីតាំងដ៏សមស្រប និងមិនធ្វើអោយបាត់បង់នូវធនធានធម្មជាតិ សំរាប់កូនចៅជំនាន់ក្រោយ។ ផែនការនេះនឹងបង្កើតអោយមានក្របខណ្ឌការងារច្បាស់លាស់ក្នុងការរៀបចំផែនការប្រើប្រាស់ដីធ្លី និង ការវិនិយោគទូទៅផងដែរ។ តួយ៉ាងសង្កាត់ស្ទឹងវែងជាសង្កាត់មួយក្នុងចំណោមសង្កាត់ទាំងបីរបស់ក្រុងខេមរភូមិន្ទ ដែលសង្កាត់នេះត្រូវបានជ្រើសរើសជាសង្កាត់គោលដៅសំរាប់អនុវត្តន៏ផែនការប្រើប្រាស់ដីធ្លី។ ដោយមានការព្រួយបារម្ភណ៏អំពីការអភិវឌ្ឍន៏ទីសដៅមិនមានចីរភាព និងអាចបណ្តាលអោយមានការវិនាសដល់ធនធានធម្មជាតិ បរិស្ថានកាន់តែខ្លាំង និងបង្កអោយមានផលប៉ះពាល់ដល់ក៏រិតជីវភាពរស់នៅ និង សុខដុមរមនារបស់ប្រជាពលរដ្ឋនៅក្នុងសង្កាត់ស្ទឹងវែងទាំងមូល។

គោលបំណងចំបងនៃផែនការប្រើប្រាស់ដីនៅក្នុងសង្កាត់ស្ទឹងវែងនេះ គឺដើម្បីគាំទ្រដល់ដំណើរការកសាងផែនការអភិវឌ្ឍន៏សង្កាត់ និង សំរាប់ប្រើប្រាស់ក្នុងការរៀបចំអភិវឌ្ឍន៏សង្កាត់ទាំងមូលអោយចំទីសដៅប្រកបដោយនិរន្តរភាពនិងអោយស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការសំដៅពង្រឹងអភិបាលកិច្ចល្អរបស់រាជរដ្ឋាភិបាលដើម្បីលើកស្ទួយសេដ្ឋកិច្ចក៏រិតជីវ ភាពរស់នៅនិងសុខដុមរមនារបស់ប្រជាពលរដ្ឋអោយកាន់តែប្រសើឡើង។

# ជំពូក ១

## ព័ត៌មាន និងទិន្នន័យសំរាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងសង្កាត់

### ១.១ ស្ថានភាពទូទៅ

ចាប់តាំងពីក្រោយរំដោះថ្ងៃទី ០៧ ខែ មករាឆ្នាំ ១៩៧៩ សង្កាត់ស្ទឹងវែងត្រូវបានផ្លាស់ប្តូរឈ្មោះជាបន្តបន្ទាប់ដូចខាងក្រោម:

- ពីឆ្នាំ ១៩៧៩ ដល់ ឆ្នាំ ១៩៩៥ មានឈ្មោះថា សង្កាត់ ៣ ស្រុកទីរួមខេត្ត ខេត្តកោះកុង ។
- ពីឆ្នាំ ១៩៩៥ ដល់ឆ្នាំ ២០០៨ មានឈ្មោះថា ឃុំស្ទឹងវែង ស្រុកស្មាច់មានជ័យ ខេត្តកោះកុង ។
- ពីឆ្នាំ ២០០៨ រហូតដល់បច្ចុប្បន្ននេះមានឈ្មោះថា សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ។

ទឹកដីសង្កាត់ស្ទឹងវែងទាំងមូលមានប្រហែលជាមួយភាគពីរជាដីជំរកសត្វព្រៃពាមក្រសោប ។ នៅក្នុងដែនជំរកសត្វព្រៃពាមក្រសោបមានប្រជាជនកំពុងរស់នៅយ៉ាងច្រើនកុះករ នឹងកំពុងប្រកបរបរកសិកម្ម ដូចជាធ្វើស្រែធ្វើចំការជាលក្ខណៈគ្រួសារចិញ្ចឹមសត្វគោក្របី នេសាទត្រីជាដើមព្រមទាំងមានវត្តអារាមជាទីសក្ការៈបូជាសាលារៀននៅក្នុងនោះផងដែរ ។ សូមបញ្ជាក់ផងដែរថាប្រជាជនដែលកំពុងរស់នៅក្នុងជំរកសត្វព្រៃពាមក្រសោបនេះបើតាមការសាកសួរប្រជាជននៅក្នុងតំបន់នោះ គឺពួកគាត់បានមករស់នៅតាំងពី មុនថ្ងៃរំដោះ ៧ ខែ មករា ឆ្នាំ ១៩៧៩ មកម៉្លេះហើយអ្នកខ្លះទៀតរស់នៅតាំងពីឆ្នាំ ១៩៧៩ នឹងអ្នកខ្លះទៀតបានមករស់នៅក្រោយឆ្នាំ ១៩៧៩ ជាបន្តបន្ទាប់ ។

#### ១.១.១ ទីតាំងរដ្ឋបាល

| | | |
|---|---|---|
| ខេត្ត | កោះកុង | |
| ខណ្ឌ | ក្រុងខេមរភូមិន្ទ | |
| សង្កាត់ | ឈ្មោះ : ស្ទឹងវែង | លេខកូដ : ០៩០៤០៣ |
| ចំនួនភូមិ | ២ ភូមិ : ភូមិស្ទឹង វែង និង ភូមិព្រែកស្វាយ | |

សង្កាត់ស្ទឹងវែងជាសង្កាត់មួយក្នុងចំណោមសង្កាត់ទាំងបីនៃក្រុងខេមរភូមិន្ទ សង្កាត់ស្ទឹងវែងមានទីតាំងស្ថិតនៅភាគខាងត្បូងឈៀងខាងកើត នៃសាលាក្រុងខេមរភូមិន្ទមានចំងាយប្រហែល ១២០០ ម៉ែត្រ ពីក្រុងខេមរភូមិន្ទដែលមានព្រំប្រទល់:

- ខាងជើងទល់នឹងសង្កាត់ស្មាច់មានជ័យ និង ខាងត្បូងទល់នឹងឃុំពាមក្រសោប
- ខាងកើតទល់នឹងឃុំទួលគគីរ និង ខាងលិចទល់នឹងសង្កាត់ដងទង់ ឃុំប៉ាក់ខ្លង មានផ្ទៃដីសរុបចំនួន ៤០០១,៤៩២ ហិចតា ក្នុងនោះមានភូមិចំនួន ០២ គឺ ភូមិស្ទឹងវែង និង ភូមិព្រែកស្វាយ

### ផែនទីបង្ហាញទីតាំង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង




រូបទី១ : ផែនទីបង្ហាញពីទីតាំងសង្កាត់ស្ទឹងវែង

### ១.១.២ ប្រជាសាស្ត្រ

សង្កាត់ស្ទឹងវែងមានប្រជាជនសរុបចំនួន ៥៨៤ គ្រួសារ នឹងមានប្រជាជនសរុបចំនួន ២៧១៧ នាក់ ក្នុងនោះស្ត្រីមានចំនួន ១៣៦៧ នាក់ មានដង់ស៊ីតេប្រជាជន ៦៨ នាក់ ក្នុងមួយគីឡូម៉ែត្រក្រឡា។ ស្ត្រីជាមេគ្រួសារចំនួន ១០៩ គ្រួសារ (តាមឯកសារព័ត៌មានស្តីពីស្ថានភាពភូមិឆ្នាំ ២០០៩)។ របាយប្រជាជនភាគច្រើនប្រមូលផ្តុំនៅប៉ែកខាងលិចជាប់ព្រំប្រទល់សង្កាត់ដងទង់ត្រង់ម្តុំគល់ស្ពានស្វាស្ថិតនៅក្នុងភូមិស្ទឹងវែង ហើយក៏ស្ថិតនៅក្នុងតំបន់ដែនជំរកសត្វព្រៃពាមក្រសោបផងដែរ។ ប្រជាជនភាគច្រើនជាជនជាតិខ្មែរ តែក៏មានជនជាតិខ្មែរឥស្លាមចំនួន ៧៣ គ្រួសារ ស្មើ ៥៤៤ នាក់ ភាគច្រើនប្រកបរបរនេសាទ។ ជាទូទៅប្រជាជនខ្មែរភាគច្រើនកាន់ព្រះពុទ្ធសាសនា តែក៏នៅមានជំនឿទៅលើការសែនព្រេនអារក្សអ្នកតាខ្លះដែរ។

### តារាងស្ថិតិប្រជាជនសង្កាត់ស្ទឹងវែង ឆ្នាំ ២០០៨ តាមក្រុមអាយុ

| ស្ថិតិតាមក្រុមអាយុ | ប្រុស | ស្រី | សរុប | ផ្សេងៗ |
|---|---|---|---|---|
| អាយុពី ០-២ ឆ្នាំ | ៧៦ | ៧៣ | ១៤៩ | |
| អាយុពី ៣-៥ ឆ្នាំ | ៩៥ | ៧៤ | ១៦៩ | |
| អាយុពី ៦-១១ ឆ្នាំ | ១៩៨ | ២១៦ | ៤១៤ | |
| អាយុពី ១២-១៤ ឆ្នាំ | ៩៥ | ១០១ | ១៩៦ | |
| អាយុពី ១៥-១៧ ឆ្នាំ | ១១១ | ១០៤ | ២១៥ | |
| អាយុពី ១៨-២៤ ឆ្នាំ | ១៩៥ | ២០៧ | ៤០២ | |
| អាយុពី ២៥-៦០ ឆ្នាំ | ៥៣៦ | ៥៥២ | ១០៨៨ | |
| អាយុពី ៦១ ឆ្នាំឡើងទៅ | ៤៤ | ៤០ | ៨៤ | |
| ប្រជាជនសរុប | **១៣៥០** | **១៣៦៧** | **២៧១៧** | |
| ចំនួនគ្រួសារសរុប | ៥៨៤ | | | |

ប្រភព : សៀវភៅទិន្នន័យភូមិឆ្នាំ ២០០៨

### ស្ថិតិជនជាតិភាគតិចនៅក្នុងសង្កាត់

| ជនជាតិភាគតិច | ឆ្នាំ ២០០៦ | | ឆ្នាំ ២០០៧ | | ឆ្នាំ ២០០៨ | |
|---|---|---|---|---|---|---|
| | ចំនួនគ្រួសារ | ចំនួនប្រជាជន | ចំនួនគ្រួសារ | ចំនួនប្រជាជន | ចំនួនគ្រួសារ | ចំនួនប្រជាជន |
| ខ្មែរឥស្លាម | ៧២ គ្រួសារ | ៣៧២ នាក់ | ២៨ គ្រួសារ | ៣៧៧ នាក់ | ៧៣ គ្រួសារ | ៥៤៤ នាក់ |
| វៀតណាម | ០ គ្រួសារ | ០ នាក់ | ២ គ្រួសារ | ១០ នាក់ | ០ គ្រួសារ | ០ នាក់ |
| ឡាវ | ០ គ្រួសារ | ០ នាក់ | ០ គ្រួសារ | ០ នាក់ | ០ គ្រួសារ | ០ នាក់ |

ប្រភព : ឯកសារពតិមាន ស្តីពីស្ថានភាពសង្កាត់ ២០០៩

#### ១.១.៣ ភាពគ្មានដីធ្លី

- គ្រួសារដែលមានដីស្រែតិចជាង ០១ ហិចតា មានចំនួន ៦ គ្រួសារ
- គ្រួសារដែលមានដីស្រែផ្ទាល់ខ្លួនមានចំនួន ០១ គ្រួសារ
- គ្រួសារមានដីដាំដំណាំចំការតិចជាង ០១ ហិចតា មានចំនួន ៤៨ គ្រួសារ
- គ្រួសារគ្មានដីចំការផ្ទាល់ខ្លួនមានចំនួន ១០ គ្រួសារ

- គ្រួសារដែលមានផ្ទះរស់នៅលើដីសាធារណៈមានចំនួន ១៤ គ្រួសារ

ចំពោះចំនួនប្រជាជនខាងលើបច្ចុប្បន្នបានប្រកបរបរនេសាទនៅតាមព្រៃកោងកាង បឹងបួរ អូរ ដៃព្រែក និង សមុទ្រក្រៅ ដែលមុខរបរទាំងនេះជាមុខរបរបន្ទាប់បន្សំក្រៅពីការធ្វើកសិកម្មរបស់ពួកគាត់ ។

**តារាងចំនួនគ្រួសារដែលគ្មានដី និងមានដីមិនគ្រប់គ្រាន់**

| ល.រ | បរិយាយ | ចំនួនគ្រួសារ | ចំនួនភាគរយ ប្រជាជនសរុប(%) | ផ្សេងៗ |
|---|---|---|---|---|
| ១ | មានដីស្រែតិចជាង ១ ហិចតា | ០៦ | ១,០២ % | |
| ២ | គ្មានដីស្រែផ្ទាល់ខ្លួន | ០១ | ០,១៧ % | |
| ៣ | មានដីចំការតិចជាង ១ ហិចតា | ៤៨ | ៨,២១ % | |
| ៤ | គ្មានដីចំការផ្ទាល់ខ្លួន | ១០ | ១,៧១ % | |
| ៥ | មានផ្ទះនៅលើដីសាធារណៈ | ១៤ | ២.,% | |

ប្រភព: សៀវភៅទិន្នន័យភូមិឆ្នាំ ២០០៨




រូបថត១ : ផ្ទះនៅលើដីសាធារណៈ

**១.១.៤ ស្ថានភាពសេដ្ឋកិច្ច**

នៅក្នុងសង្កាត់មានប្រជាជនចំនួន ៩១ គ្រួសារ ប្រកបរបរកសិកម្មជាចំបងក្នុងនោះមានចំនួន ៣៣ គ្រួសារ ធ្វើស្រែ វស្សាដោយពឹងផ្អែកទាំងស្រុងលើទឹកភ្លៀង ៦ គ្រួសារ ប្រកបរបរដាំដំណាំរយៈពេលវែង ៥២ គ្រួសារ ដាំដំណាំបន្លែ ៤ គ្រួសារ ប្រកប របរសិប្បកម្ម ១១៤ គ្រួសារ ប្រកបរបរនេសាទ ២៦ គ្រួសារ ចិញ្ចឹមសត្វ ១៣ គ្រួសារ ប្រកបរបរអនុផលព្រៃឈើ និង ២២៦ គ្រួសារ ប្រកបរបរសេវាកម្មផ្សេងៗ។

**តារាងមុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋនៅក្នុងសង្កាត់ស្ទឹងវែង**

| ល.រ | ប្រភេទមុខរបរ | ចំនួនគ្រួសារ | ចំនួនភាគរយ | |
|---|---|---|---|---|
| ១ | **មុខរបរកសិកម្ម** | | | |
| | - ធ្វើស្រូវស្រែ | ៣៣ គ្រួសារ | ៥,៦៥% | |
| | - ដាំដំណាំរយៈពេលវែង | ៦ គ្រួសារ | ១,០២% | |
| | - ដាំដំណាំបន្លែ | ៥២ គ្រួសារ | ៨,៩% | |
| ២ | **មុខរបរនេសាទចិញ្ចឹមសត្វ អនុផលព្រៃឈើ** | | | |
| | - នេសាទ | ១១៤ គ្រួសារ | ១៩,៥២% | |
| | - ចិញ្ចឹមសត្វ | ២៦ គ្រួសារ | ៤,៤៥ % | |
| | - អនុផលព្រៃឈើ | ១៣ គ្រួសារ | ២,២២% | |
| ៣ | **មុខរបរសិប្បកម្ម** | | | |
| | - សិប្បកម្មផលិតពីដែកអាលុយមីញ៉ូម កញ្ចក់ | ៣ គ្រួសារ | ០,៥១% | |
| | - សិប្បកម្មផលិតផ្សេងៗ | ១គ្រួសារ | ០,១៧% | |
| ៤ | **មុខរបរសេវាកម្ម** | | | |
| | - មុខរបរជំនួញ | ៦៨ គ្រួសារ | ១១,៦៤% | |
| | - ធ្វើជាជាងជួសជុល | ២៧ គ្រួសារ | ៤,៦២% | |
| | - ដឹកជញ្ជូន | ១ គ្រួសារ | ០,១៧% | |
| | - សេវាកម្មផ្សេងៗ | ១៣០ គ្រួសារ | ២២,២៦% | |
| ៥ | **មុខរបរជាមន្ត្រី បុគ្គលិក កម្មករ ក្នុងក្របខណ្ឌរដ្ឋ** | ៧៣ គ្រួសារ | ១២,៥% | |
| ៦ | **មុខរបរជាបុគ្គលិក កម្មករ ក្នុងក្របខណ្ឌឯកជន** | ៣៧ គ្រួសារ | ៦,៣៣% | |
| **សរុប** | | **៥៨៤ គ្រួសារ** | | |

ប្រភព : ឯកសារពត៌មាន ស្តីពីស្ថានភាពសង្កាត់ឆ្នាំ ២០០៩

### ១.១.៥ ស្ថានភាពអប់រំ និងសិក្សាធិការ

សង្កាត់ស្ទឹងវែងមានសាលាបឋមសិក្សាតែ ១ ប៉ុណ្ណោះ មានបន្ទប់ចំនួន ៣ បន្ទប់ ស្មើនឹង ៦ ថ្នាក់ មានសិស្សានុសិស្ស សរុប៨២១នាក់ ក្នុងនោះសិស្សស្រីចំនួន៤00 នាក់។ កុមារគ្រប់អាយុដែលត្រូវចូលរៀនសរុបមាន ១៤0២នាក់ អត្រាកុមារគ្រប់ អាយុដែលមិនបានចូលរៀនមានចំនួន ៥៨១ នាក់ស្មើនឹង ៤១,៤៤% នៃចំនួនកុមារគ្រប់អាយុចូលរៀនទាំងអស់។បើតាមការពិនិត្យជាក់ ស្តែងនៅក្នុងសង្កាត់នេះមានអត្រាសិស្សដែលមិនបានចូលរៀនបណ្តាលមកពី :

- ខ្វះសាលាកំរិតមធ្យមសិក្សា (សិស្សដែលរៀនចប់បឋមសិក្សានៅសាលាបឋមសិក្សាភូមិព្រែកស្វាយត្រូវជួបបញ្ហាដោយ សិស្សត្រូវបន្តទៅរៀននៅអនុវិទ្យាល័យសម្តេច ជា ស៊ីម សង្កាត់ស្មាច់មានជ័យ ដែលមានចំងាយប្រហែល ៧ គីឡូម៉ែត្រ ឬបន្តទៅរៀន នៅវិទ្យាល័យកោះកុងមានចំងាយប្រហែល ១0 គីឡូម៉ែត្រ ដូច្នេះចំពោះសិស្សដែលក្រី ក្រត្រូវបោះបង់ចោលការសិក្សា។
- គ្រួសារខ្លះក្រីក្រគ្មានលទ្ធភាពអោយកូនទៅរៀន ,ខ្វះសាលាកំរិតសិក្សាថ្នាក់មត្តេយ្យ
- ឪពុកម្តាយមិនយល់ពីតំលៃនៃការសិក្សា និងទុកកូនអោយធ្វើការងារផ្ទះ ដោយសារជីវភាពខ្វះខាត។

ដើម្បីអោយកុមារបានចូលរៀនគ្រប់ៗគ្នា ក្រុមប្រឹក្សាសង្កាត់មានគំរោងអប់រំឪពុកម្តាយកុមារអោយយល់ពីតំលៃនៃការសិក្សា។

ដើម្បីអភិវឌ្ឍន៏វិស័យអប់រំនៅក្នុងសង្កាត់ក្រុមប្រឹក្សាសង្កាត់ បានបង្កើតកិច្ចសហការជាមួយមេភូមិនាយកសាលាគ្រូបង្រៀន និង មាតា បីតា សិស្សពិភាក្សារិះរកមធ្យោបាយក្នុងការជំរុញអោយកុមារទាំងអស់ទៅរៀនជា ប្រចាំអោយបានយ៉ាងហោចណាស់ចប់កំរិតអនុវិទ្យាល័យ ដោយសង្កាត់លើកគំរោងផែនការអភិវឌ្ឍន៏កម្មវិធីវិនិយោគផ្សព្វផ្សាយអោយទូលំទូលាយដល់ឪពុកម្តាយអោយនាំកូនចូលរៀននៅកំរិតបឋមសិក្សាដោយសាងសង់សាលាបឋមសិក្សាបន្ថែម និងអប់រំផ្សព្វផ្សាយពីតំលៃនៃការសិក្សា និងការអភិវឌ្ឍន៏ធនធានមនុស្សអោយឪពុកម្តាយរបស់សិស្សបានយល់ជ្រួតជ្រាបទូទាំងសង្កាត់។ មុនពេលបវេសនកាលនៃឆ្នាំសិក្សានីមួយៗទំនាក់ទំនងជាមួយមន្ទីរអប់រំបង្កើនចំនួនគ្រូបង្រៀននៅកំរិតបឋមសិក្សាដើម្បីលើកំពស់ផលធៀបសិស្សគ្រូសាងសង់សាលាមធ្យម បឋមសិក្សាភូមិ ដើម្បីអោយប្រជាពលរដ្ឋជាពិសេសសិស្សបានទទួលសេវាគ្រប់គ្រាន់កាត់បន្ថកចំណាយរបស់សិស្សក្រីក្រតាមរយៈការផ្តល់អាហារូបករណ៏ (បឋមសិក្សាមធ្យមសិក្សា) ពង្រីកនិងកំណត់មុខសញ្ញាអោយបានល្អជាងមុនសំរាប់កម្មវិធីផ្តល់អាហារូបករណ៏នៅបឋមសិក្សា និងកម្មវិធីលើកទឹកចិត្តសំរាប់សិស្សថ្នាក់ទី ៧ ដល់ថ្នាក់ទី ៩ ។ កាត់បន្ថយអនក្ខរជននៅមានកំរិតទាបបំផុត ។

## តារាងស្ថិតិសាលា និងចំនួនសិស្សប្រចាំឆ្នាំ ២០០៨

| ប្រភេទសាលា | ចំនួនសាលានៅឆ្នាំ ២០០៨ | | | ចំនួនកុមារ/សិស្សនៅឆ្នាំ ២០០៨ | | | អត្រាមិនបានចូលរៀន | |
|---|---|---|---|---|---|---|---|---|
| | សាលា | បន្ទប់ | ថ្នាក់ | កុមារសរុប | សិស្សសរុប | សិស្សស្រី | ចំនួនអ្នកមិនចូលរៀន | អត្រាអ្នកមិនចូលរៀន(%) |
| ថ្នាក់មត្តេយ្យសិក្សា | ០ | ០ | ០ | ១៦៩ | ៥៩ | ២៨ | ១១០ | ៦៥% |
| ថ្នាក់បឋមសិក្សា | ១ | ៣ | ៦ | ៥១៩ | ៤៤៧ | ២២៦ | ៧២ | ១៣,៨៧% |
| ថ្នាក់អនុវិទ្យាល័យ | ០ | ០ | ០ | ៣១២ | ២៣៥ | ១០៨ | ៧៧ | ២៤,៦៧% |
| ថ្នាក់វិទ្យាល័យ | ០ | ០ | ០ | ៤០២ | ៨០ | ៣៨ | ៣២២ | ៨០,០២% |

ប្រភព : ឯកសារពត៌មាន ស្តីពីស្ថានភាពសង្កាត់ឆ្នាំ ២០០៩

## ស្ថិតិគ្រូបង្រៀនប្រចាំឆ្នាំ ២០០៨

| ល.រ | ប្រភេទថ្នាក់ | ចំនួនគ្រូបង្រៀន | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រុស | ស្រី | សរុប | |
| ១ | ថ្នាក់មត្តេយ្យសិក្សា | ០ | ០ | ០ | |
| ២ | ថ្នាក់បឋមសិក្សា | ៣ នាក់ | ០ នាក់ | ០ នាក់ | |
| ៣ | ថ្នាក់អនុវិទ្យាល័យ | ០ | ០ | ០ | |
| ៤ | ថ្នាក់វិទ្យាល័យ | ០ | ០ | ០ | |
| ៦ | កីឡាវិទ្យាល័យចុះ (សាលាឯកជន) | ៥ នាក់ | ១ នាក់ | ៦ នាក់ | |

ប្រភព : ទិន្នន័យសង្កាត់ឆ្នាំ ២០០៨




រូបថត ២ : សាលារៀន

### ១.១.៦ ស្ថានភាពសុខាភិបាល

#### ១.១.៦.១ ផ្នែកសុខាភិបាល

ស្ថានភាពសុខភាពរបស់ប្រជាជនមិនទាន់ចាត់ទុកថាល្អប្រសើទៅតាមបំណងប្រាថ្នា ដែលកំណត់ឡើងនៅក្នុងគោលដៅសហាវត្សរ៍ និងទីសដៅវិស័យនោះឡើយ។ ប្រសិនបើប្រជាជនមានសុខភាពល្អការប្រកបមុខរបរចិញ្ចឹមជីវិតបានប្រក្រតី មិនខាតបង់ពេលវេលា និងទ្រព្យសម្បត្តិទៀតផង។ ការមានជំងឺ ឬមានសុខភាពមិនល្អ ជាកត្តាចំបងដែលនាំអោយគ្រួសារមួយចំនួនធ្លាក់ទៅក្នុងភាពក្រីក្រ។ ការកែលំអសេវាសុខភាពដែលផ្តល់តាមរយៈមណ្ឌលសុខភាពការអប់រំប្រជាជនក្នុងសង្កាត់អោយបានយល់ដឹងពីសារសំខាន់ នៃការនាំកូនទៅចាក់ថ្នាំបង្ការកែប្រែទំលាប់ពីការសំរាលកូនដោយឆ្មបបុរាណអោយមកប្រើប្រាស់សេវាកម្មឆ្មប ដែលធានាសុវត្ថិភាពគឺជាការចាំបាច់ដែលត្រូវការគាំទ្រ និងកិច្ចសហការទាំងប្រជាជន ទាំងបុគ្គលិកសុខាភិបាលជំនាញ។

នៅក្នុងសង្កាត់មានមណ្ឌលសុខភាព ០១ កន្លែង នៅក្នុងភូមិស្ទឹងវែងតែទោះជាយ៉ាងណាក្តីឆ្នាំកន្លងទៅទូទាំងសង្កាត់មានស្ត្រីសំរាលកូនដោយធ្មបបុរាណមានចំនួន ០២ នាក់ គឺភាគច្រើនស្ថិតនៅក្នុងភូមិព្រែកស្វាយ ដែលនៅឆ្ងាយពី មណ្ឌលសុខភាព។ កុមារមិនទាន់ចាក់ថ្នាំបង្កាគ្រប់ចំនួនមាន ១០ នាក់ ស្ថិតនៅក្នុងភូមិស្ទឹងវែង និង ភូមិព្រែកស្វាយចំនួន មរណៈភាពកុមារអាយុក្រោម ៥ ឆ្នាំ សរុប ០១ នាក់។ សំរាលកូនដោយធ្មបបុរាណនៅក្នុងសង្កាត់មាន

ចំនួនច្រើននៅឡើយ។ ប្រការនេះអាចបណ្តាលអោយប៉ះពាល់អាយុជីវិតម្តាយ និងទារក និងធ្វើអោយជួបប្រទះបញ្ហាសុខភាពទ្រុឌទ្រោមចំណាយថវិការច្រើននៅការព្យាបាលធ្វើអោយជីវភាពគ្រួសារធ្លាក់ចុះ។ កត្តាដែលមិនបានទទួលសេវាកម្មមណ្ឌលសុខភាពរបស់ប្រជាជនមួយចំនួននេះមកពីប្រជាជនមិនយល់ពីផលប៉ះពាល់សុខភាពនៃការសំរាលកូនដោយឆ្មបបុរាណពួកគាត់មានជំនឿលើឆ្មបបុរាណតាំងពីដើមមក បញ្ហាជីវភាពរបស់ប្រជាជនមានការខ្វះខាតមិនអាចទទួលយកបាននូវសេវាសុខភាពដែលមានចំណាយថវិកា។ ដើម្បីដោះស្រាយបញ្ហាខាងលើការបណ្តុះបណ្តាលដល់ឆ្មបបុរាណ ដែលមានស្រាប់ជាប្រចាំអោយមានចំណេះដឹងពីជំនាញបន្ថែម និង ផ្តល់សំភារៈឧបករណ៍សំរាប់ជាជំនួយសេវាឆ្មប។ បណ្តុះបណ្តាលអោយមានឆ្មបប្រចាំភូមិណាដែលមិនទាន់មានឆ្មបពេទ្យនៅឡើយ និង ផ្សព្វផ្សាយដល់ស្ត្រីទាំងអស់អោយយល់ដឹងពីសុខភាពអនាម័យយល់ដឹងពីសញ្ញានានាដែលត្រូវប្រុងប្រយ័ត្ននៅពេលមានផ្ទៃពោះ និង នៅពេលសំរាលជំរុញអោយស្ត្រីទៅពិនិត្យផ្ទៃពោះគ្រប់រូប និងពិនិត្យផ្ទៃពោះនៅមណ្ឌលសុខភាពអោយបាន ២ ដងយ៉ាងតិច។

**តារាងស្ថិតិមណ្ឌល/ប៉ុស្តិ៍សុខភាព និងចំនួនគ្រូពេទ្យ**

| ល.រ | មណ្ឌល/ ប៉ុស្តិ៍សុខភាព | សមត្ថភាពផ្គត់ផ្គង់ | | | | | |
|---|---|---|---|---|---|---|---|
| | | ចំនួនកន្លែង | គ្រែ/បន្ទប់ | វិជ្ជបណ្ឌិត | គ្រូពេទ្យ | ពេទ្យឆ្មប | ឆ្មបបុរាណ |
| ១ | ប៉ុស្តិ៍សុខភាពភូមិ | 0 | 0 | 0 | 0 | | |
| ២ | មណ្ឌលសុខភាព | ០១ កន្លែង | 0 | 0 | 0 | ៥ នាក់ | ៣ នាក់ |

ប្រភព : សៀវភៅទិន្នន័យភូមិឆ្នាំ ២០០៨

**១.១.៦.២ ការផ្គត់ផ្គង់ទឹកស្អាត**

បញ្ហាសុខភាពរបស់ប្រជាជនវាមានការពាក់ព័ន្ធដល់ការប្រើប្រាស់ទឹកដែលមានកត្តាសំខាន់ផងដែរ។ នៅក្នុងសង្កាត់ មានអណ្តូងលូសរុបចំនួន ២៣២ អណ្តូង ក្នុងនោះអណ្តូងមិនអាចប្រើប្រាស់បាននៅរដូវប្រាំង(ទឹកមិនចេញ) មានចំនួន ០៥ អណ្តូង អណ្តូងទឹកដែលត្រូវការចាំបាច់ធ្វើការជួសជុលឬស្តាឡើងវិញមានចំនួន ០១ អណ្តូង។ អណ្តូងដៃមិនដាក់លូឬរៀបឥដ្ឋសរុបចំនួន ១២ អណ្តូង។ ស្រះទឹកដែលអ្នកភូមិប្រើប្រាស់ និងទទួលទានសរុបមានចំនួន ១០ ស្រះ។

**ស្ថិតិប្រភពទឹកប្រើប្រាស់នៅក្នុងសង្កាត់**

| ល.រ | ប្រភពទឹក | ចំនួនប្រភពទឹក | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | សរុប | ប្រើបាន | ខូច | |
| ១ | អណ្តូងលូ | ២៣២ អណ្តូង | ២៣១ អណ្តូង | ១ អណ្តូង | ជួសជុលឬស្តារឡើងវិញ |
| ២ | អណ្តូងដៃមិនដាក់លូ | ១២ អណ្តូង | ១២ អណ្តូង | 0 | ប្រើប្រាស់បានទាំងអស់ រដូវវស្សារដូវប្រាំង |

| | | | | | |
|---|---|---|---|---|---|
| ៣ | ស្រះទឹក | ១០ ស្រះ | ១០ ស្រះ | 0 | ប្រើប្រាស់បានទាំងរដូវវស្សា និង រដូវប្រាំង |

ប្រភព : សៀវភៅទិន្នន័យឆ្នាំ ២០០៨



រូបថត ៣ : អណ្តូងទឹកលូ និងអណ្តូងដៃ

## ១.២ ស្ថានភាពភូមិសាស្ត្រ

### ១.២.១ ទីតាំងភូមិសាស្ត្រ

សង្កាត់ស្ទឹងវែងមានទីតាំងស្ថិតនៅស្របតាមបណ្តោយព្រែកទួលគគីរផ្នែកខាងត្បូង និងស្ថិតនៅស្របតាមបណ្តោយ ផ្លូវជាតិលេខ ៤៨ ផ្លូវសេរីកា និងផ្លូវព្រែកស្វាយនៅផ្នែកខាងជើង។ សង្កាត់ស្ទឹងវែងមានស្ថានភាពដី ២ ខុសគ្នា គឺផ្នែកខាងជើង នៃសង្កាត់ទាំងមូលជាតំបន់ខ្ពង់រាបមានដីល្បាយខ្សាច់លាយឡំជាមួយដីក្រហម ដីប្រភេទនេះសំបូរជីវជាតិច្រើនចំណែកឯផ្នែកខាងត្បូង នៃសង្កាត់ជាតំបន់វាលទំនាបដីជាប្រភេទដីខ្សាច់ពុំសូវមានជីវជាតិ ដីមានសណ្ឋានជាទឹករលកដីនៅទីទួលជាប្រភេទដីខ្សាច់ខ្សោះជីវ ជាតិ រីឯដីនៅទីទាបជាប្រភេទដីភក់មានជីវជាតិគួសម។

សង្កាត់ស្ទឹងវែងស្ថិតវែងនៅក្នុងរយៈកំពស់រែបប្រួលពី 0-៣៦ ម

- ផ្នែកខាងត្បូងនៃសង្កាត់ស្ទឹងវែងមួយភាគធំមានរយៈកំពស់ពី 0-៨ ម
- ផ្នែកខាងជើងឈៀងខាងកើតនៃសង្កាត់ស្ទឹងវែងមួយភាគតូចមានរយៈកំពស់ពី ៨-៣៦ ម

ផែនទីរយៈកំពស់ ក្នុងសង្កាត់ស្ទឹងវែង




រូបទី ២ : ផែនទីរយៈកំពស់ក្នុងសង្កាត់ស្ទឹងវែង

### ១.២.២ អាកាសធាតុ

នៅក្នុងខេត្តកោះកុងយើងសង្កេតឃើញថាមានរដូវពីរផ្សេងគ្នាគឺរដូវប្រាំង និងរដូវវស្សា ដែលរដូវប្រាំងមានចំនួន០៥ខែគឺចាប់ពីខែធ្នូរហូតដល់ខែមេសាប៉ុន្តែក៏មានការប្រែប្រួលដោយជួនកាលមានរាំងភ្លៀងនៅពាក់ កណ្តាលខែវិច្ឆិកាផងដែរ។ ដោយឡែកខេត្តកោះកុងគឺជាខេត្តមួយដែលមានភ្លៀងធ្លាក់ច្រើនជាងគេព្រោះវាជាខេត្តដែលនៅជាប់នឹងសមុទ្រហើយហ៊ុំព័ទ្ធទៅដោយប្រជុំភ្នំ (ជួរភ្នំក្រវាញ) ដែលវាជារនាំងបាំងចំហាយទឹកភ្លៀង និងខ្យល់មួយភាគធំ។ ដូច្នេះកត្តាទាំងនេះដែលជាហេតុធ្វើអោយអំណោយផលយ៉ាងខ្លាំងចំពោះខេត្តកោះកុង ។ នៅក្នុងរយៈពេលពីឆ្នាំ១៩៩៩-២០០៨ យើងសង្កេតឃើញថាបរិមាណទឹកភ្លៀងធ្លាក់ច្រើនជាងគេ គឺក្នុងកំឡុងឆ្នាំ ២០០៧ ដែលមានប្រមាណ ៨៩.៨៦០ មម ជាពិសេសក្នុងខែកក្កដា។

**តារាង កំពស់ទឹកភ្លៀង**

| ស្ថានភាព | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ១៩៩៩ | ០ | ១.៤៣៨ | ១.៦០១ | ៤.៦១៧ | ៦.៨៤២ | ២.២២៦ | ៩.០១៦ | ៤.១០៥ | ២.៩៤៦ | ១.៨៣៣ | ០ | ០ |
| ២០០០ | ១.១៧៣ | ៧៨៥ | ៧៤២ | ១៤៨ | ៧.៨០៩ | ៤.៥០៧ | ១០.៤៨១ | ១៥.៣១៦ | ២០៣ | ៤.២៨៩ | ៤៣ | ៩៥៦ |
| ២០០១ | ១.២១៩ | ៨.០៨០ | ១.៥៥៧ | ២.២៤៤ | ១១.៥៧៥ | ៥.៨៤៤ | ៧.១២១ | ៩.៣១៦ | ៤.២៧១ | ៣.៥៦៩ | ២៦ | ៩១ |
| ២០០២ | ០ | ០ | ៨៦៣ | ១៧២ | ៧.៨២៤ | ៣.៦៩៣ | ៥.០៤៣ | ៨.៨៦២ | ៦.០៤៤ | ៧៧ | ៧៩៥ | ៣៨២ |
| ២០០៣ | ០ | ៣៧៧ | ៣៨៧ | ៩១៣ | ២.៩១៤ | ២.៥១៣ | ៩.២៩៤ | ៥.៩៣៨ | ៤.៩៣៩ | ៣.៧២៤ | ៥ | ០ |
| ២០០៤ | ៤៧៤ | ៩៤៤ | ៥៤៨ | ៣៧២ | ៦៩៤ | ១.៨២៩ | ៨.៧២១ | ១០.៥២២ | ២៤២ | ២.៤៥៧ | ៦០៥ | ០ |
| ២០០៥ | ០ | ០ | ០ | ១.៣៣២ | ៧.២៧៧ | ៣.៣៧៦ | ១០.៤០៨ | ៤៦៦ | ៦.២៧៤ | ២.២២៦ | ០ | ០ |
| ២០០៦ | ៤៨៧ | ១.៤៧៧ | ៦៤៩ | ១.០៥៥ | ៤.១៣៧ | ៥.៩២៦ | ១៧.១៧៤ | ៨.៦៩២ | ៥.៨៤២ | ៥.២៨៥ | ១២៣ | ៦២ |
| ២០០៧ | ៦៦ | ៣២ | ៤៧៨ | ២.៥៩៦ | ៤.២៨៨ | ៣.១៩១ | ៨៩.៨៦០ | ៧.៤៦៨ | ៧.៥៧៣ | ២.៦៥៩ | ៤៧៥ | ១៩១ |
| ២០០៨ | ២៨ | ៤៧៧ | ១.០៨៥ | ៣.៤៧៧ | ៥.៥៨២ | ៦.៣៨៨ | ៧.០១២ | ៧.៦០៧ | ៦.៥១២ | ២.៧៣៩ | ៦០ | ៣៨៥ |

ប្រភព : នាយកដ្ឋានឧតុនិយម និងជលសាស្ត្រ




ក្រាហ្វិក ១ : កំពស់ទឹកភ្លៀងប្រចាំឆ្នាំ/ខែ

### ១.២.៣ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន

នៅក្នុងសង្កាត់ស្ទឹងវែង មានហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់កាត់គ្នាខ្វាត់ខ្វែងយ៉ាងច្រើនគួរអោយកត់សំគាល់ផ្លូវទាំងនោះមានដូចជា ផ្លូវកៅស៊ូ ផ្លូវបេតុង ផ្លូវគ្រួសក្រហម ផ្លូវដីស និងផ្លូវថ្មើជើងជាដើម ។

-ផ្លូវកៅស៊ូមានចំនួន ០២ ខ្សែ ០១ ខ្សែជាផ្លូវជាតិ និង ០១ ខ្សែទៀតជាផ្លូវខេត្ត ស្ថិតនៅតាមព្រំប្រទល់អន្តរសង្កាត់គឺរវាងសង្កាត់ស្ទឹងវែង និងសង្កាត់ស្នាច់មានជ័យ ខ្សែមួយផ្លូវទៀតចាប់ពីកែងផ្លូវចូលវត្តទៅវត្តទេព និមិត្តជលសា (ហៅវត្តថ្មី) រហូតដល់មុខសាលាក្រុងខេមរភូមិន្ទ មានប្រវែង៤៦៩ម ខ្សែទី ២ ជាផ្លូវជាតិចាប់ពីផ្លូវកែងសេរីការហូតដល់ព្រែកទួលគគីរ (ហៅជ្រោះតាប៉ន) មានប្រវែង ១៦៤៦ ម ។

- ផ្លូវបេតុងមានចំនួន ០២ខ្សែ : -ផ្លូវបេតុង ០១ខ្សែស្ថិតនៅខាងកើតផ្ទះលោក នី ម៉ាលីមានប្រវែង ១៤៧ ម ។
- ផ្លូវបេតុង ០១ខ្សែទៀតស្ថិតនៅពីស្ពានស្វាមកដល់ផ្លុនកែងវិហារឥស្លាមមានប្រវែង ១៨០ ម ។
- ផ្លូវគ្រួសក្រហមមានចំនួនច្រើនខ្សែ មានប្រវែងសរុប ២៩៧៣៩ ម ។

- ផ្លូវដីសមានចំនួនច្រើនខ្សែមានប្រវែងសរុប ៩១២៤ ម ។
- ផ្លូវថ្មើរជើងមានចំនួនច្រើនខ្សែមានប្រវែងសរុប ២៥៨៤៧ ម ។

## តារាងស្ថិតិផ្លូវថ្នល់នៅក្នុងសង្កាត់ស្ទឹងវែង

| ល.រ | ប្រភេទផ្លូវ | ចំនួនកន្លែង | ប្រវែង | ផ្សេងៗ |
|---|---|---|---|---|
| ១ | ផ្លូវកៅស៊ូ ( ផ្លូវជាតិ) | ០១ ខ្សែ | ១៦៤៦ម | |
| ២ | ផ្លូវកៅស៊ូ ( ក្នុងខេត្ត) | ០១ ខ្សែ | ៤៦៩ម | |
| ៣ | ផ្លូវបេតុង | ០២ខ្សែ | ៣២៧ម | |
| ៤ | ផ្លូវគ្រោះក្រហម | ខ្សែ | ២៩.៧៣៩ម | |
| ៥ | ផ្លូវដីស | ខ្សែ | ៩១២៤ម | |
| ៦ | ផ្លូវថ្មើរជើង | ខ្សែ | ២៥៨៤៧ម | |

ប្រភព : ទិន្នន័យពតិមានភូមិសាស្ត្រ បានធ្វើបច្ចុប្បន្នភាព



រូបថត ៤ : ផ្លូវលំក្រាលគ្រួសក្រហម និងផ្លូវកៅស៊ូ

## ១.៣ ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

### ១.៣.១ ស្ថានភាពនៃការប្រើប្រាស់ដី

នៅក្នុងសង្កាត់ស្ទឹងវែងគេបែងចែក ៥ ចំណាត់ថ្នាក់ប្រើប្រាស់ដីសាមញ្ញាមានដូចជា ដីលំនៅដ្ឋាន.ដី កសិកម្ម (ស្រែ វស្សាដីចំការឈើហូបផ្លែចំការស្វាយចន្ទី) ដីព្រលិចទឹក (ព្រៃដុះតាមមាត់ទឹក ព្រៃលិចទឹក..) ដីវាលស្មៅ (ព្រៃកាប់ឆ្ការ) ផ្ទៃទឹក (បឹង អូរ បឹងមានទឹកជាប្រចាំ) ។

**តារាងប្រភេទនៃការប្រើប្រាស់ដីលំអិត**

| ល.រ | ប្រភេទនៃការប្រើប្រាស់ដី | ទំហំ (ហ.ត) | ចំណាត់ថ្នាក់មូលដ្ឋាន |
|---|---|---|---|
| ១ | ដីលំនៅដ្ឋាន-ភូមិ | ១០៤,២៤៧៦ | ផ្ទះ, ដំណាំឈើហូបផ្លែ, ស្រែ |
| ២ | ដីលំនៅដ្ឋានទីប្រជុំជន | ១១២,៦៣៨៧ | ផ្ទះ, ឈើហូបផ្លែ |
| ៣ | ដីស្រែវស្សា | ១២២,១៩៧១ | ស្រែស្រូវវស្សា |
| ៤ | ដីស្រែជាមួយភូមិ | ៥១,៦៨៩ | ស្រែស្រូវវស្សា ផ្ទះ ដំណាំឈើហូបផ្លែ |
| ៥ | ចំការឈើហូបផ្លែ | ៣៤៧,៣៥៥៥ | ឈើហូបផ្លែ, ផ្ទះ, ដំណាំរួមផ្សំ |
| ៦ | ចំការស្វាយចន្ទី | ៨,៩៩២៣ | ស្វាយចន្ទី |
| ៧ | ស្រែក្នុងបឹង. អូរ | ៣៨,២៤២៣ | ដីស្រែ, រុក្ខជាតិតូចលិចទឹក.. |
| ៨ | ព្រៃដុះតាមមាត់ទឹក (អូរ,ស្ទឹង) | ១៣,២៣១៦ | ព្រៃគម្ពោត |
| ៩ | ព្រៃលិចទឹក (ព្រៃកោងកាង) | ៥៧២,៦៧១៨ | ព្រៃកោងកាង... |
| ១០ | ព្រៃលិចទឹកស្តើង (ព្រៃកោងកាង) | ៣២៨,១០៨៥ | ព្រៃកោងកាង, លំនៅដ្ឋាន, ស្រែ |
| ១១ | វាលស្មៅ | ៨៥៨,៤៧៩២ | ដីបោះបង់ចោល, ដីស្រែបោះបង់ចោល |
| ១២ | ព្រៃកាប់ឆ្ការ | ៨៧៧,១១៥៥ | ដីព្រៃ, លំនៅដ្ឋាន, ចំការឈើហូបផ្លែ |
| ១៣ | បឹង | ០,១៦០២ | បឹង |
| ១៤ | អូរ, ស្ទឹង, ទន្លេ | ០,៨២៧៩ | អូរ, ស្ទឹង, ទន្លេ |
| ១៥ | សមុទ្រ | ៥១៨,០៨៧៦ | សមុទ្រ |
| ១៦ | បឹងមានទឹកជាប្រចាំ | ១,៥៥៣៨ | បឹងដែលស្ថិតនៅក្នុងព្រៃលិចទឹក |
| ១៧ | បឹងមានទឹកនៅរដូវវស្សា | ៣,៥០៩៦ | ព្រៃដុះតាមមាត់ទឹក, វាលស្មៅ.... |
| ១៨ | ស្រះ | ៤,៣១១៦ | ស្រះ |
| ១៩ | ដីស្រែបង្គា | ៧៣,៤៥០១ | ស្រែបង្គា |

ប្រភព : លំអិតអំពីប្រភេទនៃការប្រើប្រាស់ដីនីមួយៗ មានពិពណ៌នាលំអិតនៅក្នុងឧបសម្ព័ន្ធ ១ និង មានភ្ជាប់ជាមួយនូវផែនទីប្រើប្រាស់ដីលំអិត និងសាមញ្ញខ្នាត A3) **ផ្ទៃដីសរុបចំនួន ៤០៣៦** , ៨៦៩៩ ហិចតា

### ១.៣.២ ស្ថានភាពនៃការកាន់កាប់គ្រប់គ្រងដី

ស្ថានភាពនៃការកាន់កាប់ដីនិងគ្រប់គ្រងដីនៅក្នុងសង្កាត់ស្ទឹងវែង ក្រៅពីដីលំនៅដ្ឋាន ដីស្រែចំការដែលជាកម្មសិទ្ធិរបស់ឯកជន គឺសុទ្ធសឹងជាដីសាធារណៈរបស់រដ្ឋទាំងអស់ដែលឋិតនៅ ក្រោមរូបភាពដូចខាង ក្រោមដូចជា:

- តំបន់ការពារពាមក្រសោប : តំបន់ដែនជំរកសត្វពាមក្រសោប

បច្ចុប្បន្នស្ថានភាពកាន់កាប់រាតដីព្រៃយកទៅធ្វើជាកម្មសិទ្ធិ រឺ យកទៅលក់ដូរដែលបង្កអោយទៅជាបញ្ហាទំនាស់ដីធ្លី និង កាប់បំផ្លាញព្រៃលិចទឹក ដែលជាកត្តាធ្វើអោយរិចរិលដល់ធនធានទាំងនោះ ។

**តារាងសង្ខេបស្ថានភាពកាន់កាប់ និងគ្រប់គ្រងដី**

| ល.រ | ប្រភេទនៃការគ្រប់គ្រង | ទំហំដី( ហ.ត) | ផ្សេងៗ |
|---|---|---|---|
| ១ | ដែនជំរកសត្វព្រៃពាមក្រសោប | ២,៦៩៤,៣៤ | |

ប្រភព : ក្រសួងបរិស្ថាន/មន្ទីរបរិស្ថាន

### ១.៣.៣ ផលិតកម្មកសិកម្ម

សង្កាត់ស្ទឹងវែងមានផ្ទៃដីសំរាប់ផលិតកម្មដំណាំស្រូវវស្សាមានចំនួន ២៥០ ហត ដែលប្រជាជនបានធ្វើការដាំដុះទិន្នផលដែលទទួលបាន ១,៩ តោន/ហត ។ ស្ថានភាពបច្ចុប្បន្ននៅក្នុងសង្កាត់ស្ទឹងវែងប្រជាជនភាគច្រើននៅទីនោះ ប្រើពូជស្រូវដែលគាត់ជ្រើសរើសយកមកដាំដុះគឺពូជស្រូវស្រាល ( ដាំរយៈពេលខ្លីទទួលផល) ។ សង្កាត់នេះពុំមានប្រព័ន្ធធារាសាស្ត្រដើម្បីធ្វើការស្រោចស្រពទេគឺពឹងផ្អែកទាំងស្រុងទៅលើទឹកភ្លៀង ចំពោះការប្រកបការងារកសិកម្មនេះពួកគាត់ធ្វើទៅតាមទំលាប់គ្មានបច្ចេកទេសដាំដុះត្រឹមត្រូវគ្មានការជ្រើសរើសពូជការប្រើប្រាស់ជីពុំតាមបច្ចេកទេសធ្វើអោយដីខូចគុណភាព( ដីហិល , ដីរឹងខ្សោះជីវជាតិ) ធ្វើអោយទិន្ន ផលស្រូវថយចុះ និង ធ្វើអោយស្រូវមានជំងឺ ( ស្លឹកស្រូវក្រហមហើយតឿ,សត្វល្អិត......) ។

**តារាងប្រភេទដំណាំកសិកម្មសំខាន់ៗ និងទិន្នផលទទួលបាន**

| ល.រ | ប្រភេទកសិកម្ម | ផ្ទៃដី ( ហត) | | ផល/ទិន្នផល | |
|---|---|---|---|---|---|
| | | សរុប ( ហត) | ដាំបាន ( ហត) | ផលសរុប ( តោន) | ទិន្នផល ( ត/ហត) |
| ១ | ដំណាំស្រូវវស្សា | ១២២,១៩៧១ | ២៥ | ៣៧.៥ | ១.៥ |

ប្រភព : ឯកសារពត៌មាន ស្តីពីស្ថានភាពឃុំ

បច្ចុប្បន្នការងារកសិកម្មដូចដែលបង្ហាញខាងលើ គឺពឹងផ្អែកទាំងស្រុងទៅលើទឹកភ្លៀងបច្ចុប្បន្ននៅក្នុងសង្កាត់ស្ទឹងវែង បាននឹងកំពុងជីកប្រឡាយទឹក៥៥០ម ( ប្រឡាយរំដោះទឹកភ្លៀង) ចេញពីភូមិអោយហូរធ្លាក់ទៅតំបន់ទំនាប ( ត្រពាំង.ដីស្រែ) ក្នុងនោះដែរមានទ្វារទឹកប្រវែងប្រមាណ ១២០,០០០ម សំរាប់រំដោះទឹកសំរាប់ធ្វើការស្រោចស្រពលើដំណាំស្រូវផងដែរ ។

**តារាងក្រឡាផ្ទៃតាមផលិតភាពដី និងការប្រើប្រាស់ និងផលិតផល**

| ល.រ | ចំណាត់ថ្នាក់ដីមានជីវជាតិ (តាមបច្ចេកទេស | ចំណាត់ថ្នាក់ដីមានជីវជាតិ (តាមមូលដ្ឋាន) | ផ្ទៃក្រឡា ( ហត) |
|---|---|---|---|
| ១ | **ដីមានផលិតភាពទាប** | **ល្បាយខ្សាច់ និងល្បាយឥដ្ឋ** | |
| | - ដីចំការស្វាយចន្ទី | - ដំណាំស្វាយចន្ទី | ១៤,៨០ |
| | - ព្រៃកាប់ឆ្ការ | - ដីលំនៅដ្ឋាន, ដីស្រែ, ចំការឈើហូបផ្លែ | ៨៥១ |
| | - វាលស្មៅ | - វាលស្មៅ.... | ៨៥៧ |
| | - ដីហេដ្ឋារចនាសម្ព័ន្ធ | - ដីផ្លូវ.ដីសាលារៀន.. | ០,១៦០២ |
| | - បឹង | -បឹង | ២,៣៩ |
| | -ព្រៃកោងកាង | - ព្រៃកោងកាង | ៥៧៣ |
| | - ចំការឈើហូបផ្លែ | - ត្របែក. ខ្នុរ. ស្វាយ. ដូង. ល្មុត .. | ៤៨៩ |
| | - បឹងមានទឹកជាប្រចាំ | - បឹង | ២,៣៩ |
| | - ស្រះ | - ស្រះ | ៤ |
| | -ព្រៃកោងកាងស្តើង | - ព្រៃកោងកាងស្តើង | ២៤៨ |
| | - ស្រែក្នុងបឹង/អូរ | - ស្រែ | ៣៨ |
| | - ដីស្រែជាមួយភូមិ | - លំនៅដ្ឋាន. ដីស្រែ. ដំណាំរួមផ្សំ | ៥១,៧០ |
| | -ព្រៃដុះតាមមាត់ទឹក | - ព្រៃកោងកាង ... | ១២ |
| | - អូរ/ស្ទឹង | - អូរ.ស្ទឹង | ៦ |
| | - សមុទ្រ | - សមុទ្រ | ៤៧៦ |
| | - បឹងមានទឹកនៅរដូវវស្សា | - បឹងមានទឹកនៅរដូវវស្សា | ៣,៥០ |
| | - ព្រៃដុះឡើងវិញ | - ព្រៃគម្ពោត.. | ០,០១ |
| | - ស្រែបង្ហា | - ស្រែបង្ហា | ៦៣ |
| | - ដីលំនៅដ្ឋានទីប្រជុំ | - លំនៅដ្ឋាន. ដំណាំឈើហូបផ្លែ.. | ១០៧ |
| | - ដីលំនៅដ្ឋានភូមិ | - លំនៅដ្ឋាន. ដំណាំឈើហូបផ្លែ. បន្លែ.. | ៥៤ |
| | - ដីស្រែវស្សា | - ដីស្រែ | ១៦៣ |

ប្រភព: ទិន្នន័យពតិមានភូមិសាស្ត្រ (GIS) **៤០១៥ . ៩៥០២**

ផែនទីផលិតភាពដី ក្នុងសង្កាត់ស្ទឹងវែង




រូបទី ៣ : ផែនទីបង្ហាញពីផលិតភាពដី

### ១.៣.៤ ធនធានធម្មជាតិ

#### ១.៣.៤.១ ធនធានព្រៃឈើ

សង្កាត់ស្ទឹងវែងគឺសង្កាត់មួយសំបូរទៅដោយព្រៃលិចទឹក ដែលប្រភេទព្រៃទាំងនេះវាមានសារៈសំខាន់ណាស់សំរាប់មនុស្ស និងសត្វផ្សេងៗ។ នៅក្នុងនោះវាមិនត្រឹមជាប្រភពថាមពលដែលមានតំលៃទេវាថែមទាំងជាទីជំរកសំរាប់ពពួកសត្វស្លាប និង មច្ឆាជាតិផ្សេងៗទាំងពួងទៀតផង។ ជាពិសេសជាជំរកសត្វស្លាបដែលវាតែងតែហោះឆ្លងកាត់ពីប្រទេស.ថៃហើយឆ្លងប្រទេសយើងហើយមកជ្រកនៅទីនេះ ដែលវាជាកន្លែងមួយជាជំរកដ៏ល្អសំរាប់ពពួកសត្វនោះ។ ម្យ៉ាង

ទៀតប្រភេទព្រៃទាំងនេះ ជាជំរកពពួកមច្ឆាជាតិទាំងពួង (ប្រភេទទឹកប្រៃ)រួមមាន ត្រីឆ្លង់ បង្កា ក្តាម ខ្យង មឹក... ហើយព្រៃលិចទឹកទាំងនោះមានព្រៃកោងកាង, ស្មាច់ .......។ ដោយឡែកព្រៃលិចទឹក ទាំងនេះបច្ចុប្បន្នត្រូវបានចងក្រងជាសហគមន៏ដែលហៅឈ្មោះថាសហគមន៏ពាមក្រសោបដើម្បីធ្វើការអភិរក្សនូវប្រភេទ ធនធានធម្មជាតិរួមទាំងជីវចំរុះនៅក្នុងនោះផងដែរ។ ជាពិសេសទៅទៀតជំរុញកន្លែងនេះអោយក្លាយទៅជាកន្លែងទាក់ទាញនូវភ្ញៀវទេសចរណ៏ធម្មជាតិមកកំសាន្តនៅទីនោះ ហើយបានធ្វើការកែលំអរ និង ថែរក្សាដើម្បីទាញយកនូវផលប្រយោជន៏ដែលមានស្រាប់តាំងពីធម្មជាតិ។ បើ ទោះបីជាមានអំណោយផលពីធម្មជាតិ ក៏ដោយប៉ុន្តែតំបន់នេះត្រូវបានគេកាប់ឆ្ការរុករានទន្រ្ទានយកដីមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនខ្លះទៅហើយ។

#### ១.៣.៤.២ ធនធានជលផល

នៅក្នុងសង្កាត់នេះសំបូរទៅដោយអូរដែលមានប្រវែងប្រមាណ ០,៨២៧៥ ហត ហើយមានបឹងប្រវែង ០,១៦០២ ហត ហើយនៅប៉ែកខាងលិចសង្កាត់មានសមុទ្រមានប្រវែងប្រមាណ៥១៦,០៨៧៦ ហត។ តំបន់ទាំងនេះសំបូរត្រីទឹកសាប និងត្រីទឹកប្រៃ ដែលត្រីទឹកសាបមានដូចជា : ត្រីរ៉ស់,ត្រីផ្ទក់,ត្រីអណ្តែង,ត្រីក្រាញ់,ត្រីកំផ្លាញ,ត្រីកន្ធរ,អន្ទង់, ក្តាម,ខ្យង និងខ្ចៅ។ ដោយឡែកត្រីទឹកប្រៃមានដូចជា ត្រីឆ្លង់សរ,ត្រីបបែល, ត្រីឆ្លាម, ត្រីបាលាំង, ត្រីខ្យុក,ត្រីសំប៉ាន់, ត្រីកាម៉ុង, បង្កា ក្តាម ខ្យង...។ ប្រភេទធនធានជលផលទាំងអស់នោះវាមានសារៈសំខាន់ណាស់សំរាប់ប្រជាពលរដ្ឋដែលរស់នៅតំបន់នោះជាពិសេសទៅទៀតពពួកធនធានទាំងនោះជាមុខរបរចំបងរបស់ពួកគាត់តែម្តង។ នៅក្នុងសង្កាត់ស្ទឹងវែងប្រកបរបរនេសាទនេះ គឺពួកគាត់រកត្រឹមតែទ្រង់ទ្រាយតូចប៉ុណ្ណោះដោយពួកគាត់ប្រើប្រាស់នូវឧបករណ៏សំរាប់ទឹកសាបមានដូចជា អ៊ួន, លប, អង្រុត, សន្ទូច,បង្កៃ, សំណាញ់ ...។ ចំពោះឧបករណ៏នេសាទទឹកប្រៃ មានដូចជា ស្នរមុខមួយ, ស្នរមុខបី និងមុខប្រាំ,លប,សង្ទូច..។ ប៉ុន្តែនៅក្នុងនេសាទបច្ចុប្បន្ននេះភាគច្រើនមិនត្រឹមត្រូវតាមបច្ចេកទេសនៃច្បាប់ជលផលទេដែលនាំអោយប៉ះពាល់ទៅដល់ធនធានចំរុះទាំងនោះ។

## ១.៤ ទីផ្សារ និងខ្សែសង្វាក់ផលិតផល

### ១.៤.១ ទីផ្សារ និង តម្លៃកសិផល ផលអនុផលព្រៃឈើ និងនេសាទ

- តម្លៃអូស/ធ្យូង : នៅសង្កាត់នេះការផលិតធ្យូងគឺធ្វើឡើងជាទ្រង់ទ្រាយតូចតែប៉ុណ្ណោះ ជាពិសេស នោះលក់នៅក្នុងខេត្តតែប៉ុណ្ណោះ ហើយតំលៃលក់មូលដ្ឋាន ១៣០០-១៤០០រៀល/គីឡូក្រាម ចំពោះការនាំចេញពុំមាននាំចេញទេ។
- ចំពោះតម្លៃស្រូវនៅក្នុងសង្កាត់វិញគឺភាគច្រើនប្រជាពលរដ្ឋពុំមានការលក់ចេញទេ ដោយពួកគាត់ធ្វើសំរាប់តែ ផ្គត់ផ្គង់នៅក្នុងគ្រួសារតែប៉ុណ្ណោះ បើទោះជាមានការលក់ដូរក្នុងរូបភាពតិចតួចបំផុត។

- តម្លៃត្រីទឹកសាប : ត្រីរ៉ស់ពី ១៤000-១៨000រៀល/គក្រ, ត្រីផ្ទក់ពី ១៥000-១៧000 រៀល/គ.ក្រ, ត្រីអណ្តែងពី ១៥000-១៦000រៀល/គ.ក្រ, ត្រីក្រាញ់ពី ១0000-១២000រៀល/គ.ក្រ. អន្ទង់ពី ១៥000-១៨000 រៀល/គ.ក្រ...។

- តម្លៃត្រីទឹកប្រៃ : ត្រីស្តង់សពី ២៨000-៣0000 រៀល/គ.ក្រ. ត្រីស្តង់ក្រហមពី ២៥000-២៧000 រៀល/គ.ក្រ. ត្រីបបែលពី ១២000-១៥000 រៀល/គ.ក្រ. ត្រីឆ្លាមពី ១២000-១៨000 រៀល/គ.ក្រ. ត្រីខ្យកពី ១0000-១២000 រៀល/គ.ក្រ. ត្រីសំប៉ាន់ពី ១២000-១៦000 រៀល/គ.ក្រ. ត្រីកាម៉ុងពី ៤000-៥000 រៀល/គ.ក្រ. ចំពោះបង្គាពី ១២000-២0000 រៀល/គ.ក្រ. ក្តាមពី ២៥000-៣៥000 រៀល/គ.ក្រ។

### ១.៤.២ ខ្សែសង្វាក់ និងចរាចរផលិតផល

- ចំពោះចរាចរណ៍នេសាទនៅក្នុងមូលដ្ឋានរួចហើយក៏បានប្រមូលលក់-ទិញដូចខាងក្រោម:

១. ឈ្មួញប្រមូលទិញពីអ្នកនេសាទមកស្តុកទុកវីក្លាស្សេទុក( ទៅតាមប្រភេទផលិតផលនិងតម្លៃទៅតាមប្រភេទផលិតផលផងដែរ) ។

២ ឈ្មួញប្រមូលទិញត្រីពីស្តង់ វីរានត្រីរួចដឹកយកទៅលក់នៅប្រទេសថៃ,ភ្នំពេញនិងតាមបណ្តាខេត្តដ៏ទៃ ទៀត។

### ១.៤.៣ ឱកាស និងឧបសគ្គ

សង្កាត់ស្ទឹងវែងមានព្រៃលិចទឹក ដែលផ្តល់ផលប្រយោជន៍ជាច្រើនយ៉ាងសំរាប់ប្រជាពលរដ្ឋរស់នៅទីនោះវាមិនត្រឹមផ្តល់ជំរកសំរាប់ពពួកសត្វស្លាបនោះទេ វាក៏ជាជំរកពពួកមច្ឆាជាតិ ត្រី ,បង្គា, ក្តាម... ជាពិសេសវាជាជំរកសំខាន់សំរាប់ត្រីពងកូន ។ចំពោះធនធានជលផលទាំងនេះវាជាប្រភេទធនធានដែលសំបូរបែបហើយថែមទាំងមានតំលៃទៀតផង។ ដោយឡែក បច្ចុប្បន្នដោយមានការប្រើប្រាស់ធនធាននេះច្រើនហើយម្យ៉ាងទៀតមានការកាប់រុករានទន្ទ្រានយកដីជាកម្មសិទ្ធិធ្វើអាជីវកម្ម ផ្សេងៗធ្វើជាអុសធ្យូងសំរាប់ដុត ជាពិសេសការប្រើឧបករណ៍ខុសច្បាប់ដែលធ្វើអោយមានការប៉ះពាល់ដល់ព្រៃលិចទឹក និង មច្ឆាជាតិ ។ ដោយមានកត្តាជាច្រើនខាងលើទើបធ្វើអោយមានថយចុះ។
ដូច្នេះទើបបង្កើតជាសហគមន៍ដើម្បីធ្វើការអភិរក្ស និងទប់ស្កាត់រាល់បទល្មើសខុសច្បាប់ទាំងនោះ ។
ក្នុងសហគមន៍គឺជាឱកាសមួយដើម្បីធ្វើការការពារ និងបង្កើនប្រាក់ចំណូល
ដល់សមាជិកសហគមន៍នៅទីនោះដើម្បីធ្វើការអភិវឌ្ឍន៍លើធនធានផ្សេងៗទៀតដែលមានស្រាប់ ។

# ជំពូក ២
# ការវិភាគពីតំរូវការសំរាប់អនាគត ឧបសគ្គ និងសក្តានុពល

## ២.១ តំបន់សើប

តំបន់ព្រៃលិចទឹក និងវាលស្មៅនៅស្របតាមបណ្តោយព្រែកទួលគគីរ ជាតំបន់ដីសើម និងដីល្បាប់ភក់សំបូរជីវជាតិ ដែលស្ថិត នៅក្នុងសហគមន៍គ្រប់គ្រង និងការពារធនធានធម្មជាតិ និងបរិស្ថាន សង្កាត់ស្ទឹងវែងនៃដែនជំរកសត្វព្រៃពាមក្រសោបដែលជាតំបន់មានជីវចំរុះយ៉ាងពិសេស និងជាជំរកត្រីពងកូនដ៏សំខាន់។ តំបន់នេះត្រូវតែរក្សាជាព្រៃលិចទឹកដដែល ហើយមិនអាចអោយមានការពង្រីកដីកសិកម្មនៅតំបន់នេះបានទេ ហើយសកម្មភាពរបស់មនុស្សឬការតាំងលំនៅដ្ឋានគឺត្រូវក៏រិតកំណត់ជាទីបំផុតមិនអាចអោយមានការអភិវឌ្ឍន៏ក្នុងទ្រង់ទ្រាយធំបានទេ។ ទំរង់នៃការប្រើប្រាស់ដីបច្ចុប្បន្នដែលត្រូវរក្សាទុកដោយឥតមានការប្រែប្រួលរួមមានៈ

- តំបន់ព្រៃកោងកាងដែលដុះនៅតាមមាត់ព្រែកទាំងអស់មាន ៩០០ ហិចតា
- តំបន់សហគមន៏នេសាទ ៦២១ ហិចតា
- តំបន់ដែនជំរកសត្វព្រៃពាមក្រសោបទាំងអស់ ដែលមាននៅបំរើផលប្រយោជន៏សាធារណៈក្នុងគោលដៅការពារបរិស្ថាន និង ធនធានធម្មជាតិ ២៦៩៤ ហិចតា។

## ២.២ ការប្រឈម/ឧបសគ្គ

នៅក្នុងសង្កាត់ស្ទឹងវែងមានបញ្ហាប្រឈមជាច្រើនតែបញ្ហាប្រឈមដែលពាក់ព័ន្ធដល់ធនធានធម្មជាតិ និងបរិស្ថាន ក៏ដូចជាការកាន់កាប់ប្រើប្រាស់ដីមានដូចខាងក្រោម :

- បញ្ហាធនធានជលផលមានការថយចុះដោយសារ
  ១. ការឈូសឆាយ ការកាប់រុករានទន្រ្ទានព្រៃលិចទឹកយកដីធ្វើជាកម្មសិទ្ធិឯកជន
  ២. ការប្រើប្រាស់ឧបករណ៏នេសាទខុសច្បាប់
- បញ្ហាទិន្នផលស្រូវចុះទាបដោយសា :
  ១. ដីស្រែជាប្រភេទដីខ្សាច់ពុំសូវសំបូរជីវជាតិ
  ២. ធ្វើស្រែពឹងផ្អែកទាំងស្រុងលើទឹកភ្លៀង ដោយគ្មានប្រព័ន្ធធារាសាស្ត្រសំរាប់ប្រើប្រាស់
  ៣. ការប្រើប្រាស់ពូជស្រូវមិនបានត្រឹមត្រូវ

៤. ធ្វើស្រែតាមទំលាប់ ដោយគ្មានលក្ខណៈបច្ចេកទេសការប្រឈមទាំងអស់ខាងលើនេះ និងនាំមកនូវការវិនាសហិចហោចធនធានជលផលទីជំរកមច្ឆាជាតិ និង កំរិតជីវភាពរបស់ប្រជាជនមិនមានភាពប្រសើឡើយបើគ្មានវិធានការទប់ស្កាត់អោយបានសមស្របទាន់ពេលវេលានោះ។

## ២.៣ កំណត់តំរូវការនៃការអភិវឌ្ឍន៍ និងគោលដៅយុទ្ធសាស្ត្រសង្កាត់ស្ទឹងវែង

### ២.៣.១ គោលដៅនៃការអភិវឌ្ឍន៍

ក្រុមប្រឹក្សាសង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទបានធ្វើការកំណត់ចេញនូវគោលដៅនៃការអភិវឌ្ឍន៍ដូចតទៅ :

១. អនុវត្តន៍ឱ្យមានកំណើនសេដ្ឋកិច្ចសំដៅកសាងប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនដោយតភ្ជាប់ផ្លូវពីភូមិមួយទៅភូមិ មួយទៀត ដើម្បីដឹកជញ្ជូននិងធ្វើដំណើររបស់ប្រជាជន។

២. បង្កើនដំណាំស្រូវ និង ដំណាំរួមផ្សំផ្សេងៗទៀតដោយយកចិត្តទុកដាក់ពង្រីកផ្ទៃដីដែលដាំដុះការប្រើប្រាស់គ្រាប់ពូជដែលមានទិន្នផលខ្ពស់ និងការប្រើប្រាស់បច្ចេកទេសទំនើបៗ។

៣. ពង្រីក និងពង្រឹងផលិតកម្មបសុសត្វ និងសេវាកម្មបសុពេទ្យដោយត្រូវកែលំអគុណភាព និង សុខភាពនៃសត្វពាហនៈដោយចាប់ផ្តើមនូវពូជល្អ និងឆាប់ធំ។

៤. ជំរុញកុមារដែលគ្រប់អាយុមកចុះឈ្មោះចូលរៀនគ្រប់គ្នាៗ ដោយមានការផ្តល់អាហារូបករណ៍រវាងឪពុកម្តាយអាណាព្យាបាល និង គ្រូយកចិត្តទុកដដាក់ការពារបរិស្ថានការអភិរក្ស និងការប្រើប្រាស់ធនធានធម្មជាតិជីវៈចំរុះប្រកបដោយនិរន្តភាពសំដៅថែរក្សាគុណភាពបរិស្ថាន និងសុខភាពសាធារណៈក្នុងសង្កាត់។

### ២.៣.២ យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍

ក្រុមប្រឹក្សាសង្កាត់ស្ទឹងវែង បានកំណត់នូវយុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ដូចខាងក្រោម :

១. បន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធ ដោយយកចិត្តទុកដាក់ក្នុងការថែទាំប្រព័ន្ធគមនាគមន៍និងប្រព័ន្ធធានាសាស្ត្រការពារទឹកប្រៃ។

២. លើកស្ទួយវិស័យកសិកម្មដោយផ្តោតទៅលើផលិតកម្ម និងពូជសត្វដែលមានសុខភាពល្អធំធាត់

៣. ធានាការគ្រប់គ្រងប្រកបដោយចីរភាពបរិស្ថាន និងធនធានធម្មជាតិដូចជាព្រៃឈើ ជលផល ដី ទឹក ជីវចំរុះ និងសុខមាលភាពរបស់មនុស្សដោយត្រូវពឹងផ្អែកទាំងស្រុងទាលើមូលដ្ឋានទាំងនេះ។

៤. បង្កើនចំនួនគ្រូទាំងបុរស ស្ត្រីទៅគ្រប់កំរិតសិក្សាដើម្បីលើកកំពស់ផលធៀបរវាងសិស្ស និងគ្រូ។

## ២.៤ តំរូវការសំរាប់អនាគត

### ២.៤.១ ប្រជាសាស្ត្រ

**២.៤.១.១ អត្រាកំណើន**

ស្ថានភាពអត្រាកំណើននៃគ្រួសារ និងចំនួនប្រជាជននៅសង្កាត់ស្ទឹងវែងបើពិនិត្យទៅតាមបណ្តា ឆ្នាំនីមួយៗ កន្លងមកឃើញមានការប្រែប្រួលឡើងចុះដូចខាងក្រោម :

- ឆ្នាំ ២០០៣ ចំនួនគ្រួសារមាន ៤៦៥ គ្រួសារ និងចំនួនប្រជាជនមាន ២៤៣១ នាក់
- ឆ្នាំ ២០០៤ ចំនួនគ្រួសារមាន ៥៦៤ គ្រួសារ និងចំនួនប្រជាជនមាន ២៦៣៤ នាក់
- ឆ្នាំ ២០០៥ ចំនួនគ្រួសារមាន ៥០៥ គ្រួសារ និងចំនួនប្រជាជន ២៤៥៧ នាក់
- ឆ្នាំ ២០០៦ ចំនួនគ្រួសារមាន ៤៩៩ គ្រួសារ និងចំនួនប្រជាជនមាន ២៤៥៥ នាក់
- ឆ្នាំ ២០០៧ ចំនួនគ្រួសារមាន ៥៥២ គ្រួសារ និងចំនួនប្រជាជនមាន ២៦៤៦ នាក់
- ឆ្នាំ ២០០៨ ចំនួនគ្រួសារមាន ៥៨៤ គ្រួសារ និងចំនួនប្រជាជនមាន ២៧១៧ នាក់។

ការប្រែប្រួលនេះបណ្តាលមកពីប្រជាជនមានការយល់ដឹងពីកម្មវិធីពន្យារកំណើតផង និង ពីកត្តាសេដ្ឋកិច្ចផង ដែលជំរុញអោយប្រជាជនត្រូវធ្វើចំណាកស្រុក ឬចំណូលស្រុកដើម្បីប្រកបមុខរបរផ្សេងៗរបស់ពួកគេ បានកំរៃយកមក ចិញ្ចឹមជីវិត។ ប៉ុន្តែបើពិនិត្យទៅលើចំនួនកុមារឃើញមានការកើនឡើងនូវកង្វះខាតទីកន្លែងសិក្សា។ ដីនៅក្នុងសង្កាត់ទាំង មូលមានទំហំធំក្នុងនោះមាន ½ ជាដីដែនជំរកសត្វព្រៃពាមក្រសោបកត្តានេះហើយដែលធ្វើអោយសង្កាត់មានការខ្វះខាតដីធ្លី ពីមួយឆ្នាំទៅមួយឆ្នាំប្រជាជនមានការថយចុះតិចតួច រីឯកំណើនមានការកើនឡើងចំនួនច្រើនកត្តានេះធ្វើអោយយើងត្រូវការកត់សំគាល់ទៅលើសក្តានុពលមួយចំនួនដូចជា លទ្ធផលនៃការពង្រីកអាគារសិក្សាការបង្កើនមុខរបរការបង្កើននូវទិន្នផលកសិកម្ម ការអភិរក្សនូវធនធានធម្មជាតិ និង ការកំណត់នូវការប្រើប្រាស់ធនធានអោយបានសមស្របទើបអាចធានាបាននូវអត្រាកំណើន។

**តារាង ការគណនាអត្រាកំណើនមធ្យម**

| ចំនួនគ្រួសារ-ប្រជាជន | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | អត្រាកំណើនមធ្យម | កំណើន/ឆ្នាំ |
|---|---|---|---|---|---|---|---|---|
| **ចំនួនគ្រួសារសរុប** | ៤៦៥ គ្រួសារ | ៥៦៤ គ្រួសារ | ៥០៥ គ្រួសារ | ៤៩៩ គ្រួសារ | ៥៥២ គ្រួសារ | ៥៨៤ គ្រួសារ | - | - |
| **អត្រាកំណើនគ្រួសារ** | - | ១៧,៤១% | -៧,៥០% | -១,១៨% | ១០,៦២% | ៥,៧៩% | ៥,០២% | ២៥ គ្រួសារ |

| ចំនួនប្រជាជនសរុប | ២៨៣១ នាក់ | ២៦៣៤ នាក់ | ២៤៥៧ នាក់ | ២៤៥៥ នាក់ | ២៦៩៦ នាក់ | ២៧១៧ នាក់ | - | - |
|---|---|---|---|---|---|---|---|---|
| អត្រាកំណើនសរុប | | ៨,៣៥% | -៦,៧១% | -0,0៨% | ៧,៧៨% | ២,៦៨% | ២,៤0% | ៦៥ នាក់ |

## ស្ថិតិប្រជាជនផ្លាស់ប្តូរលំនៅដ្ឋាន

| បរិយាយ | ២00៦ | | | ២00៧ | | | ២00៨ | | |
|---|---|---|---|---|---|---|---|---|---|
| | ចំនួនគ្រួសារ | ចំនួនមនុស្ស | | ចំនួនគ្រួសារ | ចំនួនមនុស្ស | | ចំនួនគ្រួសារ | ចំនួនមនុស្ស | |
| | | សរុប | ស្រី | | សរុប | សរុប | | សរុប | សរុប |
| ប្រជាជនចំណូលស្រុក | ១៥ គ្រួសារ | ៨២នាក់ | ៤១នាក់ | ១៦គ្រួសារ | ៤៥នាក់ | ២៤នាក់ | ២២គ្រួសារ | ៨២នាក់ | ៤៣នាក់ |
| ប្រជាជនចំណាកស្រុក | ៣២គ្រួសារ | ១១0នាក់ | ៦១នាក់ | ២គ្រួសារ | ៩នាក់ | ៤នាក់ | ១គ្រួសារ | ៥នាក់ | ៣នាក់ |
| ប្រជាជនចូលមកស្នាក់នៅបណ្តោះអាសន្ន | 0គ្រួសារ | 0នាក់ | 0នាក់ | ៤១គ្រួសារ | ១១៤នាក់ | ៥៤នាក់ | ៣គ្រួសារ | ១0នាក់ | ៥នាក់ |

### ២.៤.១.២ ការធ្វើចំណោលប្រជាសាស្ត្រ

## តារាងការធ្វើចំណោលប្រជាសាស្ត្រ

| ស្ថិតិតាមក្រុមអាយុ | ឆ្នាំ ២0១២ | | ឆ្នាំ២0១៧ | | ឆ្នាំ ២0២២ | |
|---|---|---|---|---|---|---|
| | សរុប (នាក់) | ស្រី(នាក់) | សរុប(នាក់) | ស្រី(នាក់) | សរុប(នាក់) | ស្រី(នាក់) |
| អាយុពី 0-២ ឆ្នាំ | ១៦៣នាក់ | ៨0នាក់ | ១៨១ នាក់ | ៨៩នាក់ | ១៩៩នាក់ | ៩៨នាក់ |
| អាយុពី៣-៥ឆ្នាំ | ១៨៥នាក់ | ៨១នាក់ | ២0៥នាក់ | ៩0នាក់ | ២២៥នាក់ | ៩៩នាក់ |
| អាយុពី៦-១១ឆ្នាំ | ៤៥៤នាក់ | ២៣៧ នាក់ | ៥0៤ នាក់ | ២៦៣ នាក់ | ៥៥៤ នាក់ | ២៨៩ នាក់ |
| អាយុពី១២-១៤ ឆ្នាំ | ២១៥ នាក់ | ១១១ នាក់ | ២៣៨ នាក់ | ១២៣ នាក់ | ២៦១ នាក់ | ១៣៥ នាក់ |
| អាយុពី១៥-១៧ឆ្នាំ | ២៣៦ នាក់ | ១១៤ នាក់ | ២៦២ នាក់ | ១២៦ នាក់ | ២៨៨ នាក់ | ១៣៨ នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| អាយុពី១៨-២៤ឆ្នាំ | ៤៤០នាក់ | ២២៦នាក់ | ៤៨៨ នាក់ | ២៥១ នាក់ | ៥៣៦ នាក់ | ២៧៦ នាក់ |
| អាយុពី២៥-៦០ឆ្នាំ | ១១៩២ នាក់ | ៦០៥ នាក់ | ១៣២២ នាក់ | ៦៧១ នាក់ | ១៤៥២ នាក់ | ៧៣៧ នាក់ |
| អាយុពី៦១ ឆ្នាំឡើង | ៩២ នាក់ | ៤៤នាក់ | ១០២នាក់ | ៤៩នាក់ | ១១២នាក់ | ៥៤នាក់ |
| ចំនួនប្រជាជនសរុប | ២៩៧៧នាក់ | ១៤៩៨នាក់ | ៣៣០២នាក់ | ១៦៦២នាក់ | ៣៦២៧នាក់ | ១៨២៦នាក់ |
| **ចំនួនគ្រួសារសរុប** | **៦៤០ គ្រួសារ** | | **៧១០ គ្រួសារ** | | **៧៨០គ្រួសារ** | |

អត្រាកំណើនប្រជាជននៅក្នុងសង្កាត់ស្ទឹងវែង បើពិនិត្យទៅលើកំណើនរយៈពេល ៥ ឆ្នាំម្តងសំរាប់រយៈពេល ១៤ ឆ្នាំខាងមុខ ឃើញថាអត្រាកំណើនប្រជាជនជាមធ្យម២,៤០%ស្មើនឹង ៦៥ នាក់ក្នុងមួយឆ្នាំ និងមាន ៥,០២% ស្មើនឹង ២៩ គ្រួសារក្នុងមួយឆ្នាំនោះបើពិនិត្យទៅលើបរិមាណផ្ទៃដីដែលអាចប្រើប្រាស់បាននៅមានកំរិត ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏យើងត្រូវចាប់អារម្មណ៏ដល់ការអភិវឌ្ឍន៏ដែរព្រោះអត្រាកំណើនរបស់ប្រជាជននៅក្នុងសង្កាត់ស្ទឹងវែង គឺវាពាក់ព័ន្ធទៅលើការអភិវឌ្ឍន៏ធនធានដែលមាននៅក្នុងសង្កាត ។

### ២.៤.២ តំរូវការដីសំរាប់លំនៅដ្ឋាន

ដីលំនៅដ្ឋានគឺសំដៅដល់ដីដែលប្រើប្រាស់សំរាប់សាងសង់ផ្ទះ និងសំរាប់ដាំដំណាំជាលក្ខណៈគ្រួសារនៅជុំវិញ (លំអិតសូមមើលឧបសម្ព័ន១ ) សំរាប់ឆ្នាំគោល ២០០៨ មានទំហំ ២១៦,៨៨ ហិចតាសំរាប់ប្រជាជនប្រមាណជា៥៧០ [១] គ្រួសារ ដូចនេះទំហំដី សំរាប់មួយគ្រួសារគិតជាមធ្យមគឺមាន ០,៣៨ ហិចតា ទំហំនេះអាចជាទំហំសមស្របសំរាប់ការតាំងលំនៅដ្ឋាន

តំរូវការសំរាប់សង់លំនៅដ្ឋានឆ្នាំ ២០២២ គឺមាន :

- ចំនួនគ្រួសារដែលបច្ចុប្បន្នមិនមានលំនៅដ្ឋាន ១៤ គ្រួសារ X ០,៣៨ ហិចតា = **៥,៣២** ហិចតា
- កំនើនគ្រួសារឆ្នាំ ២០២២ ២១០គ្រួសារ X ០,៣៨ ហិចតា = ៧៩,៨ ហិចតា

សរុប = **៨៥,១២** ហិចតា

### ២.៤.៣ តំរូវការដីកសិកម្ម

តំរូវការដីកសិកម្មគឺរួមមាន ដីសំរាប់ស្រែវស្សា ស្រែជាមួយភូមិ ចំការដំណាំ (លំអិតសូមមើលឧបសម្ពន្ធ័ ១ ) សំរាប់ឆ្នាំគោល២០០៨ មានទំហំ ១៧៣,៨៣ ហ.ត សំរាប់ប្រជាជនសរុប ៥៨៤ គ្រួសារ ដូច្នេះទំហំដីជាមធ្យមសំរាប់មួយគ្រួសារមាន ០,៣០ ហ.ត ។ តែប្រជាជននៅសង្កាត់ស្ទឹងវែងមានមុខរបរសំខាន់ៗមួយចំនួនទៀតដូចជានេសាទចិញ្ចឹមសត្វ ជំនួយ និងសេវាកម្មផ្សេងៗ........បើតាមស្ថិតិគឺមានតែ ១៥,៩៧ % តែប៉ុណ្ណោះ ដែលពឹងផ្អែកជាចំបងលើវិស័យកសិកម្ម គឺ

[១] ចំនួនគ្រួសារសរុប ៥៨៤ គ្រួសារដក និងចំនួនគ្រួសារដែលមិនមានដីសំរាប់សាងសង់លំនៅដ្ឋានចំនួន ១៤ គ្រួសារ

មានប្រមាណ ៩១ គ្រួសារ ដែលអាចមានដីជាមធ្យមទំហំ ១,៩១ [2] ហ.ត ក្នុងមួយគ្រួសារ (ចំនួននេះគឺសរុបទាំងដីស្រែជាមួយភូមិផង និងចំការដំណាំរយះពេល វែង និងរយះពេលខ្លីផង) ដែលជាទំហំសមស្របសំរាប់ប្រជាជន មួយគ្រួសារ ។

**តំរូវការដីកសិកម្មសំរាប់ឆ្នាំ ២០២២ គឺមាន :**

- ចំនួនគ្រួសារដែលបច្ចុប្បន្នមិនទាន់មានដីកសិកម្ម (ដីស្រែ) ១គ្រួសារ X ១,៩១ ហ.ត =១,៩១ ហ.ត
- ចំនួនគ្រួសារមានដីស្រែតិចជាង ១ ហ.ត = ៦ គ្រួសារ X ១,៥ ហ.ត = ៩ ហ.ត
- កំណើនគ្រួសារឆ្នាំ ២០២២ =១២២ គ្រួសារ X ១,៩១ ហ.ត = ២៣៣,០២ ហ.ត

**សរុប = ២៤៣,៩៣ ហ.ត**

ខាងលើនេះជាការវិភាគទៅតាមទំហំដី តែបើយើងវិភាគទៅតាមចំនួនប្រជាជន ផ្ទៃដីដំណាំស្រូវគឺយើងឃើញថា ទិន្នផលស្រូវមាន ២ តោន ក្នុងមួយហ.ត ហើយប្រជាជនម្នាក់ត្រូវការអង្ករ ១៤៣ គ.ក្រ ស្មើនឹង ២២៤ គ.ក្រ ស្រូវក្នុងមួយឆ្នាំ (ទិន្នន័យកសិកម្មក្រុង) តាមទិន្នន័យពី GIS ផ្ទៃដីស្រែជាក់ស្តែងមានប្រមាណ ១៧៣,៨៣ ហ.ត ទទួលបានផលស្រូវ ៣៤៧,៦៦ តោន តំរូវការ ជាក់ស្តែង ៦០៨,៦ តោន ខ្វះពីតំរូវការចំនួន ២៦០ តោន ស្មើនឹងផ្ទៃដីស្រែដែលត្រូវការបន្ថែមចំនួន ១៣០ ហ.ត ។ ឯកំណើនប្រជាជនរហូតដល់ឆ្នាំ ២០២២ គឺមានចំនួន ៣៦២៧ នាក់ ត្រូវការស្រូវ ៨១២,៤៤ តោន ស្មើនឹងផៃដីស្រែ ទំហំ ៤០៦.២២ ហ.ត។ តែបើក្នុងករណី ការបង្ករបង្កើនផលស្រូវត្រូវបានអនុវត្តតាមបច្ចេកទេស ប.វ.ស និងបង្កើនរដូវអោយបាន ២ដងក្នុង១ឆ្នាំនោះ ដីស្រែក្នុងមួយហិកតា អាចទទួលបានទិន្នផលជាមធ្យម ៣.២តោន ដូច្នេះ តំរូវការដីស្រែបន្ថែមសំរាប់រហូតដល់ឆ្នាំ ២០២២ មានចំនួនតឹមតែ **១២៦.៩៤ ហ.ត** តែប៉ុណ្ណោះ ។

### ២.៤.៤ តំរូវការដីសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ

ដោយសង្កាត់ស្ទឹងវែងនៅមានព្រៃលិចទឹក និងវាលស្មៅសំបូរនៅឡើយ ដូច្នេះដីដែលបានកំណត់នៅក្នុងតំបន់សើម និងដីផ្សេងៗទៀតដែលមិនបានកំណត់នៅក្នុងប្រភេទប្រើប្រាស់ដីផ្សេងៗទៀត គឺត្រូវតែទុកអោយនៅជាដីព្រៃ និងវាលស្មៅសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ជាពិសេសគឺបណ្តាព្រៃកធម្មជាតិដែលជាប្រភពដ៏ចំបងសំរាប់ធនធានជលផល ។

### ២.៤.៥ តំរូវការដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធសង្គម

---

[2] តំបន់ដែលមានដីទំហំសមស្របអាច ៥ ហាត

តំបន់ការពារដោយច្បាប់ (អនុក្រិត..),តំបន់ការពារបរិស្ថានដោយធម្មជាតិ (ស្នើសុំអោយទុក ..ទឹកធ្លាក់

តំបន់ដែលប៉ះពាល់សង្គម និងវប្បធមិ (ព្រៃអារក្ស..),តំបន់ដែលមានតំរូវការជាក់ស្តែង (ដីលំនៅដ្ឋាន..ដែលមិនប៉ះពាល់ដីរដ្ឋ)

ជារួមហេដ្ឋារចនាសម្ព័ន្ធសង្គម ក្នុងរូបភាពតូចតាច គឺត្រូវបានបញ្ចូលទៅក្នុងដីលំនៅដ្ឋាន ឬ ដីទីប្រជុំជន ដោយមិនបានញែកចេញដោយឡែកនោះទេ (ក្នុងនោះមានដីកបខ្មោច វត្តអារាម អាស្រម ក៏គិតគូរក្នុងនេះដែរ )ក្នុងនោះ ក៏មានការគិតគូរជារួមលើហេដ្ឋារចនាសម្ព័ន្ធសង្គមដែលមានទ្រង់ទ្រាយធំ ទើបមានការញែកចេញដោយឡែក ។ និយាយ រួមដីសំរាប់គំរូវការហេដ្ឋារចនាសម្ពន្ធ័ ត្រូវបានកំណត់ជារួមជាមួយនិងដីត្រៀមបំរុងសំរាប់ពង្រីកទីប្រជុំជន ។

តាមការប៉ាន់ប្រមាណជាសរុប ដីសំរាប់ហេដ្ឋារចនាសម្ពន្ធ័សង្គមគឺមានតំរូវការបន្ថែមចំនួន ៤,៥ហ.ត ចំពោះ ផ្លូវទំនប់តូចៗគឺមិនមានការគិតជាផ្ទៃដីទេតែមានប្រវែងហើយនិងត្រូវបង្ហាញក្នុងផែនទីដោយឡែក (សូមមើលឧបសម្ពន់ផែន ទីហេដ្ឋារចនាសម្ពន្ធ័) ។

**តារាងផែនការអភិវឌ្ឍន៏ផ្នែកហេដ្ឋារចនាសម្ពន័សង្គម និងសេវាកម្មទូទៅ**

| ហេដ្ឋារចនាសម្ពន័ | ចំនួនក្នុងឆ្នាំនេះ | ចំនួន ១៥ ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| សាលាកមត្តេយសិក្សា | 0 | ០១ | ០១ |
| សាលាបឋមសិក្សា | ០១ | ០១ | 0 |
| អនុវិទ្យាល័យ | 0 | ០១ | ០១ |
| មណ្ឌលសុខភាព | ០១ | 0 | 0 |
| ប៉ុស្តិ៍សុខភាព | 0 | ០១ | ០១ |
| កន្លែងចាក់សំរាម | 0 | ០១ | ០១ |
| ប៉ុស្តិ៍នគរបាល | 0 | ០១ | ០១ |
| អណ្តូងទឹកស្អាត | | | |

ប្រភព: ស្ថានភាពឃុំ ឆ្នាំ ២០០៩

**២.៤.៥.១ តំរូវការសាលារៀន**

ផ្ទៃដីសំរាប់សាងសង់សាលារៀននៅក្នុងសង្កាត់ស្ទឹងវែងនេះ គឺមិនបានកំណត់ផ្ទៃដីអោយបានច្បាស់លាស់ នោះទេ ដោយកន្លងមកដីសាលាត្រូវបានគិតបញ្ចូលទៅក្នុងដីហេដ្ឋារចនាសម្ព័ន្ធ ហើយប្រសិនបើតំរូវអោយមានការសាងសង់ សាលាបឋមសិក្សារួមជាមួយបន្ទប់ថ្នាក់មត្តេយ្យសិក្សាថ្មី គឺអាចធ្វើការសាងសង់នៅក្នុងបរិវេណសាលាចាស់បានលើកលែងតែ មានសាងសង់សាលាអនុវិទ្យាល័យដែលមានដីថ្មីដាច់ឡែក ។

ចំពោះការអភិវឌ្ឍន៍ និងប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសង្គមនៅក្នុងមូលដ្ឋានសង្កាត់ស្ទឹងវែង បច្ចុប្បន្ននៅមានកំរិតដោយបណ្តើរៗកំពុងដំណើរការអភិវឌ្ឍន៍ដូចជានៅចុងឆ្នាំ ២០០៨ និង ដើមឆ្នាំ ២០០៩ បានសាងសង់នូវសាលាបឋមសិក្សាភូមិព្រៃកស្វាយមួយកន្លែង ប៉ុន្តែទោះបីយ៉ាងនេះក៏ដោយក៏ការអភិវឌ្ឍន៍លើវិស័យអប់រំនៅក្នុងសង្កាត់ស្ទឹងវែងនៅពុំទាន់បំពេញបាននូវតំរូវការសិក្សារបស់សិស្សានុសិស្សនៅឡើយដូចជានៅគំរោងផែនការ ១៥ ឆ្នាំខាងមុខតំរូវការលើអគារសិក្សាផ្អែកតាមបរិមាណសិស្សានុសិស្សគឺសាលាមតេយ្យ សាលាបឋមសិក្សា ក៏ដូចជាអនុវិទ្យាល័យបើពិនិត្យទៅតាមការគណនាកំណើនប្រជាជនឃើញថាតំរូវការទាំងនេះអាចផ្តល់ឱកាសអោយសង្កាត់អាចអភិវឌ្ឍន៍ទៅតាមលទ្ធភាពជាបណ្តើរៗ ដែលក្នុងនោះថ្នាក់មត្តេយ្យសិក្សា១បន្ទប់រួមជាមួយថ្នាក់បឋមសិក្សា ៥ បន្ទប់ស្មើនឹងមួយអគារ និងអនុវិទ្យាល័យរួមជាមួយវិទ្យាល័យ ០១ អគារស្មើរ ៦បន្ទប់ ( អគារស្តង់ដាររបស់ រាជរដ្ឋាភិបាល) ស្ថិតនៅភូមិព្រៃកស្វាយ ។

**តារាងកំណើនកុមារ និងតំរូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០១២-២០២២**

| ប្រភេទសាលា | ឆ្នាំ ២០១២ | | | ឆ្នាំ ២០១៧ | | | ឆ្នាំ ២០២២ | | |
|---|---|---|---|---|---|---|---|---|---|
| | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ |
| ថ្នាក់មត្តេយ្យសិក្សា | ១៨៥ | ០ | ២ | ២០៥ | ០ | ០ | ២២៥ | ០ | ២ |
| ថ្នាក់បឋមសិក្សា | ៤៥៤ | ០ | ២ | ៥០៤ | ១ | ៤ | ៥៥៤ | ០ | ២ |
| ថ្នាក់អនុវិទ្យាល័យ | ២១៥ | ១ | ៦ | ២៣៨ | ០ | ០ | ២៦១ | ០ | ០ |
| ថ្នាក់វិទ្យាល័យ | ២៣៦ | ០ | ០ | ២៦២ | ០ | ០ | ២៨៨ | ០ | ០ |

<u>ប្រភព</u>: ស្ថានភាពឃុំ ឆ្នាំ ២០០៩

### ២.៣.៥.២ សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត

#### ក. សេវាកម្មសុខភាព

នៅក្នុងសង្កាត់ស្ទឹងវែងបច្ចុប្បន្ននេះ បញ្ហាសុខភាពរបស់ប្រជាជននៅចោទជាបញ្ហានៅឡើយដោយសង្កាត់មានមណ្ឌលសុខភាពមួយកន្លែងស្ថិតនៅក្នុងភូមិ ៤ សង្កាត់ដងទង់ជាប់ព្រំប្រទល់ភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ដែលមណ្ឌលសុខភាពនេះស្ថិតនៅឆ្ងាយពីភូមិព្រៃកស្វាយប្រហែល ៧ គីឡូម៉ែត្រ បញ្ហានេះនាំអោយប្រជាជននៅភូមិព្រៃកស្វាយខ្វះភាពកក់ក្តៅក្នុងការស្វែង រកសេវាសុខភាព ។

ដើម្បីដោះស្រាយបញ្ហានេះសង្កាត់មានគំរោងកសាងប៉ុស្តិ៍សុខភាព ០១ កន្លែងនៅក្នុងភូមិព្រែកស្វាយ ចាប់តាំងពីពេលនោះរហូតដល់ឆ្នាំ ២០២២ ខាងមុខ ។

**តារាងស្ថិតិកំណើនមណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព**

| បរិយា | ចំនួនក្នុងឆ្នាំនេះ | ចំនួន ១៥ ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| ប៉ុស្តិ៍សុខភាព | 0 | ១ | ១ |
| មណ្ឌលសុខភាព | ០១ | 0 | 0 |

ប្រភព: ស្ថានភាពឃុំ ឆ្នាំ ២០០៩

### ខ. ការផ្គត់ផ្គង់ទឹកស្អាត

ការប្រើប្រាស់ទឹកស្អាត នៅក្នុងសង្កាត់នេះបច្ចុប្បន្ននៅតែជាបញ្ហាចំបងនៅឡើយ ព្រោះថាចំពោះអណ្តូងទឹកស្រះនៅក្នុងសង្កាត់ ដែលបានកសាងសង់ពីមុននោះមួយចំនួនត្រូវបានខូចដូចនេះជាជំហ៊ានដំបូងនៃការអភិវឌ្ឍន ត្រូវស្តារ និងជួសជុលនូវប្រភពទឹកស្អាតទាំងនេះ ហើយផែនការនៅពេលខាងមុខសង្កាត់ត្រូវបន្ថែមនូវគំរោងផែនការក្នុងការជីកអណ្តូងទឹកស្អាតនិងស្នើសុំទៅក្រុមហ៊ុនផ្គត់ផ្គង់ទឹកស្អាតខេត្តអោយតទុយោមេចូលក្នុងសង្កាត់ត្រង់តំបន់ណាដែលមានប្រជាជនរស់នៅច្រើន។

**តារាងស្ថិតិកំណើនប្រភពទឹកស្អាត**

| ប្រភពទឹកស្អាត | ចំនួនក្នុងឆ្នាំនេះ | ចំនួន ១៥ ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| អណ្តូងលូ | ២៣២ អណ្តូង | ៧៧ | ៧៧ |
| អណ្តូងដៃមិនដាក់លូ | ១២ អណ្តូង | 0 | 0 |
| ស្រះទឹក | ១០ ស្រះ | ២ | ២ |
| ប្រព័ន្ធទឹកស្អាត | 0 | 0 | 0 |

### ២.៤.៥.៣ ផ្នែកវប្បធម៌ និងសាសនា

នៅក្នុងការអភិវឌ្ឍន៍ទៅលើផ្នែកវប្បធម៌ ជាកត្តាមួយចូលរួមចំណែកជំរុញអោយមានសន្ទុះដល់ការអប់រំផ្នែកព្រះពុទ្ធសាសនា។ រាល់ទីតាំងនីមួយៗតាមបណ្តាភូមិត្រូវបានផ្តល់លទ្ធភាព និង ជួយសំរួលដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានផ្ទាល់មានឱកាសចូលរួមពង្រីកការផ្សព្វផ្សាយតាមរយៈការអប់រំដល់យុវជន ដែលជាសរសរទ្រូងប្រទេសជាតិអោយជៀសផុតពីអំពើខុសច្បាប់ទាំងឡាយដែលរាជរដ្ឋាភិបាលបានកំណត់។ ជាអាទិភាពសំរាប់សង្កាត់ស្ទឹងវែងសំរាប់ជាកន្លែងគោរពប្រពៃណីសាសនានាថ្ងៃអនាគត ពុំទាន់មានតំរូវការបន្ថែមនៅឡើយ។

**តារាងការអភិវឌ្ឍន៍ និងការអភិរក្សផ្នែកវប្បធម៌ និងសាសនា**

| វប្បធម៌ និងសាសនា | ចំនួនក្នុងឆ្នាំនេះ | ចំនួន ១៥ ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| វត្តអារាម | ០១ | ០១ | ០ |
| ទីកន្លែងសាការបូជា | ០១ (ឯកជន) | ០ | ០ |
| សាលាឆទាន | ០ | ០ | ០ |
| វិហារឥស្លាម | ០១ | ០១ | ០ |
| ផ្សេងៗ | | | |

### ២.៤.៥.៤ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងប្រព័ន្ធធារាសាស្ត្រ

ផ្អែកតាមស្ថានភាពជាក់ស្តែងនៃបរិមាណផ្លូវ ដែលមាននៅក្នុងសង្កាត់ស្ទឹងវែងឃើញថាផ្លូវមួយចំនួនត្រូវធ្វើការជួសជុលដូចជា : ផ្លូវគ្រួសក្រហម ដែលបានសាងសង់ពីមុនមកបច្ចុប្បន្នត្រូវបានទទួលរងនូវការខូចខាតហើយជាបណ្តើរៗដើម្បីងាយស្រួល ធ្វើចរាចរណ៍សង្កាត់និងធ្វើការជួសជុលឡើងវិញចំនួន ០៥ខ្សែមានប្រវែងសរុប ១៥.៧៣៨ ម ជួសជុលទំនប់ការពារទឹកប្រៃចំនួន ២ ខ្សែមានប្រវែងសរុប ៣៧៤៤ម ។

ដើម្បីអោយសក្តិសមទៅនិងពាក្យថាសង្កាត់ក្នុងក្រុងនៅរយៈពេល ១៤ ឆ្នាំខាងមុខទៀត សង្កាត់មានគំរោងដូច ខាងក្រោម:

- លើកគំរោងកសាងផ្លូវក្រាលកៅស៊ូលើផ្លូវគ្រួសក្រហមចាស់ដែលមានស្រាប់ចំនួន ៣ ខ្សែក្នុងនោះផ្លូវអន្តរសង្កាត់ មាន ចំនួន ២ ខ្សែ : ១ខ្សែស្ថិតនៅលើផ្លូវព្រែកស្វាយ ចាប់ពីមុខសាលាក្រុងខេមរភូមិរហូតដល់ផ្លូវកែងសេរីកាមានប្រវែង ១៧១០ម និង ១ខ្សែ ទៀតស្ថិតនៅលើផ្លូវសេរីការចាប់ ពីផ្លូវកែង ៤៨ រហូតដល់ផ្លូវកែងព្រែកស្វាយមានប្រវែង ១១៦៨ ម ហើយផ្លូវនេះបាន បន្លាយបន្តទៅមុខទៀតចាប់ពីផ្លូវកែងព្រែក ស្វាយរហូតដល់មាត់ព្រែកកោះប៉ោ (ហៅឆ្នេរកោះស្នេហ៍) មានប្រវែង ៣៩៣៥ ម ស្ថិតនៅក្នុងសង្កាត់ស្ទឹងវែង ចំណែក ០១ខ្សែទៀតស្ថិតនៅក្នុងសង្កាត់ស្ទឹងវែងតែម្តងគឺចាប់ពីមុខសាលាក្រុងខេមរភូមិន្ទ រហូតដល់ឆ្នាបាត់ជាកន្លែងទីសក្ការៈបូជារបស់ឯកឧត្តម **ទា បាញ់** មានប្រវែង ៦១៨៣ ម ។

- លើកគំរោងកសាងផ្លូវចាក់បេតុង លើផ្លូវគ្រួសក្រហមចាស់ដែលមានស្រាប់ចំនួន ១២ ខ្សែ ក្នុងនោះមានមួយខ្សែជាផ្លូវអន្តរសង្កាត់ គឺរវាងសង្កាត់ស្ទឹងវែង និងសង្កាត់ដងទង់ ចាប់ពីផ្លូវកែងទៅសាលាក្រុងខេមរភូមិន្ទ (ខាងមុខសិប្បកម្មធ្វើធូប) រហូតដល់ស្ពានលូជ្រុងខាងក្រោយសិប្បកម្មធ្វើធូបមានប្រវែង ១៦៥ ម ផ្លូវនេះបានបន្លាយបន្តទៅខាងមុខទៀតរហូតដល់ផ្លូវ កែង ស្ទឹងវែងមានប្រវែង ២៨៤ម នៅសល់ ១១ ខ្សែទៀត គឺស្ថិតនៅក្នុងសង្កាត់ស្ទឹងវែងដែលក្នុងនោះមានចំនួន ៦ខ្សែ ស្ថិតនៅម្តុំផ្ទះ ១០ ខ្នង (ស្ថិតនៅខាងកើតរបងស្តាត)និង ៥ខ្សែទៀតមានទីតាំងដូចនៅ ខាងក្រោម :

ក-ខ្សែទី១:ចាប់ពីកែងវិហារឥស្លាមរហូតដល់ទ្វារទឹកធារាសាស្ត្រជាប់ព្រំប្រទល់ភូមិ២សង្កាត់ដងទង់មានប្រវែង ៣២០ម

ខ-ខ្សែទី ២ :ចាប់ពីផ្លូវកែងខាងមុខសិប្បកម្មធ្វើធូប រហូតដល់ផ្លូវកែងខាងក្រោយមន្ទីរ អភិវឌ្ឍន៍ជនបទ ខេត្ត មានប្រវែង ៨២១ ម

គ- ខ្សែទី ៣ :ចាប់ពីផ្លូវឆ្នាបាត់ ( ខាងកើតមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ) រហូតដល់ផ្លូវកែង ស្ទឹងវែង ( មុខផ្ទះលោកនី ម៉ាលី ) មានប្រវែង ៦៣៧ ម

ឃ-ខ្សែទី៤ :ចាប់ពីផ្លូវកែងខាងក្រោយមន្ទីរអភិវឌ្ឍន៍ខេត្តរហូតផ្លូវសេរីការ មានប្រវែង ១២២០ ម ។

ង- ចាប់ពីផ្លូវកែងឆ្នាបាត់( ខាងមុខ PM ក្រុងខេមរភូមិន្ទ ) រហូតដល់ចុងហាងខាងត្បូង( ហាងស្រី) មានប្រវែង៣២១ ម ។

- លើកគំរោងកសាងផ្លូវក្រាលគ្រួសក្រហមលើផ្លូវដីស មានចំនួន ៥ ខ្សែ ,២ ខ្សែស្ថិតនៅក្នុងភូមិព្រែកស្វាយមានទី តាំងស្ថិតនៅ : ខ្សែទី១ ចាប់ពីខាងមុខផ្ទះរបស់លោក តា ខុង សារី រហូតដល់ខាងមុខផ្ទះរបស់លោក នួន អ៊ុង ( ផ្លូវកាត់មុខផ្ទះលោក កាយ ក្រុង ) មានប្រវែង ១៥៦០ ម , ខ្សែទី ២ ចាប់ពីផ្លូវកែងព្រែកស្វាយ រហូតដល់ជិតមាត់ទឹក មានប្រវែង ៦១៣ ម ។ ចំណែកឯផ្លូវចំនួន៣ខ្សែទៀត គឺស្ថិតនៅក្នុងភូមិស្ទឹងវែង មានទីតាំងដូចតទៅ : ខ្សែទី ១ ចាប់ពីព្រំប្រទល់ភូមិ ៤ សង្កាត់ដងទង់ ( ត្រង់ចំនុចភូមិ តាកែវ ) រហូតផ្លូវកែង សេរីការ ( ជិតដី ឯកឧត្តម អាយ ខន ) កាត់មុខ ផ្ទះលោក ខុង វិឈាន មានប្រវែង ១០១៥ម , ខ្សែទី ២ចាប់ ពីមុខផ្ទះលោក វ៉ុន យ៉ង់ រហូតដល់ផ្លូវកែងរោងចក្រទឹកកក សុខ ហុងមានប្រវែង ៥២៤ ម និង ខ្សែទី៣ ចាប់ពីផ្លូវកែងសេរីការរហូត ដល់ខាងចុងផ្លូវ ( ផ្លូវខាងមុខផ្ទះលោក ថង សំនឹក មានប្រវែង ៧០០ ម ។

នៅសង្កាត់ស្ទឹងវែង ពុំមានប្រភពមេទឹក ដូចជា ទឹកស្ទឹង បឹង ទន្លេ ....(ទឹកសាប ) ដើម្បីធ្វើការជីកប្រឡាយមេ ឬ ប្រឡាយរងសំរាប់ទាក់ទាញយកទឹកមកធ្វើស្រែ គឺពឹងផ្អែកទាំងស្រុងទៅលើទឹកភ្លៀង ។ ប៉ុន្តែនៅក្នុងសង្កាត់សំបូរទៅដោយ ទឹកប្រៃ និងទឹកភ្លៀងនៅរដូវវស្សា ចូលមកដល់ស្រែ និងជន់លិចភូមិ ឬ ផ្លូវថ្នល់ជាដើម ។ ដើម្បីដោះស្រាយបញ្ហាខាងលើនេះនៅក្នុងរយៈពេល ១៤ ឆ្នាំខាងមុខ សង្កាត់មានគំរោងដូចខាងក្រោម :

- លើកគំរោងកសាងទំនប់ការពារទឹកប្រៃស្ថិតនៅក្នុងភូមិព្រែកស្វាយចំនួន ១ខ្សែ មានប្រវែង ១៨០ ម

- លើកគំរោងស្តារប្រឡាយរំដោះទឹកភ្លៀងចំនួន ៣ ខ្សែ ក្នុងនោះ១ខ្សែស្ថិតនៅក្នុងភូមិព្រែកស្វាយនៅជាប់ទំនប់ការពារទឹកប្រៃ ( នៅមុខផ្ទះលោកតា ខុង សារី ) មានប្រវែង ៧៩៤៣ ម ចំណែកឯ២ខ្សែទៀតស្ថិតនៅក្នុងភូមិស្ទឹងវែង ក្នុងចំណោម ២ ខ្សែ នេះ មាន១ខ្សែជាប្រឡាយអន្តរសង្កាត់រវាងសង្កាត់ស្ទឹងវែង និងសង្កាត់ដងទង់ចាប់ពីស្ពានស្វារហូតដល់ស្ពានខាងក្រោយសិប្បកម្មធ្វើធូបមានប្រវែង ៥៤៣ម ហើយប្រឡាយនេះបានបន្លាយបន្តទៅខាងមុខទៀតរហូតដល់ដី របស់**ឯកឧត្តម អាយ ខន** ( ប្រឡាយ រំដោះទឹកខាងក្រោយសាលាក្រុងខេមរភូមិន្ទ ) មានប្រវែង ៥០៤ម និងមួយខ្សែទៀតនៅចាប់ពីទំនប់ការពារទឹកប្រៃ ខេងខូង រហូតដល់ចុងខាងលិចមានប្រវែង ១៣៥០ ម ។

ដើម្បីអោយផ្លូវថ្នល់និងទំនប់ការពារទឹកប្រៃជាប់បានយូរអង្វែងនៅក្នុងរយៈពេល ១៤ ឆ្នាំខាងមុខសង្កាត់មានគំរោង:

- កសាងទ្វារទឹកការពារទឹកប្រៃចំនួន ៤ កន្លែងក្នុងនោះ នៅក្នុងភូមិស្ទឹងវែងមានចំនួន ២ កន្លែង និង នៅក្នុងភូមិ ព្រៃកស្វាយមានចំនួន ២ កន្លែង ។
- ជួសជុលទ្វារទឹកការពារទឹកប្រៃចំនួន ៥ កន្លែង ក្នុងនោះនៅក្នុងភូមិស្ទឹងវែង មានចំនួន ២ កន្លែង និង នៅក្នុងភូមិព្រៃកស្វាយមាន ៣ កន្លែង ។
- ដាក់លូមូលកាត់ផ្លូវចំនួន ១៦ កន្លែងនៅក្នុងភូមិស្ទឹងវែងចំនួន ១៣ កន្លែង និងនៅភូមិព្រៃកស្វាយ ចំនួន ៣ កន្លែង

**តារាង ការអភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត**

| ប្រភេទហេដ្ឋារចនាសម្ពន័ | ប្រវែងផ្លូវឆ្នាំនេះ | ប្រវែងផ្លូវ១៥ឆ្នាំ ខាងមុខ | បំរែបំរួល |
|---|---|---|---|
| ផ្លូវក្រាលកៅស៊ូ | ៤៦៩ ម | ១៣៤៦៥ ម | ១២៩៩៦ ម |
| ផ្លូវបេតុង | ៣២៧ម | ៦៣៤៤ម | ៦០១៧ម |
| ផ្លូវក្រាលគ្រួសក្រហម | ២៩៧៣៩ ម | ៣៤១៥១ ម | ៤៤១២ ម |
| ទំនប់ការពារទឹកប្រៃ | ៤៩១០ម | ៥០៩០ម | ១៨០ម |
| ទ្វារទឹកការពារទឹកប្រៃ | ១២ កន្លែង | ១៦ កន្លែង | ៤កន្លែង |
| លូដាក់កាត់ផ្លូវ | ១៩ កន្លែង | ៣៥ កន្លែង | ១៦ កន្លែង |
| ជួសជុលទ្វារទឹកប្រៃ | 0 | ៥ កន្លែង | ៥ កន្លែង |

# ជំពូក ៣
# ផែនការប្រើប្រាស់ដីអនាគត

## ៣.១ ស្ថានភាពដី (សក្តានុពលដី និងតំរូវការដី)

### ៣.១.១ ស្ថានភាពដីទូទៅ និង សក្តានុពល

សង្កាត់ស្ទឹងវែងជាសង្កាត់មួយដែលមានព្រៃកទឹកប្រៃព័ទ្ធជុំវិញនៅតាមព្រំប្រទល់សំបូរទៅដោយដីទំនាបសំបូរជីជាតិ និងមាន ព្រៃកជាច្រើនកាត់គ្នាខ្វាត់ខ្វែងមានដើមជាច្រើនដុះតាមទំនាបលិចទឹកប្រៃដូចជា ដើមកោងកាង. ដើមកាញ្ចឹប. ដើមសុបុន ដើមចាក .....។ល។ ដើមឈើទាំងនេះមានសារៈសំខាន់ណាស់សំរាប់ដូចជារបាំងការពាររលក ជារបាំងការពារខ្យល់ ជាជំរកមច្ឆាជាតិផ្សេងៗ ដូចជា ត្រី. ក្តាម. ខ្យង. ងៀវ. ពស់. ស្វា. អន្សង ត្រកួត ..និងសត្វស្លាបជាច្រើនប្រភេទទៀតដូចជា សត្វកំប្លុក សត្វលលក. សត្វអំពិល អំពែកជាដើម។ ធនធានទាំងអស់ខាងលើនេះគឺជាសក្តានុពលមួយដែលផ្តល់សារៈប្រយោជន៏ដល់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងមូលដ្ឋានសំរាប់ដកយកផលធនធានទាំងនេះតាមលក្ខណៈបច្ចេក ទេស។

### ៣.១.២ តំរូវការដីតាមប្រភេទ

ដោយយោងតាមការគណនាអំពីចំណោលប្រជាសាស្ត្រនៅក្នុងជំពូក ២ នៃសៀវភៅផែនការប្រើប្រាស់ដីសង្កាត់ស្ទឹងវែងនេះ ឃើញចំនួនប្រជាពលរដ្ឋក៏ដូចជាចំនួនគ្រួសារមានការកើនឡើង។ អត្រាកំណើនប្រជាពលរដ្ឋគឺជាការកើនឡើងនូវតំរូវការនៃការប្រើប្រាស់ទៅលើធនធានគ្រប់ប្រភេទដូច្នេះដើម្បីធានាអោយមាននិរន្តរភាពក្នុងរយៈពេល ១៥ ឆ្នាំ ខាងមុខសង្កាត់មានគំរោងផែនការដូច ខាងក្រោម :

- ពង្រីកដីសំរាប់សាងសង់លំនៅដ្ឋាន ៨៥.១២ហត នៅអមសងខាងផ្លូវដែលមានស្រាប់ដូចជាតាមផ្លូវព្រែកស្វាយ ផ្លូវស្នាបាត់ ផ្លូវសេរីការ និងតាមផ្លូវមួយចំនួនទៀត។ ចំពោះដីសំរាប់សាងសង់លំនៅដ្ឋាននេះគឺយើងបានជ្រើសរើសយកតាមភាពសម ស្របរបស់ដីមានន័យថាដីដែលពុំសំបូរជីជាតិ។
- ដីសំរាប់បញ្ចុះសពមានចំនួន ០២ កន្លែង ហើយបានចែកចេញជាពីរសាសនា គឺព្រះពុទ្ធសាសនា និងឥស្លាមសាសនាសំរាប់ទីបញ្ចុះសពពុទ្ធសាសនិកគឺបានរៀបចំជាឈាបនដ្ឋានរួចហើយ (នៅក្នុងវត្តព្រែកស្វាយ)ចំណែកឯទីបញ្ចុះសពសាសនិកឥស្លាមដែលមានរួចហើយនោះ គឺមិនត្រូវបានពង្រីកឡើយហើយត្រូវបញ្ចុះសពតាមទំនៀមទំលាប់ប្រពៃណីរបស់ពួកគេដោយមិនត្រូវការកែលំអទីបញ្ចុះសពអោយទៅជាឈាបនដ្ឋានក៏ទេដែរ។
- នៅក្នុងការពង្រីកដីវាលស្រែរបស់សង្កាត់ស្ទឹងវែងគឺជាការចាប់អារម្មណ៏ទៅលើដីវាលស្រែដែលបានបោះបង់ចោលក្លាយទៅជាវាលស្មៅ និងដីទំនាប ដីទៃទៀតដែលអាចធ្វើស្រែបានមានចំនួន ............ហត។ ដីខាងលើនេះមិនអាចធ្វើស្រែបានទេបើគ្មានទំនប់ទឹកប្រៃ និងប្រឡាយរំដោះទឹកភ្លៀងចេញពីដីស្រែ។ ដើម្បីបានធ្វើ ស្រែបានសង្កាត់មាន គំរោងសាងសង់ទំនាប់ការពារទឹកប្រៃចំនួន ១ខ្សែ ស្មើនឹង ១៨០ ម ទ្វារទឹកប្រៃ ចំនួន ៤ ខ្សែ និងស្ពារប្រលាយរំដោះទឹកភ្លៀងចំនួន ៣ ខ្សែ ស្មើនឹង ៣៦៧៣ ម។
- ដីចំការដំណាំរយៈពេលខ្លី គឺត្រូវបានបញ្ចូលនៅក្នុងដីសំរាប់សាងសង់លំនៅដ្ឋានរួចហើយ។
- ដីចំការដំណាំឈើហូបផ្លែមានចំនួន ០១ កន្លែង។ ដីដែលអាចដាំដំណាំឈើហូបផ្លែបានលុះត្រាតែដីនោះជាប្រភេទដីក្រហមមានជីជាតិស្ថិតនៅតំបន់ខ្ពង់រាប។ បើតាមការពិនិត្យជាក់ស្តែងដីក្រហមមានជីជាតិស្ថិតនៅខ្ពង់រាបមានចំនួន ០១ កន្លែងគត់ មានផ្ទៃដីប្រមាណជា ៣៤៧ ហត នៅភាគខាងជើងនៃភូមិសាស្ត្ររបស់សង្កាត់ស្ទឹងវែង ក្រៅពីតំបន់ខ្ពង់រាបខាងលើគឺជាតំបន់វាលទំនាបជាប្រភេទដីខ្សាច់ខ្សោះជីជាតិមិនអាចដាំដំណាំឈើហូបផ្លែបានទេ។ ដូចនេះក្នុងរយៈពេល ១៥ ឆ្នាំខាងមុខសង្កាត់ មិនមានគំរោងពង្រីកដីសំរាប់ដាំដំណាំ ឈើហូបផ្លែនោះទេ។
- ដីព្រៃលិចទឹកគឺជាកត្តាសំខាន់សំរាប់ការពារថែរក្សាអភិរក្ស និង អភិវឌ្ឍទៅលើធនធានធម្មជាតិ។ កន្លងមកដោយសារការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកំរិតរួមផ្សំ និង កំរិតជីវភាពផងនោះប្រជាពលរដ្ឋបានកាប់បំផ្លាញព្រៃលិចទឹកជាច្រើន ដូចជាព្រៃកោងកាង ដើមឈើសុបុន ។ល។ ដូច្នេះដើម្បីអោយវាលលិចទឹក ខាងលើក្លាយទៅជាព្រៃលិចទឹកវិញនោះនៅក្នុងរយៈពេល ១៥ ឆ្នាំ ខាងមុខសង្កាត់មានគំរោងដាំដើមកោងកាងឡើងវិញ។

- ដើម្បីធានាបាននូវនិរន្តរភាពរវាងមនុស្ស និងភាវរស់ដែលរស់នៅក្នុងទឹក សង្កាត់មានគំរោងបង្កើតសហគមន៍នេសាទមួយដែលស្ថិតនៅក្នុងទាំងពីរគឺភូមិស្ទឹងវែង និងភូមិព្រែកស្វាយនៃសង្កាត់ស្ទឹងវែង សំរាប់ធានានូវការប្រើប្រាស់ឧបករណ៍នេសាទអោយស្របតាមច្បាប់កំណត់ ។

**តំរូវការនៃការប្រើប្រាស់ដីអនាគត**

| ការប្រើប្រាស់ដី | ក្រឡាផ្ទៃឆ្នាំនេះ (ហត) | ក្រឡាផ្ទៃ ១៥ ឆ្នាំ (ហត) | បំរែបំរួល (ហត) |
|---|---|---|---|
| ដីលំនៅដ្ឋានទីប្រជុំជន | ១១២ | ១៩៧ហត | ៨៥ហត |
| លំនៅដ្ឋានភូមិ | ១០៤ | 0 | 0 |
| ដីវាលស្រែ | ១៧៣ ហត | ៤១៦ហត | ២៤៣ហត |
| ដីទំនប់ការពារទឹកប្រៃ | ៤៩១០ម | ៥០៩០ម | ១៨០ម |
| ស្ពានប្រឡាយរំដោះទឹកភ្លៀង | 0 | ៣៥៩៣ | ៣៥៩៣ |
| ដីចំការដំណាំឈើហូបផ្លែ | ៣៤៧ | 0 | 0 |
| ដីព្រៃជុះតាមមាត់ទឹក | ១២ | 0 | 0 |
| ដីវាលស្មៅ | ៨៥៧ | 0 | 0 |
| ដីផ្ទៃទឹក សមុទ្រ | ៤៧៦ហត | 0 | 0 |
| ដីសហគមន៍នេសាទ | 0 | ៦២១ | ៦២១ |

| | | | |
|---|---|---|---|
| ដីសំរាប់បញ្ចុះសព | ០.៨៤០១ | ០ | ០ |
| ដីដែនជំរកសត្វព្រៃពាមក្រសោប | ២៦៩៤ | ២៦៩៤ | ០ |

## ៣.២ ការបែងចែកដីតាមតំរូវការប្រើប្រាស់

### ៣.២.១ ការវិភាគអន្តរអំពើ

ការគ្រប់គ្រង និងការបែងចែកសំរាប់ប្រើប្រាស់ដីមានកត្តាដែលត្រូវផ្តល់នូវផលប្រយោជន៍មាននិរន្តរភាព និងកត្តាដែលផ្តល់ នូវផលប៉ះពាល់ទៅលើផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងបរិស្ថានដែលមានក្នុងនោះមានដូចជា :

ការប្រែប្រួលពីដីព្រៃ ឬដីវាលស្មៅទៅជាដីស្រែ សំរាប់បង្កបង្កើនផលនេះជាការពង្រីកទៅលើវិស័យកសិកម្មវាជាកត្តាអំណោយផលដល់ការបង្កើនផលិតផល ក៏ដូចជាសេដ្ឋកិច្ចក្នុងមូលដ្ឋាន។ នៅក្នុងបរិបទនេះការប្រែប្រួលប្រភេទដីប្រសិនបើដីព្រៃ ឬដីវាលស្មៅដែលជាដីស្រែដែលត្រូវបោះបង់ចោលនោះវាជាមោទនៈភាពសំរាប់ការពង្រីកលើការងារធ្វើស្រែ។ តែក្នុងករណីដីព្រៃឬដីវាលស្រែមានការពាក់ព័ន្ធទៅនឹងនាទីព្រៃលិចទឹកនោះ និងធ្វើអោយមានផលប៉ះពាល់ដល់ធនធានធម្មជាតិ និងបាត់បង់នូវប្រាក់ចំណូលរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។

ការលើកទំនប់ការពារទឹកប្រៃរួមនិងការជីកប្រឡាយរំដោះទឹកភ្លៀងចេញ គឺជាការប៉ះពាល់ដល់ធនធានធម្មជាតិនិងមុខរបរនេសាទខ្លះជៀសមិនរួចឡើយ ប៉ុន្តែយើងត្រូវចាប់អារម្មណ៍ទៅលើការជំរុញអោយមានផលដំណាំគ្រប់ប្រភេទនៅក្នុងមូលដ្ឋានដើម្បីបង្កើនប្រាក់ចំណូល និងកំរិតជីវភាពរបស់ប្រជាពលរដ្ឋអោយកាន់តែប្រសើរឡើង។

ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍នៅក្នុងមូលដ្ឋានសង្កាត់ គឺជាការផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើនដល់ប្រជាពលរដ្ឋដែលក្នុងនោះមានដូចជា :

- ការសាងសង់ផ្លូវគឺជាការសំរួលដល់ការធ្វើដំណើរ និងធ្វើចរាចរណ៍គ្រប់ប្រភេទ ហើយនិងចូលរួមក្នុងការកាត់បន្ថយការចំណាយទៅលើការដឹកជញ្ជូននិងចំណេញពេលវេលាក្នុងការធ្វើដំណើរ ការអភិវឌ្ឍន៍នេះថ្វីត្បិតតែមានផលប៉ះពាល់ខ្លះៗ ក៏ដោយប៉ុន្តែវាបានផ្តល់ផលប្រយោជន៍ច្រើនដលប្រជាពលរដ្ឋសំរាប់ប្រើប្រាស់។
- ការសាងសង់ទំនប់ការពារទឹកប្រៃ គឺជាការផ្តល់នូវផលប្រយោជន៍ក្នុងការបង្កើនប្រាក់ចំណូលតាមរយៈការបង្កបង្កើនផល និងដាំដំណាំរួមផ្សំនៅខាងក្នុងទំនប់ ពិសេសជាងនេះទៅទៀតនោះគឺជាផ្លូវគមនាគមន៍សំរាប់ធ្វើចរាចរណ៍គ្រប់ប្រភេទទៅលើខ្នងទំនប់នេះ។ ការសាងសង់ទំនប់ការពារទឹកប្រៃថ្វីត្បិតតែមានប្រយោជន៍ ប៉ុន្តែក៏មានផលប៉ះពាល់តិចតួចជៀសមិនរួចឡើយ។

ការពង្រីកវិស័យអប់រំដោយផ្តោតទៅលើការពង្រីកអាគារសិក្សានិងសាលា គឺជាការចាំបាច់បំផុតសំរាប់ការបង្កើនធនធានមនុស្សនៅក្នុងមូលដ្ឋាន។ បច្ចុប្បន្នទោះបីសង្កាត់មានការខ្វះខាតដីសំរាប់បង្កើតសាលាថ្មីសំរាប់ថ្នាក់បឋម

សិក្សាប៉ុន្តែជាអាទិភាពនៅតាមសាលាចាស់ នៅមានដីដែលអាចសាងសង់អាគារសិក្សាបន្ថែមបាន។ ចំណែកដីសំរាប់សាងសង់ថ្នាក់អនុវិទ្យាល័យ បច្ចុប្បន្នថ្មីត្បិតនៅឆ្ងាយពីទីប្រជុំជនបន្តិចមែន ប៉ុន្តែសង្កាត់បានគ្រោងដីទុកសំរាប់សាងសង់អនុវិទ្យាល័យរួចរាល់ហើយ។ រីឯសាលាមត្តេយ្យដោយមើលឃើញពីការលំបាកសំរាប់កុមារដែលគ្មានលទ្ធភាពទៅសិក្សានៅទីឆ្ងាយ គឺជាអាទិភាពសង្កាត់ត្រូវព្យាយាមរកដំណោះស្រាយអោយខាងតែបាននៅតាមបណ្តាភូមិគោលដៅព្រោះវាមានសារៈសំខាន់និងជាមូលដ្ឋានគ្រឹះនៃការបណ្តុះបណ្តាល និង អប់រំបំពាក់បំប៉នអោយបានយល់ដឹងតាំងពីកុមារភាព។

### ៣.២.២ ផែនទីប្រើប្រាស់ដីពេលអនាគត



**រូបទី ៤ : ផែនទីប្រើប្រាស់ដីអនាគត**

### ៣.២.៣ បរិយាយការប្រើប្រាស់តាមក្បាលដី

ការប្រើប្រាស់ដីនៅក្នុងសង្កាត់ស្ទឹងវែងត្រូវបានបែងចែកទៅតាមប្រភេទនៃការប្រើប្រាស់ដែលមានលក្ខណៈជាសត្យានុម័តដោយអនុលោមទៅតាមតួនាទីដូចតទៅ:

- ការប្រើប្រាស់ដីសំរាប់សាងសង់គឺជាដីដែលផ្តល់នូវសក្តានុពលទៅលើការសាងសង់លំនៅដ្ឋាន និងមានដាំដំណាំរួមផ្សំ។ ដីសំរាប់សាងសង់ត្រូវបានចែកចេញជាពីរប្រភេទគឺជាដីសំរាប់សាងសង់លំនៅដ្ឋានទីប្រជុំជន និង ដីលំនៅដ្ឋានភូមិ។
- ដីលំនៅដ្ឋានទីប្រជុំជនគឺជាដីសំរាប់សាងសង់លំនៅដ្ឋានតាមបែបទំនើប និងជួយលំអសោភ័ណ្ឌភាពនៅទីប្រជុំជនអោយមានលក្ខណៈល្អស្រស់បំព្រងដោយមានដំណាំរួមផ្សំដូចជា ដូង. ស្វាយ.ខ្នុរ...។
- ដីលំនៅដ្ឋានភូមិ គឺជាដីសំរាប់សាងសង់លំនៅដ្ឋាន អាចមានដីស្រែដែលមានលក្ខណៈជាទីសាប សំណាប និងអាចដាំដំណាំរួមផ្សំដូចជាអំពៅ. ននោង. ត្រឡាច.ឳឡឹក.ដូង.ស្វាយ.ពោតជាដើម។

  ការប្រែប្រួលប្រភេទដីពីដីចំការ ឬវាលស្មៅមកជាដីលំនៅសាងសង់តាមរយៈនៃការកើនឡើងនូវចំនួនគ្រួសាររបស់ប្រជាពលរដ្ឋដោយការបែងចែកកេរ្តិ៍ទុកអោយកូន ឬតាមរយៈនៃការទិញដី។ ស្ថានភាពនៃការដុះដាលដីសំរាប់សាងសង់គឺភាគច្រើនរីកតាមបណ្តោយផ្លូវដែលមានស្រាប់។ ការបង្កើតលំនៅដ្ឋានថ្មីតូច ឬធំអាស្រ័យទៅតាមស្ថានភាពដីដែលឪពុកម្តាយចែកអោយឬតាមថវិកាដែលខ្លួនមានសំរាប់ទិញដី។
- ការប្រើប្រាស់ដីសំរាប់ដីស្រែ នៅក្នុងសង្កាត់ស្ទឹងវែងមានតែមួយប្រភេទគត់គឺស្រែវស្សាការធ្វើស្រែនេះគឺពឹងផ្អែកទាំងស្រុងទៅលើទឹកភ្លៀង។ នៅក្នុងសង្កាត់ពុំមានប្រភពមេទឹក ទឹកសាបដូចជា ស្ទឹង ទន្លេ បឹង...............ដើម្បីរៀបចំប្រព័ន្ធប្រឡាយទឹកសំរាប់ធ្វើស្រែប្រាំងបាននោះទេ។

  ការប្រែប្រួលក៏ដូចជាការកើនឡើងនៃប្រភេទដីស្រែនេះ គឺជាការពង្រីកទៅលើវាលស្មៅដែលអាចធ្វើស្រែបានប៉ុន្តែមិនប៉ះពាល់ដល់ព្រៃលិចទឹកដែលជាតំបន់អភិរក្សមច្ឆាជាតិនោះទេនិងដីស្រែចាស់ដែលបានបោះបង់ចោលពីមុនមកនោះត្រូវធ្វើការរៀបចំកែលំអរឡើងវិញដោយធ្វើការកែលំអទៅតាមលក្ខណៈបច្ចេកទេសកសិកម្មដំណាំស្រូវ ដល់ប្រជាពលរដ្ឋផ្តល់ឱកាសដល់ពួកគាត់បានចូលរួមក្នុងការបង្កើនទិន្នផលស្រូវនៅក្នុងមូលដ្ឋានដើម្បីកាត់បន្ថយភាពក្រីក្រ និងបង្កើនកំរិតជីវភាពអោយកាន់តែប្រសើរឡើងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រអោយបាន ២ភាគរយក្នុងរយៈពេល ១ ឆ្នាំ។

- ការប្រើប្រាស់ដីសំរាប់នាទីព្រៃលិចទឹក (ដីសាធារណៈរបស់រដ្ឋ) គឺត្រូវទាមទារមានការថែរក្សាអោយគង់វង្សដូច្នេះសង្កាត់មានគោលបំណងធ្វើការរៀបចំនូវផែនការការពារថែរក្សាអភិរក្ស និង អភិវឌ្ឍន៏ទៅលើធនធានទាំងនេះអោយមានប្រសិទ្ធភាពខ្ពស់ និង ដើម្បីផ្តល់នូវប្រយោជន៏ក្នុងការបង្កើនប្រាក់ចំណូលសំរាប់ប្រជាពលរដ្ឋតាមរយៈការប្រើប្រាស់ប្រកបដោយនិរន្តរភាព។
- នៅក្នុងការប្រែប្រួលពីដីវាលភក់ទៅជាដីដែលមានព្រៃលិចទឹកតាមរយៈនៃការដាំដុះកោងកាងឡើងវិញដីដែលមានសារៈសំខាន់បំផុតសំរាប់បង្កើនទីជំរកពពួកមច្ឆាជាតិគ្រប់ប្រភេទ ដែលជំរុញអោយកំរិតជីវភាពរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានមានការកើនឡើងជាលំដាប់។

ចំពោះប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ ដែនជំរកសត្វព្រៃពាមក្រសោបទាំងអស់សង្កាត់មានគោលបំណងស្នើសុំទៅរាជរដ្ឋាភិបាល ដើម្បីបានកាត់ដីចេញពីផែនទីដែនជំរកសត្វព្រៃពាមក្រសោបដោយហេតុថាប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងតំបន់នោះ គឺពួកគាត់បានរស់នៅជាយូរយាណាស់ មកហើយអ្នកខ្លះរស់នៅតាំងពីមុនឆ្នាំ ១៩៧៩ អ្នកខ្លះរស់នៅពីឆ្នាំ ១៩៧៩ និងអ្នកខ្លះទៀតរស់នៅក្រោយឆ្នាំ ១៩៧៩ ជាបន្តបន្ទាប់រហូតដល់បច្ចុប្បន្ន។

ដោយឡែកប្រជាពលរដ្ឋដែលបានរស់នៅលើដីសាធារណៈរបស់រដ្ឋ(ដីផ្លូវ) បច្ចុប្បន្នអ្នកដែលបានរស់នៅភូមិចាស់មានការលំបាកក្នុងការផ្លាស់ប្តូរ ប៉ុន្តែជាគោលការណ៏សង្កាត់ធ្វើការហាមឃាត់ការសាងសង់ថ្មី។

- ការប្រើប្រាស់ដីសំរាប់សាងសង់ផ្លូវថ្នល់ក៏មានបញ្ហាខ្លះដែរ ប៉ុន្តែអាចដោះស្រាយបានព្រោះថាផ្លូវដែលកើតឡើងគឺជាការផ្តើមចេញពីប្រជាជនផ្ទាល់ដែលជាអ្នកធ្វើអោយកើតមានផ្លូវជាដំបូង ហើយសង្កាត់ក៏លើកគំរោងអភិវឌ្ឍន៏ទៅតាមការស្នើសុំពីសំណាក់ប្រជាពលរដ្ឋ។ បច្ចុប្បន្នការអភិវឌ្ឍន៏ទៅលើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ក្នុងសង្កាត់គឺអនុវត្តន៏ទៅលើផ្លូវចាស់ដែលមានស្រាប់គ្រាន់តែធ្វើការកែសំរួលខ្លះៗប៉ុណ្ណោះដូច្នេះដំណោះស្រាយអាចដោះស្រាយបាន។

**៣.២.៣.១ ដីលំនៅដ្ឋាន (បញ្ញាតិ គោលការណ៏ និងការប្រើប្រាស់ដី)**

សង្កាត់ស្ទឹងវែងជាសង្កាត់មួយដែលមានប្រជាពលរដ្ឋតិច និងមានផ្ទៃដីធំទូលាយការគ្រោងទៅលើចំនួនគ្រួសារដែលគ្មានដីលំនៅដ្ឋានបច្ចុប្បន្នចំនួន ១៤ គ្រួសារ និងអត្រាកំណើនរបស់ប្រជាពលរដ្ឋ ២១០១១ គ្រួសារសំរាប់រយៈពេល ១៤ ឆ្នាំខាងមុខ ក្នុងការគិតគូរទៅលើការកំណត់ផ្ទៃដីលំនៅដ្ឋានក្នុងមួយគ្រួសារ ០.៣៨ ហត នោះសង្កាត់មានលទ្ធភាពបំពេញតំរូវការដី ៨៥ ហត សំរាប់គ្រួសារដែលគ្មានដីលំនៅដ្ឋានបច្ចុប្បន្នចំនួន ១៤ គ្រួសារ និងតាមអត្រាកំណើនប្រជាពលរដ្ឋ១៩៦គ្រួសារហើយត្រូវកំណត់និងធ្វើការអភិវឌ្ឍន៏ទៅតាមតំបន់គោលដៅដូចខាងក្រោមៈ

**ទីតាំងលេខកូដ F១១០០-០១** ការពង្រីកដីលំនៅដ្ឋានសំរាប់លេខកូដ **F១១០០-០១** ត្រូវបានកំណត់យកនៅម្តុំខាងកើតផ្ទះ ១០ ខ្នង ត្រង់ចំនុចផ្លូវកែងព្រែកស្វាយជាមួយផ្លូវសេរីការ (នៅជាប់ផ្លូវសេរីការ និងផ្លូវព្រែកស្វាយ) ស្ថិតនៅក្នុងភូមិព្រែកស្វាយមានទំហំ ២៦ ហត និងត្រូវបានកំណត់លើប្រជាពលរដ្ឋចំនួន ៦៨ គ្រួសារសំរាប់អនុវត្ត

នៅក្នុងរយៈពេល ៥ ឆ្នាំទី ១ (២០០៩-២០១២) តែប៉ុណ្ណោះ។ ការគ្រោងតំបន់នេះជាតំបន់អធិវឌ្ឍន៍ ៥ ឆ្នាំទី ១ ដោយសារទីតាំងនេះនៅជិតកន្លែងដែលក្រុមហ៊ុនអគ្គិសនីបានសិក្សារួចហើយថានឹងរៀបចំបណ្តាញអគ្គិសនីក្នុងពេលឆាប់ៗខាងមុខនេះ។

**ទីតាំងលេខកូដ F១១០០-០២** ដោយឡែកចំពោះការគ្រោងពង្រីកដីលំនៅដ្ឋានសំរាប់លេខកូដ **F១១០០-០២** នៅជាប់សាលារៀន និងវិហារគុយរ៉ែត ស្ថិតនៅក្នុងភូមិស្ទឹងវែងដែលមានទំហំដី ៩៩ ហតបានគ្រោងសំរាប់ប្រជាពលរដ្ឋចំនួន ១៩៩គ្រួសារ ដើម្បីអនុវត្ត ៥ឆ្នាំទី ២ (២០១២-២០១៧) និង ៥ឆ្នាំទី ៣ (២០១៧-២០២២) ការគ្រោងដីលំនៅដ្ឋានសំរាប់ ៥ ឆ្នាំទី ២ និង ៥ឆ្នាំទី ៣ នៅតំបន់នេះ ដោយតំបន់នេះមានផ្លូវសេរីការកំពុងសាងសង់ផ្លូវភូមិពីភូមិ៤មកទល់ផ្លូវសេរីការជាផ្លូវគ្រួសក្រហមមានរួចហើយ ផ្លូវពីភូមិតាកែវមកទល់ផ្លូវសេរីការគ្រោងចាក់គ្រួសក្រហមនៅពេលខាងមុខ និងមានផ្លូវកាត់ខ្វែងខ្វាត់ជាច្រើនទៀត។

ការប្រែប្រួលដីលំនៅដ្ឋានតាមរយៈការរីកនៃគ្រួសាររបស់ប្រជាពលរដ្ឋ ដោយការបែងចែកកេរ្តិ៍ទុកអោយកូន និងការលក់ដោះដូរជាប្រាក់លើដីដែលមានការកាន់កាប់ស្រាប់ប៉ុណ្ណោះ ព្រោះសង្កាត់ពុំមានដីសម្បទានសង្គមកិច្ចសំរាប់ធ្វើការបែងចែកជូនប្រជាពលរដ្ឋ សាងសង់លំនៅដ្ឋានឡើយ។ រីឯស្ថានភាពនៃការរីកដុះដាលសំរាប់ប្រភេទដីលំនៅដ្ឋាននេះ គឺភាគច្រើនរីកតាមបណ្តោយផ្លូវដែលមានស្រាប់មានបណ្តាញអគ្គិសនី ឬនៅជិតនិងបណ្តាញអគ្គិសនី និងមានប្រភពទឹកស្អាតសំរាប់ប្រើប្រាស់ផងដែរ។ ការបង្កើតលំនៅដ្ឋានថ្មីតូច ឬធំទៅស្ថានភាពដីដែលឪពុកម្តាយចែកអោយឬតាមលទ្ធភាពនៃការទិញដូរបាន។

**បញ្ញាតិនៃការប្រើប្រាស់ដីសំរាប់សង់លំនៅដ្ឋានថ្មីគឺ :**

ក្នុងការពង្រីកដីលំនៅដ្ឋាន សង្កាត់មានគោលការណ៍រៀបចំដីលំនៅដ្ឋានដែលបានកំណត់ និងជំរុញអោយមានសណ្តាប់ធ្នាប់សាធារណៈល្អហើយក្នុងនោះត្រូវអនុវត្តដូចខាងក្រោម:

- រាល់ដីលំនៅដ្ឋានដែលរៀបចំថ្មីត្រូវបានកំណត់ទុកចំណីផ្លូវស្របតាមការកំណត់របស់ច្បាប់។
- ចំពោះដីលំនៅដ្ឋានដែលរៀបចំថ្មីនៅតាមមាត់ព្រែកប្រឡាយ អូរ ..នានាត្រូវអនុវត្តដោយទុកចំណីព្រែកប្រឡាយ អូរ......នោះតាមការកំណត់របស់ច្បាប់។
- ការសាងសង់លំនៅដ្ឋានត្រូវអនុវត្តទៅតាមច្បាប់ដែលបានអនុញ្ញាត។
- មិនសាងសង់លំនៅដ្ឋាននៅលើដីសាធារណៈរបស់រដ្ឋជាដាច់ខាត
- រាល់ដីលំនៅដ្ឋានដែលកើតថ្មី ត្រូវមានការកំណត់ព្រំប្រទល់ដោយមានការឯកភាពរវាងភាគីពាក់ព័ន្ធ ហើយត្រូវបានបោះបង្គោលថ្មតាមព្រំដីអោយបានច្បាស់លាស់។
- ជំរុញ និងផ្សព្វផ្សាយអោយការចូលរួម បង្កើននូវផលិតផលតាមរយៈការរៀបចំជាសួនដំណាំក្នុងដីលំនៅដ្ឋានដូចជា សួនបន្លែ ដំណាំរយៈពេលខ្លី និងដំណាំរយៈពេលវែងជាដើម ដែលជាកត្តាជួយអោយទីលំនៅដ្ឋានមានសភាពបៃតងជានិច្ច និងមានលទ្ធភាពបង្កើននូវប្រាក់ចំណូលក្នុងគ្រួសារលើសកម្មភាពនេះ។

• ចំពោះប្រជាពលរដ្ឋដែលមានលំនៅដ្ឋានរស់នៅលើដីសាធារណៈរបស់រដ្ឋ (លើផ្លូវមាត់ព្រែក) បច្ចុប្បន្នអ្នកដែលរស់នៅចាស់មានការលំបាកក្នុងការផ្លាស់ប្តូរលំនៅដ្ឋានហើយបណ្តើរៗ សង្កាត់និងព្យាយាមធ្វើការដោះដូរនិងរៀបចំអោយបានត្រឹមត្រូវ ប៉ុន្តែជាគោលការណ៍សង្កាត់ធ្វើការហាមឃាត់ដាច់ខាតការសាងសង់លំនៅដ្ឋានថ្មី ។

**៣.២.៣.២ ដីស្រែវស្សា និងស្រែប្រាំង**

ការប្រើប្រាស់ដីសំរាប់ធ្វើស្រែនៅក្នុងសង្កាត់ស្ទឹងវែង មានតែមួយប្រភេទប៉ុណ្ណោះគឺស្រូវសន្ទូងស្រែវស្សា ។ នៅក្នុងសង្កាត់ស្ទឹងវែងពុំមានប្រភពមេទឹកសាបសំរាប់ជីកប្រឡាយលើទំនប់ធ្វើស្រែប្រាំងនោះទេ ។

- ការប្រែប្រួលក៏ដូចជាការកើនឡើងនៃប្រភេទដីស្រែនេះគឺសង្កាត់បានធ្វើការគិតគូរលើការពង្រីងដីទៅលើដីស្រែចាស់ដែលបានបោះបង់ចោលពីមុនមកនោះត្រូវបានធ្វើការរៀបចំកែលំអរឡើងវិញដោយអនុលោមទៅ តាមលក្ខណៈបច្ចេកទេសកសិកម្មដំណាំស្រូវដល់ប្រជាពលរដ្ឋ ដើម្បីផ្តល់ឱកាសដល់ពួកគាត់ចូលរួមក្នុងការបង្កើននូវទិន្នផលនៅក្នុងមូលដ្ឋាន ។

**គោលការណ៍នៃការប្រើប្រាស់ដីកសិកម្ម**

នៅក្នុងកិច្ចអភិវឌ្ឍន៍សំរាប់ពេលអនាគត សង្កាត់មានគោលការណ៍ក្នុងការរៀបចំនូវការបង្កើនផលិតកម្មដំណាំស្រូវដែលក្នុងនោះត្រូវអនុវត្តនូវយុទ្ធសាស្ត្រមួយចំនួនដែលអាចជួយដល់ការបង្កើនផលិតភាពកសិកម្មគឺៈ

- ជួសជុលទំនប់ និងទ្វារទឹកការពារទឹកប្រៃអោយបានល្អដើម្បីកុំអោយទឹកប្រៃហូរចូលស្រែ
- លើកកំពស់ការប្រើប្រាស់ជីធម្មជាតិ ជីកំប៉ុស្តិ៍
- កាត់បន្ថយការប្រើប្រាស់ជីគីមី
- កាត់បន្ថយការប្រើប្រាស់ថ្នាំពុលជំរុញការអនុវត្តកម្មវិធីIPM
- រៀបចំប្រពលវប្បកម្មដំណាំស្រូវ(បវស)
- ស្តារប្រឡាយរំដោះទឹកភ្លៀងដើម្បីកុំអោយជន់លិចស្រូវនៅរដូវវស្សា
- បង្កើនការដាំដុះដំណាំរយៈពេលខ្លីនៅលើដីស្រែដែលបានច្រូតកាត់រួច ដើម្បីអោយការប្រើប្រាស់ដីប្រកបដោយប្រសិទ្ធិភាពនិងមានតម្លាភាព ។

**ការពង្រីកដីសំរាប់ធ្វើស្រែត្រូវបានហាមឃាតដូចខាងក្រោមៈ**

- ហាមដាច់ខាតការពង្រីកដីលើដីសាធារណៈរបស់រដ្ឋ
- ហាមឃាត់ដាច់ខាតការវាតដីស្រែចូលអូរ. ព្រែកឬប្រឡាយ

- ហាមឃាត់ដាច់ខាតការកាប់រានចូលដីនាទីព្រៃលិចទឹកដើម្បីធ្វើស្រែ
- រាល់ដីស្រែត្រូវមានភ្លឺសំរាប់សំគាល់ព្រំប្រទល់ច្បាស់លាស់

### ៣.២.៣.៣ ការប្រើប្រាស់ទឹក និងប្រព័ន្ធស្រោចស្រព

ការប្រើប្រាស់ដីផ្ទៃទឹកនានា គឺជាកត្តាចំបងសំរាប់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ដើម្បីបំរើផលប្រយោជន៍អោយវិស័យកសិកម្ម និងការប្រើប្រាស់ទូទៅ ប៉ុន្តែជាអកុសលនៅក្នុងសង្កាត់ស្ទឹងវែងពុំមានប្រភពមេទឹកសាបដូចជាទន្លេ ស្ទឹង បឹង សំរាប់ទាញយកទឹកមកប្រើប្រាស់លើវិស័យកសិកម្មបាននោះទេមាន អូរ ព្រែកដែរ តែអូរ ព្រែកទាំងនោះបំរើអោយតែទឹកប្រៃប៉ុណ្ណោះ ( ទឹកសមុទ្រ )

**ប្រព័ន្ធស្រោចស្រព**

ការប្រែប្រួលពីដីប្រឡាយរំដោះទឹកភ្លៀងចាស់មកជាប្រឡាយថ្មីអាចមានបញ្ហាចោទព្រោះថាមានការលំបាកសំរាប់ការដោះស្រាយនូវបញ្ហាប្រឈមមួយចំនួន និងកើតឡើងនៅពេលប្រឡាយចាប់ផ្តើមដំណើរការស្តារដូចជាការរំលោភយកដីចំណីប្រឡាយធ្វើជាកម្មសិទ្ធ ឬមានបញ្ហាផ្សេងៗទៀត បញ្ហានេះកើតឡើងដោយសារប្រជាពលរដ្ឋមិនទាន់យល់ច្បាស់ពីសារៈប្រយោជន៍ក្នុងការប្រើប្រាស់ប្រឡាយ ដូច្នេះបញ្ហានៃការប៉ះពាល់ដីចំណីប្រឡាយធ្វើអោយសង្កាត់ប្រឈមមុខក្នុងការដោះស្រាយ ។

**ទីតាំងដីស្តារប្រឡាយលេខ FDN ៥៧-០១**

ក្នុងការស្តារប្រឡាយរំដោះទឹកភ្លៀងចាស់មកជាប្រឡាយថ្មីមានលេខកូដ FDN ៥៧-០១ មានប្រវែង ៩០៤ ម ស្ថិតនៅក្នុងភូមិស្ទឹងវែងចាប់ពីលូឆ្លងកាត់ផ្លូវជីឯកឧត្តម អាយ ខន រហូតដល់ស្ពានថ្មីខាងក្រោយសិប្បកម្មធ្វើធូក ប្រឡាយនេះបានបន្លាយទៅមុខទៀតជាប្រឡាយអន្តរសង្កាត់ គឺរវាងសង្កាត់ស្ទឹងវែងជាមួយសង្កាត់ដងទង់ចាប់ពីស្ពានថ្មខាងក្រោយសិប្បកម្មធ្វើធូករហូតដល់ស្ពានស្វា (ស្ពានថ្ម) មានប្រវែង ៥៤៣ម។ ប្រឡាយមួយខ្សែនេះអាចដំណើរការអនុវត្តនៅក្នុងដំណាក់កាល ៥ ឆ្នាំទី ៣ (២០១៧-២០២២) ។

**ទីតាំងដីស្តាប្រឡាយលេខកូដ FDN ៥៧-០២**

ការស្តារប្រឡាយមានលេខកូដ FDN ៥៧-០២ ត្រង់ចំនុចមុខផ្ទះលោកតា ខុង សារី មានប្រវែង ៧៩៥ ម ជាអាទិភាពសង្កាត់បានលើគំរោងសំរាប់ស្តារប្រឡាយនេះមុនគេបង្អស់ គឺចាប់ធ្វើនៅក្នុងរយៈពេល ៥ ឆ្នាំទី ១ (២០០៩-២០១២) ។

**ទីតាំងដីស្តារប្រឡាយលេខកូដ F៥៧-០៣**

ប្រឡាយចាស់ត្រូវស្តារមកជាប្រឡាយថ្មីមានលេខកូដ F៥៧-០៣ ស្ថិតនៅភូមិស្ទឹងវែងចាប់ពីទំនប់ការពារទឹកប្រៃខេងខូងរហូតដល់ចុងខាងលិចមានប្រវែង ១៣៥០ម ត្រូវបានចាត់ចូលទៅក្នុងគំរោងអាទិភាពទី ២ (២០១២-២០១៧) ខាងមុខ ។

**បញ្ញាតិ និងគោលការណ៍នៃការស្តារប្រឡាយ**

- នៅក្នុងលក្ខខណ្ឌនៃការស្តារប្រឡាយត្រូវមានការកំណត់អោយបានច្បាស់លាស់ទៅលើការដោះស្រាយបញ្ហាទើបដំណើរការប្រព្រឹត្តទៅទទួលបានជោគជ័យ ។
- រៀបចំគណៈកម្មការចុះដោះស្រាយអនុវត្ត និងថែទាំ
- ការស្តារប្រឡាយចាស់ត្រូវអនុវត្តសមស្របទៅតាមទំហំប្រឡាយចាស់ ។
- ត្រូវធ្វើការដោះស្រាយអោយបានរួចរាល់នូវការរំលោភយកដីចំណីប្រឡាយចាស់ និង កែសំរួលទៅតាមស្ថានភាពជាក់ស្តែងសមស្របតាមគោលការណ៍ច្បាប់ ។

### ៣.២.៣.៤ ការសាងសង់លូឆ្លងកាត់ផ្លូវ និងទ្វារទឹកប្រែ

ក្នុងការអភិវឌ្ឍន៍លើហេដ្ឋារចនាសម្ព័ន្ធ សង្កាត់មានការចាប់អារម្មណ៍លើការសាងសង់លូឆ្លងកាត់ផ្លូវ និងទ្វារទឹកការពារទឹកប្រៃថ្មីដែលក្នុងនោះ នឹងត្រូវដំណើរការទៅតាមទីតាំងដូចខាងក្រោម :

- លូឆ្លងកាត់ផ្លូវ គឺជាការចាំបាច់សង្កាត់ធ្វើការកំណត់លើការសាងសង់លូឆ្លងកាត់ផ្លូវចំនួន ១៦ កន្លែងក្នុងនោះ ១៣កន្លែងស្ថិតនៅក្នុងភូមិស្ទឹងវែង ៣ កន្លែងស្ថិតនៅក្នុងភូមិព្រែកស្វាយត្រូវអនុវត្ត ៥ឆ្នាំទី ១ ចំនួន ៥កន្លែង ៥ឆ្នាំទី ២ ចំនួន ៥កន្លែង និង ៦កន្លែងទៀតអនុវត្តទៅ ៥ឆ្នាំទី ៣ ដោយឡែកទ្វារទឹកការពារទឹកប្រៃមានចំនួន ៤កន្លែងក្នុងនោះ ២កន្លែងស្ថិតនៅក្នុងភូមិព្រែកស្វាយដែលត្រូវអនុវត្តនៅ៥ឆ្នាំទី ១ និង ២កន្លែងទៀតស្ថិតនៅក្នុងភូមិស្ទឹងវែងត្រូវអនុវត្ត ៥ ឆ្នាំទី ២ ។

**បញ្ញាតិ និងគោលការណ៍នៃការសាងសង់លូឆ្លងកាត់ផ្លូវ និងទ្វារទឹកការពារទឹកប្រៃ**

- ការសាងសង់លូឆ្លងកាត់ផ្លូវ និងទ្វារទឹកការពារទឹកប្រៃត្រូវពិនិត្យទៅតាមស្ថានភាពជាក់ស្តែងនៃដីត្រូវជ្រើសរើសយកកន្លែងទាបបំផុត ។
- ជ្រើសរើសទីតាំង ដោយអនុលោមទៅតាមស្ថានភាពនៃចរន្តទឹកហូរ ជៀសវាងការជ្រើសយកកន្លែងទីតាំងមិនសមស្របដែលធ្វើអោយចាល់និងបង្វែរចរន្តទឹកហូរ ។

- ការសាងសង់ត្រូវអនុវត្តន៍ទៅតាមបច្ចេកទេសអោយបានត្រឹមត្រូវ ហើយគិតគូរ និងជៀសវាងនូវកត្តាដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន ។

### ៣.២.៣.៥ ការប្រើប្រាស់ផ្លូវថ្នល់

ការប្រើប្រាស់ដីសំរាប់សាងសង់ផ្លូវថ្នល់ក៏មានបញ្ហាខ្លះដែរ ប៉ុន្តែអាចដោះស្រាយបានព្រោះថាផ្លូវដែលកើតឡើងគឺជាការចាប់ផ្តើមពីប្រជាពលរដ្ឋផ្ទាល់ដែលជាអ្នកធ្វើអោយកើតផ្លូវជាដំបូងហើយសង្កាត់ក៏លើកគំរោងអភិវឌ្ឍន៍ទៅតាមការស្នើឡើងពីសំណាក់ប្រជាពលរដ្ឋ ។បច្ចុប្បន្នការអភិវឌ្ឍន៍ទៅលើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ក្នុងសង្កាត់គឺអនុវត្ត តាមទៅផ្លូវ

ចាស់ មានស្រាប់ដូច្នេះដំណោះស្រាយអាចដោះស្រាយបាន។

**ទីតាំងផ្លូវក្រាលកៅស៊ូលើផ្លូវគ្រួសក្រហមដែលមានស្រាប់លេខកូដ FRD-០១, FRD-០២, FRD-០៣ និង FRD-០៤**

ក្នុងការអភិវឌ្ឍទីផ្លូវក្រាលកៅស៊ូនៅក្នុងសង្កាត់ស្ទឹងវែងមានចំនួន ៣ ខ្សែក្នុងនោះផ្លូវអន្តរសង្កាត់មានចំនួន ០២ខ្សែគឺរវាងសង្កាត់ស្ទឹងវែង ជាមួយសង្កាត់ស្មាច់មានជ័យ ១ខ្សែទៀតស្ថិតនៅលើផ្លូវព្រែកស្វាយចាប់ពីមុខសាលាក្រុងខេមរភូមិន្ទរហូតដល់ផ្លូវកែងសេរីការមានប្រវែង ១៧១០មមានលេខកូដ **FRD-០២** ត្រូវអនុវត្តនៅក្នុង៥ឆ្នាំទី ២ និង ១ខ្សែទៀតស្ថិតនៅលើផ្លូវសេរីការចាប់ពីផ្លូវកែងលេខ ៤៨ រហូតដល់ផ្លូវកែងព្រែកស្វាយមានប្រវែង ១១៦៨,៦០ម មានលេខកូដ **FRD-០១** ហើយផ្លូវនេះបានបន្តទៅមុខទៀតចាប់ពីផ្លូវកែងព្រែកស្វាយរហូតដល់មាត់ព្រែកកកោះប៉ោ (ហៅ ឆ្នេរកោះស្នេហ៍) មានប្រវែង ៣.៩៣៥ម មានលេខកូដ **FRD-០៣**ផ្លូវដែលមានលេខកូដ FRD-០១ និង FRD-០៣ ទាំងពីរខ្សែនេះត្រូវចាប់ផ្តើមអភិវឌ្ឍន៍នៅ ៥ ឆ្នាំទី ១ (២០០៩-២០១២) ដោយឡែក ១ ខ្សែទៀតស្ថិតនៅក្នុងសង្កាត់ស្ទឹងវែងតែម្តងគឺចាប់ពីមុខសាលាក្រុងខេមរភូមិរហូតដល់ឆ្នាបាត់ត្រង់កន្លែងទីសក្ការៈបូជារបស់ឯកឧត្តមទាបាញ់មានប្រវែង ៦,១៨៣ ម មានលេខកូដ **FRD-០២**និងត្រូវអភិវឌ្ឍន៍នៅក្នុងរយៈពេល៥ឆ្នាំទី៣(២០១៧-២០២២)។

**ទីតាំងផ្លូវចាក់បេតុងលើផ្លូវគ្រួសក្រហមចាស់ដែលមានស្រាប់លេខកូដ FRD៩-០១ , FRD៩-០២, FRD៩-០៣, FRD៩-០៤, FRD៩-០៥, FRD៩-០៦, FRD៩-០៧, FRD៩-០៨, FRD៩-០៩, FRD៩-១០, FRD៩-១១, FRD៩-១២, FRD៩-១៣ និង FRD៩-១៤**

ការសាងសង់ផ្លូវបេតុងចាប់ពី ២០០៩-២០២២ មានគំរោងសាងសង់ចំនួន ១២ ខ្សែ ក្នុងនោះមាន ១ ខ្សែជាផ្លូវអន្តរសង្កាត់គឺរវាងសង្កាត់ស្ទឹងវែង ជាមួយសង្កាត់ដងទង់ចាប់ពីផ្លូវកែងទៅក្រុងខេមរភូមិ (ខាងមុខសិប្បកម្មធ្វើធូក) រហូតដល់ស្ពាន-ព្រែកខាងក្រោយសិប្បកម្មធ្វើធូកមានប្រវែង ១៦៥ ម មានលេខកូដ **FRD៩-០១៤** ផ្លូវនេះបានបន្លាយបន្តទៅខាងមុខទៀតរហូតដល់ផ្លូវកែងស្ទឹងវែងមានប្រវែង ២៨៤ម មានលេខកូដ **FRD៩-១២** ផ្លូវមានលេខកូដ **FRD៩-០៥** នៅម៉ុំផ្ទះ ១០ ខ្នង (ខាងកើតរបងស្តាត)ផ្លូវលេខកូដ **FRD៩-០៨** ចាប់ពីមុខសិប្បកម្មធ្វើធូករហូតដល់ផ្លូវកែងក្រោយមន្ទីរអភិវឌ្ឍជនបទខេត្តមានប្រវែង ៨២១ ម ផ្លូវមានលេខកូដ **FRD៩-០៩** ចាប់ពីផ្លូវឆ្នាបាត់)ខាងកើតមន្ទីរអភិវឌ្ឍជនបទខេត្តរហូតដល់កែងស្ទឹងវែង (មុខផ្ទះលោក នី ម៉ាលី)មានប្រវែង ៦៣៧ម ផ្លូវមានលេខកូដ **FRD៩-១៤, FRD៩-១២, FRD៩-០៥, FRD៩-០៨** និង **FRD៩-០៩** ត្រូវអភិវឌ្ឍន៍នៅរយៈពេល ៥ឆ្នាំទី ១ (២០០៩-២០១២)ចំពោះផ្លូវមានលេខកូដ **FRD៩-០៣, FRD៩-០៤** នៅម៉ុំផ្ទះ ១០ខ្នង (ខាងកើតជាប់របងស្តាត និង **FRD៩-១០** ជាប់ផ្លូវកែងក្រោយមន្ទីរអភិវឌ្ឍជបបទខេត្តរហូតដល់ផ្លូវសេរីការមានប្រវែង ១២២០ ម ត្រូវអភិវឌ្ឍន៍នៅ ៥ឆ្នាំ ទី ២ (២០១២-២០១៧) ដោយឡែកផ្លូវមានលេខកូដ **FRD៩-០៨** ចាប់ពីមុខសិប្បកម្មធ្វើធូករហូតដល់ផ្លូវកែងក្រោយមន្ទីរអភិវឌ្ឍន៍ជនបទខេត្តមានប្រវែង ៨២១ ម ផ្លូវមាន

លេខកូដ **FRD៩-០៩** ចាប់ពីផ្លូវកែងឆ្នាបាត់ (ខាងកើតជាប់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តរហូតដល់ផ្លូវកែងស្ទឹងវែង (មុខផ្ទះលោក ទីម៉ាលី) មានប្រវែង ៦៣៧ម ផ្លូវមានលេខកូដ **FRD៩-១៤, FRD៩-១២, FRD៩-០៥, FRD៩-០៨ និង FRD៩-០៩** ត្រូវអភិវឌ្ឍន៍នៅរយៈពេល ៥ឆ្នាំទី ១ (២០០៩-២០១២) ចំពោះផ្លូវមានលេខកូដ **FRD៩-០៣ , FRD៩-០៤** នៅម្តុំផ្ទះ ១០ ខ្នង (ខាងកើតរបងស្តាត និង **FRD៩-១០** ចាប់ពីផ្លូវកែងខាងក្រោយមន្ទីរអភិវឌ្ឍន៍ជនបទខេត្តរហូតដល់ផ្លូវសេរីការមានប្រវែង ១២២០ម ត្រូវអភិវឌ្ឍន៍នៅ ៥ឆ្នាំទី ២ (២០១២-២០១៧) ដោយឡែកផ្លូវមានលេខកូដ **FRD៩-០១, FRD៩-០២, FRD៩-០៣** នៅម្តុំផ្ទះ ១០ ខ្នង (ខាងកើតជាប់របងស្តាត) **FRD៩-០៧** ចាប់ពីគល់ស្ពានស្វាររហូតដល់ទ្វារទឹកធារាសាស្ត្រជាប់ព្រំប្រទល់ភូមិ ២ សង្កាត់ដងទង់មានប្រវែង ៥៤១ម, **FRD៩-០១១** ចាប់ពីផ្លូវកែងឆ្នាបាត់ (ខាងមុខ PM ក្រុងខេមរភូមិន្ទ) រហូតដល់ចុងហាងខាងត្បូង (ហាងស្រី) មានប្រវែង ៣២១ម និង **FRD៩-១៣** ចាប់ពីផ្លូវកែងវិហាឥស្លាមរហូតដល់ផ្លូវកែងមកពីសិប្បកម្មធ្វើធូកមានប្រវែង ១៧៨ ម ដែលនឹងត្រូវអភិវឌ្ឍន៍នៅ ៥ឆ្នាំទី ៣ (២០១៧-២០២២)

**ទីតាំងផ្លូវក្រាលគ្រួសក្រហមលេខកូដ FRD៤-0, FRD៤-០២, FRD៤-០៣, FRD៤-០៤ និង FRD៤-០៥**

គំរោងស្ថាបនាផ្លូវក្រាលគ្រួសក្រហមលើផ្លូវដីសម្បទានទីតាំងដូចតទៅ ផ្លូវលេខកូដ **FRD៤-០៣** ចាប់ពីភូមិ ៤ សង្កាត់ដងទង់ (ត្រង់ចំនុចភូមិតាកែវ) រហូតដល់ផ្លូវកែងសេរីការ (ជិតដីឯកឧត្តម អាយ ខន) កាត់មុខផ្ទះលោក ខុង វិឃាន មានប្រវែង ១០១៥ ម និង **FRD៤-០៥** ចាប់ពីផ្លូវកែងសេរីការរហូតដល់ខាងចុងផ្លូវ (ផ្លូវខាងមុខផ្ទះថង សំនឹក) មានប្រវែង ៦៧៨ ម ត្រូវអភិវឌ្ឍន៍នៅ ៥ ឆ្នាំទី ១(២០០៩-២០១២) ចំពោះផ្លូវលេខកូដ **FRD៤-០១** មានប្រវែង ១៥៦0 ម ចាប់ពីពីខាងមុខផ្ទះលោកតា ខុង សារី រហូតដល់មុខផ្ទះលោក នួន អ៊ុង ត្រូវអភិវឌ្ឍន៍នៅក្នុង៥ឆ្នាំ ទី ២ (២០១២-២០១៧) និងផ្លូវមានលេខកូដ **FRD៤-០២** ចាប់ពីផ្លូវកែងព្រែកស្វាយរហូតដល់ជិតមាត់ទឹកមានប្រវែង ៦១៣ ម ផ្លូវលេខកូដ **FRD៤-០៤** ចាប់ពីមុខផ្ទះលោក វ៉ុន យ៉ង រហូតដល់ផ្លូវកែងរោងចក្រទឹកកក សុខ ហុង មានប្រវែង ៥២៤ ម អនុវត្តនៅក្នុងដំណាក់កាល ៥ឆ្នាំទី ៣ (២០១៧-២០២២)

**បញ្ញាតិ និងគោលការណ៍នៃការប្រើប្រាស់ផ្លូវថ្នល់ការសាងសង់ផ្លូវត្រូវបានកំណត់ដូចខាងក្រោម :**

- ផ្លូវកៅស៊ូត្រូវមានទំហំ ៤០ ម (ពីអ័ក្សចិញ្ចើមផ្លូវមានប្រវែង ២០មសងខាង)
- ផ្លូវបេតុង និងផ្លូវគ្រួសក្រហមក្នុងសង្កាត់មានទំហំសរុបពី ១៥-២០ ម (ពីអ័ក្សទៅចិញ្ចើមផ្លូវមានប្រវែងពី ៧,៥-១០ម)
- ការកំណត់លើការប្រើប្រាស់ផ្លូវថ្នល់ត្រូវអនុលោមទៅតាមច្បាប់
- បង្កើតគណកម្មការថែទាំផ្លូវដោយមានការចូលរួមពីប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- ហាមការដឹកជញ្ជូនលើសទំងន់
- ហាមយកគោ ក្របី ជ្រូក.. ចងនៅលើផ្លូវ
- រៀបចំស្លាកសញ្ញាចរាចរណ៍តាមបណ្តោយផ្លូវ

### ៣.២.៣.៦ ការសាងសង់អាគារសិក្សាលើទីតាំងសាលាចាស់ និងថ្មី

កុមារដែលគ្រប់អាយុចូលរៀនមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ធ្វើអោយក្រុមប្រឹក្សាសង្កាត់ស្ទឹងវែងមានការចាប់អារម្មណ៏ដល់ការបង្កើតសាលាឬការពង្រីកបន្ទប់អគារបន្ថែម ដើម្បីតំរូវតាមការកើនឡើងរបស់កុមារ ចាប់ពី ២០០៩-២០២២ សង្កាត់មានគំរោង :

- សាងសង់អគារចំនួន ០២ ខ្នង ស្មើនឹង ១០ បន្ទប់សំរាប់ថ្នាក់មត្តេយ្យសិក្សា និងបឋមសិក្សាស្ថិតនៅភូមិព្រែកស្វាយដែលត្រូវអភិវឌ្ឍន៏ ៥ ឆ្នាំទី ២ (២០១២-២០១៧) ចំនួន ០១ អគារស្មើនឹង ៥ បន្ទប់នឹង ០១ អគារទៀតត្រូវ សាងសង់នៅ ៥ ឆ្នាំទី ៣ មានចំនួន ០៥ បន្ទប់ដែរ។
- សាងសង់សាលាអនុវិទ្យាល័យមួយខ្នងនៅទីតាំងថ្មីចំនួន ០១ អគារស្មើ ៦ បន្ទប់ ស្ថិតនៅភូមិព្រែកស្វាយសំរាប់សិស្សានុសិស្សថ្នាក់អនុវិទ្យាល័យ និងវិទ្យាល័យរៀននៅអគារជាមួយគ្នាតែបន្ទប់ខុសគ្នា។ ការរៀបចំនេះដោយសិស្សដែលត្រូវចូលរៀនថ្នាក់អនុវិទ្យាល័យនៅមានចំនួនតិចដូចគ្នា។ ការសាងសង់សាលាអនុវិទ្យាល័យនេះត្រូវអនុវត្តនៅ ៥ ឆ្នាំទី ១ (២០០៩-២០១២)។
- សំរាប់អគារដែលត្រូវសាងសង់ ប្រសិនបើក្នុងករណីមានការគាំទ្រណាមួយដែលមានលទ្ធភាពក្នុងការសាងសង់អគារ១ ខ្នង ២ ជាន់ ១០-១២បន្ទប់នោះកាន់តែប្រសើរ ហើយសង្កាត់និងមានការគាំទ្រជានិច្ច។

### ៣.២.៣.៧ ការប្រើប្រាស់ដីក្នុងកិច្ចការពារធនធានធម្មជាតិ និងបរិស្ថាន

- ការប្រើប្រាស់ដីសំរាប់នាទីព្រៃលិចទឹក (ដីសាធារណៈរបស់រដ្ឋ)គឺត្រូវទាមទារអោយមានការថែរក្សាអោយបានគង់វង្ស ដូច្នេះសង្កាត់មានគោលបំណងធ្វើការរៀបចំនូវផែនការក្នុងការពារថែរក្សាអភិរក្ស និងអភិវឌ្ឍន៏ទៅលើធនធានទាំងនេះ ដើម្បីផ្តល់នូវផលប្រយោជន៏ក្នុងការបង្កើនប្រាក់ចំណូលសំរាប់ប្រជាពលរដ្ឋតាមរយៈការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព។
- នៅក្នុងការប្រែប្រួលពីដីវាលភក់ទៅជាដីដែលមានព្រៃលិចទឹកនោះគឺជាអាទិភាពដោយសារដីវាលភក់ស្ថិតនៅក្នុងនាទីព្រៃលិចទឹកគឺជាដីព្រៃលិចទឹកដែលបានកាប់បំផ្លាញកន្លងមកក្លាយទៅជាវាលភក់ដូច្នេះជាគោលការណ៏សង្កាត់មានគំរោងដាំដុះដើមកោងកាងឡើងវិញ ដើម្បីជាធនធានក្នុងតំបន់ផង និងជាដែនជំរក ជីវចំរុះផង និង ជារបាំងការពារទឹករលក និងខ្យល់ព្យុះផង។
- ក្នុងដំណើរការនៃការពារធនធានធម្មជាតិ និងបរិស្ថាននៅក្នុងសង្កាត់ស្ទឹងវែងត្រូវបានអនុវត្ត និងកំណត់ទៅតាមក្របខណ្ឌនៃការទទួលខុសត្រូវលើការគ្រប់គ្រងរបស់ស្ថាប័ននីមួយៗដូចជាតំបន់ដែន ជំរកសត្វព្រៃពាមក្រសោបមានផ្ទៃក្រឡា ២,៦៩៤ ហាត សហគមន៏នេសាទ (មានគំរោងបង្កើតនៅពេលខាងមុខ) មានផ្ទៃក្រឡា ៦២០ ហាត ក្រៅពីនេះសង្កាត់នៅមាននាទីព្រៃលិចទឹកមួយចំនួនទៀតដែលជា

ជំរកដ៏ប្រសើរសំរាប់ធនធានជលផល ដូច្នេះដើម្បីធានានូវសុវត្ថិភាពស្បៀង និងនិរន្តរភាពនៃធនធានក្នុងតំបន់ សង្កាត់បានយកចិត្តទុកដាក់ចូលរួមការពារ និងថែរក្សាអោយមានស្ថេរភាពយូរអង្វែង។

- នៅក្នុងការការពារធនធានជលផលតាមរយៈសហគមន៍នេសាទ និងត្រូវធ្វើដំណើរការរៀបចំលើកគំរោងផែនការក្នុងការកំណត់ការការពារ និងប្រើប្រាស់ដូចខាងក្រោមៈ
    + កំណត់កន្លែងអភិរក្ស មេពូជមច្ឆាជាតិគ្រប់ប្រភេទ
    + កំណត់កន្លែងដែលអាចប្រើប្រាស់បាន ( ធនធានជលផល និងព្រៃលិចទឹក)
    + ដាំដុះព្រៃលិចទឹកឡើងវិញទៅកន្លែងដែលបាត់បង់

## បទបញ្ញត្តិ និងគោលការណ៍នៃការប្រើប្រាស់ធនធាន

ក្នុងក្របខណ្ឌនៃការគ្រប់គ្រង និងប្រើប្រាស់ធនធានរបស់សហគមន៍នេសាទត្រូវបានរៀបចំគ្រប់គ្រង និងប្រើប្រាស់ដូចខាងក្រោមៈ

- កំណត់ការដកយកផល អនុផលព្រៃលិចទឹកត្រូវអនុវត្តទៅតាមលក្ខន្តិករបស់សហគមន៍
- ហាមចាប់សត្វព្រៃគ្រប់ប្រភេទនៅក្នុងកន្លែងព្រៃអភិរក្ស
- ហាមចាប់សត្វដែលច្បាប់ជលផលបានកំណត់
- ហាមកាប់អុសព្រៃលិចទឹកធ្វើអាជីវកម្ម
- ហាមការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់
- ហាមការប្រើប្រាស់ឧបករណ៍ដូចជា ឆក់ បំផ្ទុះគ្រាប់បែក ថ្នាំពុល..។

## គំរោងហេដ្ឋារចនាសម្ព័ន្ធសំរាប់អនុវត្ត

| លេខកូដឃុំ | លេខកូដប្រភេទ | លេខកូដខ្សែផ្លូវ | ឈ្មោះជាអង់គ្លេស | ឈ្មោះជាខ្មែរ | ប្រវែង (ម៉ែត្រ) | ផែនការប្រើប្រាស់ដីធ្លី ១៥ ឆ្នាំ | | |
|---|---|---|---|---|---|---|---|---|
| | | | | | | ៥ ឆ្នាំទី ១ | ៥ ឆ្នាំទី ២ | ៥ ឆ្នាំទី ៣ |
| 90403 | FRD2 | FRD2-01 | Seaked Road | ផ្លូវចាក់កៅស៊ូ | ១១៦៨.៤៥ | ១១៦៨.៤៥ | | |
| 90403 | FRD2 | FRD2-02 | Seaked Road | ផ្លូវចាក់កៅស៊ូ | ១៧១០.០០ | | ១៧១០.០០ | |
| 90403 | FRD2 | FRD2-03 | Seaked Road | ផ្លូវចាក់កៅស៊ូ | ៣៩៣៥.៦៣ | ៣៩៣៥.៦៣ | | |
| 90403 | FRD2 | FRD2-04 | Seaked Road | ផ្លូវចាក់កៅស៊ូ | ៦១៨៣.៦២ | | | ៦១៨៣.៦២ |
| 90403 | FRD9 | FRD9-01 | Concrete Road | ផ្លូវចាក់បេតុង | ៣៣៤.៦២ | | | ៣៣៤.៦២ |
| 90403 | FRD9 | FRD9-02 | Concrete Road | ផ្លូវចាក់បេតុង | ៤៨៦.៥២ | | | ៤៨៦.៥២ |
| 90403 | FRD9 | FRD9-03 | Concrete Road | ផ្លូវចាក់បេតុង | ៤៩០.៨៤ | | ៤៩០.៨៤ | |
| 90403 | FRD9 | FRD9-04 | Concrete Road | ផ្លូវចាក់បេតុង | ៤៩៤.៤២ | | ៤៩៤.៤២ | |
| 90403 | FRD9 | FRD9-05 | Concrete Road | ផ្លូវចាក់បេតុង | ៤៩៨.១៨ | ៤៩៨.១៨ | | |
| 90403 | FRD9 | FRD9-06 | Concrete Road | ផ្លូវចាក់បេតុង | ៣៥៥.២០ | | | ៣៥៥.២០ |
| 90403 | FRD9 | FRD9-07 | Concrete Road | ផ្លូវចាក់បេតុង | ៥៤០.៨៤ | | | ៥៤០.៨៤ |
| 90403 | FRD9 | FRD9-08 | Concrete Road | ផ្លូវចាក់បេតុង | ៨២១.៣៦ | ៨២១.៣៦ | | |
| 90403 | FRD9 | FRD9-09 | Concrete Road | ផ្លូវចាក់បេតុង | ៦៣៧.១០ | ៦៣៧.១០ | | |
| 90403 | FRD9 | FRD9-10 | Concrete Road | ផ្លូវចាក់បេតុង | ១២២០.៩៧ | | ១២២០.៩៧ | |
| 90403 | FRD9 | FRD9-11 | Concrete Road | ផ្លូវចាក់បេតុង | ៣២១.៦០ | | | ៣២១.៦០ |
| 90403 | FRD4 | FRD4-01 | Laterite Road | ផ្លូវគ្រួសក្រហម ឬក្រាលថ្ម | ១៥៦០.៧៥ | | ១៥៦០.៧៥ | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 90403 | FRD4 | FRD4-02 | Laterite Road | ផ្លូវគ្រួសក្រហម ឬក្រាលថ្ម | ៦១៣៧១ | | | ៦១៣៧១ |
| 90403 | FRD4 | FRD4-03 | Laterite Road | ផ្លូវគ្រួសក្រហម ឬក្រាលថ្ម | ១០១៥៩៧ | ១០១៥៩៧ | | |
| 90403 | FRD4 | FRD4-04 | Laterite Road | ផ្លូវគ្រួសក្រហម ឬក្រាលថ្ម | ៥២៤០២ | | | ៥២៤០២ |
| 90403 | FRD4 | FRD4-05 | Laterite Road | ផ្លូវគ្រួសក្រហម ឬក្រាលថ្ម | ៦៧៨១០ | ៦៧៨១០ | | |
| 90403 | FRD9 | FRD4-12 | Create Road | ផ្លូវចាក់បេតុង | ២៨៤២៣ | ២៨៤,២៣ | | |
| 90403 | FRD9 | FRD4-13 | Create Road | ផ្លូវចាក់បេតុង | ១៧៨០០ | | | ១៧៨០០ |
| 90403 | FRD9 | FRD4-14 | Create Road | ផ្លូវចាក់បេតុង | ១៦៥៦៥ | ១៦៥៦៥ | | |
| 90403 | FDN57 | FDN57-01 | Canal | ស្ពានប្រឡាយ | ១៤៤៨,០០ | | | |
| 90403 | FDN57 | FDN57-02 | Canal | ស្ពានប្រឡាយ | ៧៩៥,០០ | | | |
| 90403 | FDN57 | FDN57-03 | Canal | ស្ពានប្រឡាយ | ១៣៥០,០០ | | | |

សង្កាត់ស្ទឹងវែង.ថ្ងៃទី...18...ខែ...5...ឆ្នាំ 2010

**ចៅសង្កាត់**

**សុប_ហ៊ុសេន**

**បានឃើញ និង ពិនិត្យត្រឹមត្រូវ**

គោរពជូនឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត

និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកោះកុង

"ដើម្បីមេត្តាពិនិត្យ និង សំរេច"

ក្រុងខេមរភូមិន្ទ.ថ្ងៃទី...18...ខែ...5...ឆ្នាំ ...2010.

**អភិបាលនៃគណៈអភិបាលក្រុង**

**និង ប្រធានក្រុមការងារដីរដ្ឋ**

**ក្រុង ខេមរភូមិន្ទ**

**ផៃធូន_ផ្លាមកេសន**

[illegible]

**បានឃើញ និង ឯកភាព**

កោះកុង.ថ្ងៃទី..០៥.....ខែ..មិថុនា..ឆ្នាំ ២០១០..

**អភិបាលនៃគណៈអភិបាលខេត្ត**

**និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ**

**ខេត្តកោះកុង**

**ប៊ុន លើត**

## ឧបសម្ព័ន្ធ ១

❖ ការពិពណ៌នា អំពីស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

### ១. ដីលំនៅដ្ឋានទីប្រជុំជន

ដីលំនៅដ្ឋានទីប្រជុំជននៅក្នុងសង្កាត់ស្ទឹងវែង គឺជាដីស្ថិតនៅតាមដងផ្លូវដែលមានស្ថានភាពជាដីទីទួលខ្ពស់ និង ដោយចាក់ដីបំពេញធ្វើជាលំនៅដ្ឋាន និងមានប្រជាជនរស់នៅច្រើន។ ជាមួយនេះដែរដីលំនៅដ្ឋានទីប្រជុំជនទាំងនេះមាន ដាំដំណាំរួមផ្សំនានាជាច្រើនដូចជា ម្ទេស, ននោង, ត្រឡាច, ល្ពៅ, ស្លឹកគ្រៃ, ចេក, ដូង, ខ្នុរ, ទៀបបារាំង............។ល។ ដីលំនៅដ្ឋានទីប្រជុំជនភាគច្រើនស្ថិតនៅជាប់តគ្នាតាមបណ្ដោយផ្លូវ ហើយមានទំហំមិនលើសពី ១ ហិចតា។

### ២. ដីលំនៅដ្ឋានភូមិ

- **ដីភូមិលាយសួនដំណាំ :**

ដីភូមិលាយសួនដំណាំនៅក្នុងសង្កាត់ស្ទឹងវែង គឺជាដីស្ថិតនៅតាមដងផ្លូវនិងនៅផ្ដុំគ្នាជាភូមិដាច់ស្រយាល ដែលមានស្ថានភាពដីជាទីករលក។ នៅតំបន់ដីទួលគឺភាគច្រើនពុំមានជីវជាតិសំរាប់ធ្វើកសិកម្ម ដាំដំណាំឈើហូប និង ដំណាំរួមផ្សំផ្សេងៗទេ ដោយឡែកតំបន់ទំនាបគឺជាប្រភេទដីល្បាប់ និងសំបូរទៅដោយជីវជាតិ ហើយដីប្រភេទនេះវា អំណោយផលដល់ពពួករុក្ខជាតិផ្សេងៗ ក៏ដូចជាដំណាំស្រូវផងដែរ។ ចំពោះតំបន់ទំនាបខ្លះត្រូវបានគេចាក់បំពេញធ្វើជា ភូមិដ្ឋានជាមួយនេះដែរភូមិទាំងនោះត្រូវបានដាំនូវដំណាំរួមផ្សំជាច្រើនដូចជា ម្ទេស ស្ពៃ ននោង ត្រឡាច ល្ពៅ ស្លឹកគ្រៃ ចេក ដូង ដំឡូង ស្វាយ ល្មុត ខ្នុរ ស្វាយចន្ទី ........។ល។ ដីភូមិលាយសួនដំណាំនៅក្នុងសង្កាត់ស្ទឹងវែងស្ថិតនៅជាប់តគ្នា តាមបណ្ដោយផ្លូវ និង នៅតាមដៃព្រែក អូរ ។

តាមស្ថានភាពជាក់ស្ដែង បើតាមការអង្កេតឃើញថាលទ្ធភាព សំរាប់ដីភូមិលាយសួនដំណាំនៅសង្កាត់ស្ទឹងវែងគឺ មានស្រះ អូរ អាចផ្ដល់ទឹកសំរាប់ប្រើប្រាស់ ប៉ុន្តែជាក់ស្ដែងនៅរដូវប្រាំង ពុំសូវមានប្រជាពលរដ្ឋដាំដំណាំឡើយព្រោះនៅ ក្នុងសង្កាត់នេះនៅរដូវប្រាំងមិនសូវសំបូរទឹកសំរាប់ធ្វើការដាំដុះទេ។

### ៣. ដីភូមិលាយស្រែ :

ដីភូមិលាយស្រែ គឺជាដីដែលភាគច្រើនជាដីភូមិដែលស្ថិតនៅ ដាច់ៗពីគ្នា ហើយនៅក្នុងរង្វង់ដីភូមិមានដី ស្រែផ្នែកខាងក្រោយនៃក្រោយផ្ទះ រឺដីភូមិ ចំពោះដីស្រែក្នុងភូមិគេច្រើនប្រើសំរាប់ធ្វើទីសំណាប ម្យ៉ាងវិញទៀតចំពោះ អ្នកមានដីភូមិជាប់អូរគេអាចដាំដំណាំខ្លះៗនៅរដូវប្រាំង ដូចជា,សណ្ដែក ត្រសក់ ននោង ត្រឡាច ល្ពៅ ......។ល។ ដីភូមិលាយស្រែភាគច្រើនស្ថិតផ្នែកខាងក្រោយនៃដីភូមិ ។ ដីភូមិលាយស្រែច្រើនស្ថិតនៅដាច់ពីគេព្រោះដីភូមិខ្លះទើប មានគ្រួសារបែកផ្ទះថ្មី និងដីភូមិខ្លះជាដីភូមិតាំងពីយូយាណស់មកហើយ។

ដីស្រែក្នុងភូមិបច្ចុប្បន្នត្រូវបានប្រើប្រាស់ធ្វើជាទីសំណាប និងដាំនូវដំណាំរយៈពេលខ្លីដូចជា សណ្ដែក ល្ពៅ ននោង.. និង បន្លែ គ្រប់ប្រភេទ ប៉ុន្តែទៅថ្ងៃអនាគត ដីនេះនឹងក្លាយជាដីភូមិ ដែលត្រូវឱពុក ម្ដាយចែកអោយកូន ។ ដីស្រែលាយភូមិភាគច្រើនមានទំហំតូចៗ ហើយមានទំហំពី ៣០០ម ដល់ ១០០០ម។

ដូច្នេះតាមការពិនិត្យសក្តានុពលនៃការប្រើប្រាស់ដីឃើញថាគ្មានតុល្យភាពទៅនិងកំណើន និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋឡើយ គឺបង្កើនផលិតភាពលើវិស័យកសិកម្មអោយបានល្អប្រសើរជាងមុន ( បញ្ចូលបច្ចេកវិទ្យាថ្មី) ។

**៤. ដីស្រែវស្សា :**

**- ដីស្រែវស្សា ( ស្រូវសន្ទូង)**

ដីស្រែវស្សា នៅសង្កាត់ស្ទឹងវែងត្រូវបានប្រើប្រាស់ក្នុងការធ្វើស្រែ (ស្រែវស្សា) ការធ្វើស្រែវស្សារបស់ប្រជាជននៅក្នុងសង្កាត់ស្ទឹងវែងថ្វីត្បិតត្រូវពឹងផ្អែកទៅលើទឹកភ្លៀង ប៉ុន្តែដីតំបន់ខ្លះក៏ធ្វើបាន កន្លែងខ្លះទៀតក៏ធ្វើមិនបាន នៅក្នុងការថែទាំស្រូវ កសិករដែលមានដីស្រែដែលស្ថិតនៅទីខ្ពស់ ត្រូវបានប្រើប្រាស់ជីគីមីច្រើនជាជំនួយផងដែរដោយឡែកចំពោះស្រែទំនាបមិនសូវប្រើជីគីមីច្រើនឡើយ ព្រោះជាប្រភេទដីមានជីជាតិស្រាប់ ដូច្នេះគេអាចប្រើជីធម្មជាតិរួមផ្សំ ។ ដីស្រែវស្សាគេអាចធ្វើបានផលពី ១.៥ទៅ ២ តោន ក្នុងមួយហិចតា ដោយប្រើប្រភេទស្រូវស្រាល និងស្រូវធ្ងន់មានដូចជា IR 57 ។

ដីស្រែស្រូវវស្សានៅក្នុងសង្កាត់ស្ទឹងវែងមានចំនួន ៧០,១២ ហិចតា ។ ពេលវេលានៃការធ្វើស្រែវស្សារបស់ប្រជាជននៅក្នុងសង្កាត់ស្ទឹងវែងមានរយៈពេល ៦ ខែ ពីខែ មិថុនា ដល់ ខែ វិច្ឆិកា ។

ដីស្រែវស្សាបច្ចុប្បន្ន ក៏នៅពុំទាន់បំរើបាននៅសេចក្តីត្រូវការប្រើប្រាស់អោយអស់លទ្ធភាពនៅឡើយ ព្រោះវានៅមានបញ្ហាចោទលើការខ្វះទឹក ពិសេសការរាំងស្ងួត ជាពិសេសដីតំបន់ខ្លះខ្សោះជីវជាតិ ដែលកត្តាទាំងនេះធ្វើអោយទិន្នផលទាប ។ ករណីនេះដោយសារការខ្វះប្រព័ន្ធធារាសាស្ត្រក្នុងការជួយសង្គ្រោះពេលខ្វះទឹកនៅកូនរដូវប្រាំង ឬការរាំងស្ងួត ។

**៥. ដីចំការឈើហូបផ្លែ**

ដីចំការឈើហូបផ្លែនៅក្នុងសង្កាត់ស្ទឹងវែង គឺភាគច្រើនជាដីដែលនៅឆ្ងាយពីតំបន់ទីប្រជុំជន ហើយជួនខ្លះក៏ជាដីដែលនៅក្បែរលំនៅដ្ឋានផងដែរ ដីចំការឈើហូបផ្លែទាំងនេះមានទំហំប្រហែល ៣៤៧,៣៥៥៥ ហត ។

នៅក្នុងសង្កាត់ស្ទឹងវែងដីចំការឈើហូបផ្លែអាចដាំបានដំណាំនានាទាំងនោះដូចជា ខ្នុរ. ស្វាយ. ត្រប់បែក. ល្មុត.បំពេញរាជ្យ.ម្កាក់ និងប្រភេទឈើហូបផ្លែផ្សេងៗទៀត ។ ដោយដំណាំទាំងនេះដាំពឹងផ្អែកលើទឹកភ្លៀងទាំងស្រុងព្រោះខ្វះប្រព័ន្ធស្រោចស្រព និងគ្មានបច្ចេកទេសត្រឹមត្រូវនូវឡើយ ។ ដូច្នេះយើងត្រូវចាប់អារម្មណ៏ជាសំខាន់លើការពង្រីកប្រព័ន្ធទឹកសំរាប់ស្រោចស្រព្វ និង ត្រូវផ្តល់ជូននូវបច្ចេកទេសថ្មីៗ ហើយផ្សព្វផ្សាយអោយបានទូលំទូលាយដល់ពួកគាត់ដើម្បីអោយពួកគាត់មានទឹកចិត្តក្នុងការចូលរួម ។

**៦. ចំការស្វាយចន្ទី**

ដីចំការស្វាយចន្ទីនៅក្នុងសង្កាត់ស្ទឹងវែង គឺជាដីដែលឆ្ងាយពីដីភូមិហើយក៏មានមួយចំនួនតូចរួមជាមួយដីភូមិផងដែរ ។ នៅក្នុងសង្កាត់នេះភាគច្រើនគេដាំស្វាយចន្ទីដើម្បីរក្សាដីដែលគេទុកចោលទំនេរចោលដោយជីវជាតិដីទាំងនោះវាមិនសមស្របទៅនឹងដំណាំផ្សេងៗក្រៅពីដំណាំស្វាយចន្ទី ម្យ៉ាងទៀតគ្រប់រាល់មុខដំណាំទាំងអស់ពឹងផ្អែកទាំងស្រុងលើទឹកភ្លៀង ។

### ៧. ស្រែក្នុងបឹង/អូរ

ផ្ទៃដីស្រែនៅក្នុងបឹង/អូរមានលក្ខណៈធំគួរសម ដោយផ្ទៃដីស្រែទាំងនោះត្រូវបានគេទុកចោលជាយូរណាស់មកហើយ ព្រោះវាមិនបង្កលក្ខណៈល្អសំរាប់ធ្វើស្រែចំការឡើយ។ ដីទាំងនោះភាគច្រើនលិចទឹកនៅរដូវវស្សាហើយសំបូរទៅដោយដើមរុក្ខជាតិតូចៗលាយឡំគ្នា ដែលវាជាហេតុធ្វើអោយមានការពិបាកក្នុងការសំអាតសំរាប់ធ្វើស្រែចំការ។ ដោយឡែកតំបន់នោះជូនពេលខ្លះក្លាយជាតំបន់ដែលប្រជាជនអាចរកត្រី-ក្តាមបានបរិភោគដែរ។

### ៨. ព្រៃដុះតាមមាត់ទឹក (អូរ.ស្ទឹង)

នៅក្នុងសង្កាត់ស្ទឹងវែងប្រភេទព្រៃដុះតាមមាត់អូរ.ស្ទឹង គឺជាប្រភេទព្រៃដែលធន់នឹងទឹកប្រៃផង និង ទឹកសាបផងដែរ ព្រោះនៅក្នុងតំបន់នេះមានលក្ខណៈទឹកសាបលាយទឹកប្រៃនៅពេលទឹកជោ និងទឹកនាច និងម្យ៉ាងទៀតនៅក្នុងសង្កាត់ នេះម្ខាងព្រៃអូរជាប្រភេទទឹកសាប និងម្ខាងអូរទៀតជាទឹកប្រៃ ដូច្នេះចំពោះព្រៃទាំងនោះវាអាចរស់ធន់ទៅនឹងស្ថានភាពបែបនេះបាន។ ព្រៃទាំងនោះមានដូចជា ដើមស្មាច់. ដើមកាចាត. ដើមតាអោន...។ល។ ចំពោះព្រៃខ្លះវាក៏មានសារៈសំខាន់សំរាបប្រជាពលរដ្ឋ និង សត្វដែលគេអាចយកវាទៅធ្វើជាលំនៅដ្ឋានល្មមសំរាប់ប្រជាពលរដ្ឋដែលទ័លក្រ និងម្យ៉ាងទៀតអាចផ្តល់ជាទីជំរកសត្វស្លាបសត្វគោ-ក្របីទៀតផងនៅរដូវប្រាំង។ ប៉ុន្តែបច្ចុប្បន្នព្រៃទាំងនេះត្រូវបានគេហាមប្រាបមិនអោយប្រជាជនធ្វើការកាប់បំផ្លាញទៀតទេ ។

### ៩. ព្រៃលិចទឹក (កោងកាង)

ដីព្រៃលិចទឹក (កោងកាង) នៅក្នុងសង្កាត់ស្ទឹងវែងរួមមាន ទំហំ ៥៧២,៦៧១៨ ហិចតា ដែលព្រៃទាំងនោះមានកំពស់មិនលើសពី ៥ ម៉ែត្រ ហើយនៅតាមមាត់ទឹក និងដៃសមុទ្រ។ ចំពោះតំបន់ព្រៃលិចទឹកមធ្យមស្ថិតនៅចន្លោះ ព្រៃក្រាស់មានកំពស់ ពី ៥ម ទៅ ៧ម ដែលព្រៃទាំងនោះមាននៅព្រែកស្វាយ និងភូមិស្ទឹងវែងមានតិចតួច។ ដោយឆ្លងតាមស្ថានភាពនៃការប្រែប្រួលនៃព្រៃលិចទឹកបានធ្វើអោយព្រៃលិចទឹកមានការរេចរិល ដោយកត្តាមួយចំនួន ដូចជាការកាប់វាតយកដី,ការកាប់ព្រៃធ្វើអុសលក់,ការកាប់ធ្វើសំណង់ ឫផលប្រយោជន៍ផ្សេងៗ។ បច្ចុប្បន្នព្រៃលិចទឹកកំពុងទទួលរងការកាប់បំផ្លាញវាតយកដីពីប្រជាពលរដ្ឋក្នុងតំបន់ ដោយមានការចូលលុកលុយពីសំណាក់ឈ្មួញដែលមកពីខាងក្រៅបានចូលទៅបំផុសអោយប្រជាពលរដ្ឋចាប់យក និង កាប់វាតយកដីរួចហើយពួកគេប្រមូលទិញដោយយកលេសទៅលើការអភិវឌ្ឍន៏វិស័យកសិកម្ម ។

ព្រៃលិចទឹកបច្ចុប្បន្នថ្វីត្បិត តែកំពុងទទួលរងនូវការបំផ្លិចបំផ្លាញគឺវាអាស្រ័យដោយប្រជាពលរដ្ឋមួយចំនួនពុំទាន់ដឹងអំពីច្បាប់ ម្យ៉ាងទៀតគឺអាស្រ័យដោយកំរិតជីវភាពបង្ខំនិងការខ្វះខាតដីពិសេសនៅពេលដីឡើងថ្លៃពួកគាត់លក់អោយឈ្មួញអស់ដែលជាហេតុបណ្តាលអោយនៅពេលនេះខ្វះដី ធ្វើអោយពួកគាត់ត្រូវស្វែងរកដីថ្មីដើម្បីបង្កបង្កើនផលហេតុដូចនេះយើងគួរគប្បីត្រូវ :

១. ផ្សព្វផ្សាយច្បាប់អោយបានទូលំទូលាយ និងអនុវត្តច្បាប់អោយបានម៉ឺងម៉ាត់

២. ដាំកូនឈើព្រៃលិចទឹកឡើងវិញ ដើម្បីផ្សព្វផ្សាយ អោយប្រជាពលរដ្ឋ យល់ដឹងពីសារៈសំខាន់ព្រៃលិចទឹក ។

៣. កំណត់ព្រំប្រទល់នាទីព្រៃលិចទឹក និង ដាក់បង្គោលព្រំប្រទល់ អោយបានច្បាស់លាស់

៤. ការពារនូវការកាប់រំលោភចូលដីនាទី ព្រៃលិចទឹក និង ចាត់វិធានការអោយបានធ្ងន់ធ្ងរចំពោះអ្នកប្រព្រឹត្តល្មើសក្នុងការកាប់ទន្ទ្រានចូលក្នុងនាទីព្រៃលិចទឹក។

**១០. ព្រៃលិចទឹកស្តើង (ព្រៃកោងកាង)**

ផ្ទៃដីព្រៃកោងកាងស្តើងមានប្រមាណ ៣២៨,១០៨៥ ហត ដែលព្រៃទាំងនោះមានកំពស់មិនលើសពី ៣-៥ ម ដែលវាមានដុះនៅតាមមាត់ទឹកអូរ និងព្រែក។

បច្ចុប្បន្នព្រៃទាំងនេះកំពុង ទទួលរងការកាប់បំផ្លាញវាតយកដីពីប្រជាពលរដ្ឋក្នុងតំបន់ ដោយមានការចូលលុកលុយពីសំណាក់ឈ្មួញដែលមកពីខាងក្រៅបានចូលទៅបំផុសអោយប្រជាពលរដ្ឋចាប់យក និង កាប់វាតយកដីរួចហើយពួកគេប្រមូលទិញដោយយកលេសទៅលើការអភិវឌ្ឍន៏វិស័យផ្សេងៗ។ម្យ៉ាងទៀតដោយក៏រិតជីវភាពរបស់ប្រជាជនមានក៏រិតដូច្នេះហើយទើបបង្ខំអោយពួកគាត់វាតដីជាសាធារណៈរបស់រដ្ឋដើម្បីធ្វើអាជីវកម្មក៏ដូចជាលក់អោយឈ្មួញដទៃទៀត។

**១១. វាលស្មៅ**

ដីវាលស្មៅនៅក្នុងសង្កាត់ស្ទឹងវែងមានទំហំ ៨៥៨,៤៧៩២ ហត ត្រូវបានធ្វើការចាត់ថ្នាក់ជាពីរ គឺវាលស្មៅនៅតំបន់វាលស្រែដែលគេ បោះបង់ចោលដោយគ្របដណ្តប់ដោយវាលស្មៅ និង វាលស្មៅលិចទឹកដែលស្ថិតនៅតំបន់នាទីព្រៃលិចទឹក។ តំបន់វាលស្មៅដែលជាដីស្រែបោះបង់ចោលគ្របដណ្តប់ដោយស្មៅនេះ ក៏ជាដីស្រែដែលបានកាប់វាតដីព្រៃលិចទឹកយកមកធ្វើស្រែ។

ផ្អែកតាមបញ្ហាខាងលើ និង បើគិតតាមស្ថានភាព ជាកស្តែង ទៅលើដីវាលស្រែដែលបោះបង់ចោល គឺត្រូវរៀបចំកំណត់ដែនគ្រប់គ្រងអោយបានត្រឹមត្រូវដើម្បីងាយស្រួលក្នុងការពង្រីកលើវិស័យកសិកម្មក្នុងមូលដ្ឋាន។

**១២. ព្រៃកាប់ស្តារ**

ព្រៃកាប់ស្តារនៅក្នុងសង្កាត់ស្ទឹងវែងមានទំហំ ៨៧៧,១១៥៥ ហ.ត ដែលព្រៃទាំងនោះកាលពីដើមជាប្រភេទដីព្រៃក្រាស់និងសំបូរទៅដោយរុក្ខជាតិតូចៗដុះទ្រុឌទ្រោលហើយសំបូរទៅដោយសត្វព្រៃមួយចំនួនប៉ុន្តែក្រោយមកបន្ទាប់មានការកើននូវចំនួនប្រជាជនច្រើនហើយវាស្របទៅនឹងដីឡើងថ្លៃផងនោះទើបជំរុញឱ្យប្រជាជនទាំងអស់នោះកាប់ឆ្ការធ្វើ .ដីស្រែ និងចំការដំណាំផ្សេងៗតាមដែលអាចធ្វើបានតាមស្ថានភាពជាក់ស្តែងរបស់ដី ។ ព្រោះនៅតំបន់ នោះកាលពីមុន ដីស្រែ ដីព្រៃ មួយចំនួនពុំទាន់មានការកាន់កាប់ពីស្ថានប័នរបស់រដ្ឋណាកាន់កាប់នោះទេ ដោយឡែករហូតមកដល់ សម័យបច្ចុប្បន្នព្រៃទាំងអស់នោះត្រូវបានគេធ្វើការអភិរក្ស ថែរក្សា និងធ្វើការដាំដុះឡើងវិញ។

**១៣. បឹង**

ស្ថានភាពប្រភពទឹកនៅក្នុងសង្កាត់ស្ទឹងវែងទឹកបឹងមានទំហំ 0,១៦០២ ហត.។ ប្រភពទឹកដែលមាននៅក្នុងសង្កាត់ត្រូវបានផ្តល់នូវសារៈប្រយោជន៏យ៉ាងច្រើនដល់ប្រជាពលរដ្ឋនៅក្នុងតំបន់ដូចជា ការផ្គត់ផ្គង់ដល់វិស័យកសិកម្មក្នុងនោះរួមមានជាប្រភពស្រោចស្រព ដីស្រែ និង ផលដំណាំ , ផ្តល់ការប្រើប្រាស់ផ្សេងៗរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ។

### ១៤. អូរ, ស្ទឹង, ទន្លេ

នៅសង្កាត់ស្ទឹងវែងមានផ្ទៃទឹកដែលជាប្រភពនេសាទ ដែលស្ថិតនៅក្នុងសង្កាត់។ ម្យ៉ាងវិញទៀតនៅក្នុងសង្កាត់មានសមុទ្រ ដែលមានទំហំ ០,៨២៧៩ហត។

ចំពោះស្ថានភាពនៃទឹក,បឹង,ព្រែក, អូរ,នៅក្នុងមូលដ្ឋានត្រូវបានផ្តល់នូវផលប្រយោជន៍ និង លទ្ធភាពក្នុងការប្រើប្រាស់ដល់ប្រជាពលរដ្ឋ ទាំងក្នុង និង ក្រៅសង្កាត់ដូចជា :

- ផ្តល់នូវផលត្រី ក្នុងការប្រើប្រាស់ និង ធ្វើអាជីវកម្ម ដើម្បីបង្កើនប្រាក់ចំណូលក្នុងគ្រួសារ
- ផ្តល់នូវទីជម្រក សំរាប់ការចតទូក កាណូត និង ផ្ទះ ដើម្បីជៀសផុតពី ខ្យល់ព្យុះ រលក
- ផ្តល់ទឹកក្នុងការប្រើប្រាស់ សំរាប់ការស្រោចស្រពស្រែ ,ចំការ និង ផលដំណាំ នានា
- ផ្តល់ទឹកសំរាប់ការប្រើប្រាស់របស់ប្រជាពលរដ្ឋ និង គោ ក្របី និង ការចិញ្ចឹមសត្វផ្សេងៗប្រសិនបើមានការកសាងនូវប្រពន្ធ័ប្រឡាយ យើងក៏ត្រូវចាប់អារម្មណ៏លើការស្តារនូវប្រភពទឹកមួយចំនួនដែរដូចជា អូរ, ស្ទឹង ព្រែក ទើបអាចធានាបាននូវប្រភពទឹកសំរាប់ស្រោចស្រព ។

### ១៥. សមុទ្រ

ផ្ទៃដីសមុទ្រ ៥១៨,០៨៧៦ ហត នៅតាមមាត់សមុទ្រមានព្រៃកោងកាងដុះដែរ។ នៅក្នុងសង្កាត់ស្ទឹងវែងប្រជាជនភាគច្រើនប្រកបរបរនេសាទទៅតាមផ្ទៃសមុទ្រក្រៅពីការធ្វើកសិកម្ម។ ដែលប្រភពនៅក្នុងសមុទ្រនេះមានដូចជា ក្តាមសេះ. ក្តាមថ្ម. ក្តាមជ័រ (ក្តាមសំរាប់ប្រៃ). ខ្យងប៉ាវ៉ា. ខ្យងជើងមួយ.ខ្យងអ័យស្ទ័រ. ត្រីខ្លង់. ត្រីឆ្លាម. បង្គា. បឺក. បបែល...។ល។ សមុទ្រនេះសំបូរទៅធនធានធម្មជាតិច្រើនបែបណាស់សំរាប់ប្រជាពលរដ្ឋផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃ។

### ១៦. បឹងមានទឹកជាប្រចាំ

បឹងដែលមានទឹកជាប្រចាំនៅក្នុងសង្កាត់នេះមានទំហំប្រមាណ ១,៥៩៣៨ ហត ប៉ុណ្ណោះ ដែលផ្ទៃទឹកទាំងនេះ វាបានផ្តល់នូវអត្ថប្រយោជន៏មួយចំនួនសំរាប់ប្រជាជន ក៏ដូចជាសត្វមួយចំនួនដែលរស់នៅក្នុងតំបន់នោះផងដែរព្រោះវាអាចផ្តល់ទឹកសំរាប់បរិភោគ និងម្យ៉ាងទៀតវាក៏ជាប្រភពសំរាប់អោយប្រជាជនទាំងអស់នោះរកត្រី. ក្តាម. ខ្យងបានផងដែរ មិនត្រឹមតែប៉ុណ្ណោះប្រជាជនទាំងក៏អាចដាំនូវប្រភេទបន្លែ រឺធ្វើចំការដំណាំផ្សេងៗបាន។ នៅក្នុងតំបន់នេះបើទោះបីជាផ្ទៃបឹងពុំសូវធំទូលាយក៏ដោយក៏វាមានសារៈសំខាន់សំរាប់ប្រជាជនមួយផ្នែករស់នៅទីនោះដែរ។

### ១៧. បឹងមានទឹកនៅរដូវវស្សា

ចំពោះបឹងមានទឹកនៅរដូវវស្សា គឺមានទំហំប្រមាណ ៣,៥០៩៦ ហត ដែលផ្ទៃទឹកវាបានផ្តល់ទឹកគ្រប់គ្រាន់សំរាប់ប្រជាជនធ្វើស្រែចំការច្បារដំណាំផ្សេងៗ។ ម្យ៉ាងទៀតផ្ទៃបឹងនេះផ្តល់ប្រយោជន៏ច្រើនសំរាប់ប្រជាជនរស់នៅតំបន់នោះពិសេសផ្តល់កន្លែងនេសាទដ៏សំបូរបែប និងផ្តល់ប្រភពទឹកសំរាប់ស្រោចស្រព ផ្តល់ប្រភពបន្លែមួយចំនួនដូចជា

ព្រលិត ត្រកួន កញ្ឆែត និងប្រភេទបន្លែផ្សេងៗទៀត ។ ម្យ៉ាងផ្ទៃបឹងនេះវាសំបូរត្រីជាច្រើននៅរដូវវស្សា មានដូចជា ត្រីរស់ ត្រីអណ្តែង. ត្រីក្រាញ់. ខ្យង. ក្តាម និងប្រភេទត្រីមួយចំនួនទៀត ។

**១៨. ស្រះ**

ស្ថានភាពដីស្រះនៅក្នុងសង្កាត់ស្ទឹងវែងជាប្រភេទស្រះតូចតាចប៉ុណ្ណោះ ដែលមានផ្ទៃដីប្រមាណ ៤.៣១១៦ ម ហើយមានប្រជាជនមួយចំនួនតូចប្រើប្រាស់សំរាប់ធ្វើការស្រោចស្រព និងផ្តល់ទឹកអោយគោ ជាពិសេសក៏ប្រើសំរាប់បរិភោគផងដែរ ។ ជាងនេះទៅទៀតប្រភពទឹកស្រះនេះក៏ជាប្រភពត្រី និងប្រភពបន្លែដូចជា ព្រលិត ត្រកួន និង កញ្ឆែត ដែលអាចផ្តល់ប្រាក់ចំណូលបន្ថែមសំរាប់ពួកគាត់ផងដែរ ។

**១៩. ដីស្រែបង្គា**

នៅក្នុងសង្កាត់ស្ទឹងវែងមានផ្ទៃដីប្រមាណ ៧៣.៤៩០១ ហាត ដែលសំរាប់ចិញ្ចឹមបង្គា ហើយនៅ ជុំវិញដីនោះ មានដើមឈើតូច/ធំ និងលើកជាទំនប់ ហើយគេសង់ជាទ្វាទឹកសំរាប់ធ្វើការផ្លាស់ប្តូរចរន្តទឹកចេញ-ចូល ធ្វើយ៉ាងនេះ ដើម្បីការពារបង្គាអោយធំធាត់លឿននិងមានសុខភាពល្អ ។ដោយឡែកបច្ចុប្បន្នការចិញ្ចឹមបង្គាត្រូវបានផ្អាកការចិញ្ចឹម ដោយទុកដីនោះចោលនូវទំនេរព្រោះការចិញ្ចឹមត្រូវការថែទាំយកចិត្តទុកដាក់និងចំណើច្រើនណាស់ម្យ៉ាងដោយ ទីផ្សារ របស់វាមានតំលៃថោកជាង បង្គាក្នុងស្រុក ដូច្នេះជាហេតុជំរុញឱ្យពួកគាត់ផ្អាកការចិញ្ចឹមបង្គាជាបណ្តោះអាសន្ន ។

| រល | ចំណាត់ថ្នាក់ប្រើប្រាស់ដីលំអិត | ប្រើប្រាស់ដីលំអិត ប្រើប្រាស់ដីលំអិត រូបភាពនៃការប្រើប្រាស់ដី |
|---|---|---|
| | **Code 3500**<br>ព្រៃកោងកាង |  |
| | **Code : 3610**<br>ព្រៃកោងកាងស្តើង |  |
| | **Code 5220**<br>សមុទ្រ |  |
| | **Code 3500**<br>ព្រៃលិចទឹក |  |
| | **Code:6420**<br>ព្រៃកាប់ឆ្ការ |  |

| | | |
|---|---|---|
| | Code 2110<br>ស្រូវវស្សា |  |
| | Code : 5130<br>ស្រះ |  |
| | Code: 4100<br>វាលស្មៅ |  |
| | Code: 2310<br>ចំការឈើហូបផ្លែ |  |
| | Code  2111<br>ស្រែជាមួយភូមិ |  |

| | | |
|---|---|---|
| | Code: 3400<br>ព្រៃដុះឡើងវិញ |  |
| | Code: 5210<br>ទន្លេ ស្ទឹង អូរ |  |
| | Code: 2323<br>ចំការស្វាយចន្ទី |  |
| | Code:1300<br>ហេដ្ឋារចនាសម្ព័ន្ធ |  |

# ឧបសម្ព័ន្ធ ២

## ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដីបច្ចុប្បន្ន (ផែនទីA-3)

| ល.រ | ចំណាត់ថ្នាក់នៃការគ្រប់គ្រង និងកាន់កាប់ដី | | ក្រឡាផ្ទៃ (ហិចតា) |
|---|---|---|---|
| | តាមច្បាប់អនុញ្ញាត្តិ និងតួនាទី | តាមចំណាត់ថ្នាក់ដីរដ្ឋ និងដីឯកជន | |
| ១ | ដីលំនៅដ្ឋានទីប្រជុំជន | ដីសាធារណៈរបស់រដ្ឋ-ដីឯកជនរបស់រដ្ឋ | ១១២.៦៣ |
| ២ | ដីលំនៅដ្ឋានភូមិ | ដីសាធារណៈរបស់រដ្ឋ-ដីឯកជនរបស់រដ្ឋ | ២៧.៨៧ |
| ៣ | ហេដ្ឋារចនាសម្ព័ន្ធ | ដីសាធារណៈរបស់រដ្ឋ | ៤.៥ |
| ៤ | ស្រូវវស្សា | ដីសាធារណៈរបស់រដ្ឋ | ៤៦.៦២ |
| ៥ | ស្រែជាមួយភូមិ | ដីឯកជនរបស់រដ្ឋ | ១៦.២៩ |
| ៦ | ស្រែក្នុងបឹង/អូរ | ដីសាធារណៈរបស់រដ្ឋ | ៣៨.២៤ |
| ៧ | ចំការឈើហូបផ្លែ | ដីសាធារណៈរបស់រដ្ឋ | ៣៣.៤៦ |
| ៨ | ចំការស្វាយចន្ទី | ដីឯកជនរបស់រដ្ឋ | ៨.៩៩ |
| ៩ | ព្រៃដុះតាមមាត់ទឹក | ដីសាធារណៈរបស់រដ្ឋ | ៦.៩១ |
| ១០ | ព្រៃកោងកាង | ដីសាធារណៈរបស់រដ្ឋ | ៥១៤.៦៥ |
| ១១ | ព្រៃកោងកាងស្តើង | ដីសាធារណៈរបស់រដ្ឋ | ២២៦.៤០ |
| ១២ | វាលស្មៅ | ដីសាធារណៈរបស់រដ្ឋ | ៣៦០ |
| ១៣ | បឹងមានទឹកជាប្រចាំ | ដីសាធារណៈរបស់រដ្ឋ | ១.៥៥ |
| ១៤ | បឹងមានទឹកនៅរដូវវស្សា | ដីសាធារណៈរបស់រដ្ឋ-ដីឯកជនរបស់រដ្ឋ | ៣.៣៧ |
| ១៥ | ព្រែក/ស្ទឹង/អូរ | ដីសាធារណៈរបស់រដ្ឋ | ០.៨២ |
| ១៦ | សមុទ្រ | ដីសាធារណៈរបស់រដ្ឋ | ៥៤៧.៩៦ |
| ១៧ | ស្រែចិញ្ចឹមបង្គា/ត្រី | ដីឯកជនរបស់រដ្ឋ | ៥២.១៣ |
| ១៨ | ព្រៃកាប់ឆ្ការ | ដីសាធារណៈរបស់រដ្ឋ | ៨០៤.៤៥ |

## ឧបសម្ព័ន្ធ ៣

### បញ្ហាប្រឈម និងសក្តានុពល (ផ្តែកលើការវិភាគ

### បញ្ហា/មូលហេតុ/ដំណោះស្រាយ

| បញ្ហា | ទីតាំងបញ្ហា | មូលហេតុបញ្ហា | ដំណោះស្រាយ |
|---|---|---|---|
| ទិន្នផលស្រូវទាប | ភូមិស្ទឹងវែង<br>ភូមិព្រៃកស្វាយ | ទឹកប្រៃហូរចូលស្រែ<br>ប្រឡាយរាក់<br>គ្មានទំនប់ការពារទឹកប្រៃ<br>ដីខ្សោះជីជាតិ<br>ខ្វះបច្ចេកទេសកសិកម្ម<br>ខ្វះពូជស្រូវដែលមានទិន្នផល ខ្ពស់<br>ទ្វារទឹកខូច<br>ខ្វះទ្វាទឹក | សាងសង់ទំនប់ទឹកប្រៃ<br>ស្តារប្រឡាយ<br>ជួសជុលទំនប់ការពារទឹកប្រៃ<br>បើកវគ្គបណ្តុះបណ្តាលធ្វើជីកំប៉ុស្តិ៍<br>បើកវគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម<br>ផ្តល់ពូជស្រូវដែលមានទិន្នផលខ្ពស់<br>ជួសជុលទ្វារទឹក<br>ធ្វើទ្វារទឹក |
| ចំណាកស្រុកច្រើន | ភូមិស្ទឹងវែង<br>ភូមិព្រៃកស្វាយ | -ខ្វះមុខរបរ<br>-ជីវភាពខ្វះខាត<br>-ខ្វះជីវភាពខ្វះខាត<br>-ខ្វះជំនាញកែច្នៃផលិតផលក្នុងស្រុក | -បណ្តុះបណ្តាលវិជ្ជាជីវៈកាត់ដេរ និងជួសជុលគ្រឿងអេឡិចត្រូនិច<br>-បណ្តុះបណ្តាលះអំពីការកែច្នៃផលិតផលមានក្នុងស្រុក<br>-បណ្តុះបណ្តាលអំពីការកែច្នៃផលនេសាទ |

| | | | |
|---|---|---|---|
| | | | -បើកវគ្គបណ្តុះបណ្តាលអំពីការធ្វើ កសិកម្មចំរុះ ផ្តល់ពូជដំណាំរួម ផ្សំគ្រប់មុខ |
| មានផ្លូវខូចច្រើន | ភូមិស្ទឹងវែង<br>ភូមិព្រៃកស្វាយ | -ពិបាកធ្វើដំណើរ | -ជួសជុលផ្លូវក្រាលគ្រួសក្រហម<br>-ធ្វើផ្លូវបេតុង<br>-បង្កើតគណៈកម្មការថែទាំគំរោង |
| ខ្វះផ្លូវ | ភូមិស្ទឹងវែង<br>ភូមិព្រៃកស្វាយ | -ធ្វើអោយផលិតផលគ្មានទីផ្សារ<br>-ពិបាកក្នុងការទទួលប្រមូល ព័តិមាន | -សាងសង់ផ្លូវលំក្រាលគ្រួស ក្រហម |
| ខ្វះលូបង្ហូរទឹក | ភូមិស្ទឹងវែង<br>ភូមិព្រៃកស្វាយ | -ទឹកលិចលំនៅដ្ឋានប្រជាពលរដ្ឋ | -ធ្វើលូបង្ហូរ |
| ស្ទះទឹកបណ្តាល<br>អោយលិចលំនៅ ដ្ឋាន | ភូមិស្ទឹងវែង<br>ភូមិព្រៃកស្វាយ | -ប្រឡាយរាក់ | -ស្តារប្រឡាយបង្ហូរទឹក |
| ខ្វះកំលាំងអូសទាញ | ភូមិស្ទឹងវែង<br>ភូមិព្រៃកស្វាយ | -មិនបានពង្រីកដូរស្រែសំរាប់ បង្កើនផលិតផល | -ទិញត្រាក់ទ័រ និងទិញគោយន្ត ទិញគោ ក្របី |
| កុមារអាយុ ៦ ឆ្នាំ<br>មិនបានចូលរៀ | ភូមិស្ទឹងវែង<br>ភូមិព្រៃកស្វាយ | -សាលារៀននៅឆ្ងាយ<br>-ជីវភាពខ្វះខាត<br>-ខ្វះមធ្យោបាយធ្វើដំណើរ | -សាងសង់សាលារៀន<br>-បង្កើតគណៈកម្មការមាតា បិតាសិស្ស<br>-ផ្សព្វផ្សាយដល់ឪពុកម្តាយ បញ្ជូនទៅសាលារៀន |

| | | | |
|---|---|---|---|
| ន | | -ខ្វះគ្រូបង្រៀន | -ផ្តល់អាហារូបករណ៍ដល់សិស្ស ក្រីក្រ<br>-បណ្តុះបណ្តាលបច្ចេកទេស<br>ចិញ្ចឹមសត្វជ្រូក មាន់ ទា<br>-ផ្តល់សម្បទានសង្គមកិច្ច |
| នៅមានអ្នកមិនចេះអក្សរ | ភូមិស្ទឹងវែង<br>ភូមិព្រៃកស្វាយ | -ជីវភាពក្រីក្រ<br>-ពុំមានការយល់ដឹងនៃចំណេះ ដឹង | បើកបង្រៀនថ្នាក់អក្ខរកម្ម |
| ខ្វះការផ្សព្វផ្សាយពី<br>គោលនយោបាយ<br>សុខភាពបន្តពូជ និង យុវវ័យ | ភូមិស្ទឹងវែង<br>ភូមិព្រៃកស្វាយ | -ពុំទាន់បានផ្សព្វផ្សាយអោយ ទូលំទូលាយ | -ផ្សព្វផ្សាយពី គោលនយោបាយ<br>ប្រជាជនសុខភាពបន្តពូជ និង<br>យុវវ័យ |
| ផ្លូវពិបាកធ្វើដំណើរ<br>(ផ្លូវអន្តរឃុំ) | ភូមិស្ទឹងវែង<br>ភូមិព្រៃកស្វាយ<br>ភូមិ ១<br>ភូមិ ៣<br>ភូមិ ៤<br>ឃុំដងទង់<br>ព្រៃកស្វាយជា មួយ<br>ភូមិ | -លំបាកធ្វើដំណើរ<br>-មានភ្លៀងធ្លាក់ច្រើន | -ធ្វើផ្លូវបេតុងអន្តរឃុំ<br>-ធ្វើលូអន្តរឃុំ |

| | | | |
|---|---|---|---|
| | ៣ជាមួយឃុំស្នាច់មានជ័យ | | |
| នៅមានទំនាស់ផ្សេងៗ | ភូមិស្ទឹងវែង<br>ភូមិព្រៃកស្វាយ | -មានការរំលោភបំពានគ្នាទៅ វិញទៅមក<br>-ខ្វះការការពារ និងមានជន លោភលន់ | -ផ្សព្វផ្សាយ និងធ្វើទិវារពលកម្ម<br>-មានមធ្យោបាយដឹកជញ្ជូនសំរាម ជាប្រចាំ<br>-មានធុងសំរាមគ្រប់ផ្ទះ |
| អំពើហឹង្សានៅក្នុង គ្រួសារ | ភូមិស្ទឹងវែង<br>ភូមិព្រៃកស្វាយ | -ជីវភាពក្រីក្រ<br>-គ្រួសារបែកបាក់<br>-កូនៗគ្មានអនាគត | -ផ្សព្វផ្សាយពីការទប់ស្កាត់ អំពើហឹង្សាក្នុងគ្រួសារ |
| យុវនិតិសម្បទា | ភូមិស្ទឹងវែង<br>ភូមិព្រៃកស្វាយ | -ប្រើប្រាស់គ្រឿងញៀន<br>-សិស្សបោះបង់ចោលការសិក្សា<br>-កុមារប្រព្រឹត្តខុសនិងច្បាប់ | -<br>បង្កើតអោយមានមជ្ឈមណ្ឌលកែប្រែប<br>-បញ្ជូនកុមារទៅមជ្ឈមណ្ឌលកែប្រែ<br>-អនុវត្តវិធីការច្បាប់ |

| | | | |
|---|---|---|---|
| បញ្ហាស្ត្រីមេម៉ាយកូនច្រើនការលំបាក | ភូមិស្ទឹងវែង<br>ភូមិព្រៃកស្វាយ | -គ្មានការងារធ្វើ<br>-ចំណូលបានតិច<br>-គ្មានដីស្រែចំការធ្វើ | -បើកវគ្គបណ្តុះបណ្តាលការកែច្នៃ សិប្បកម្មធ្វើដោយដៃ ( កន្ត្រក. កញ្ជ្រែង....................)<br>-ផ្តល់ថវិកាធ្វើដើមទុន<br>-ផ្តល់សម្បទានសង្គមកិច្ច |

| | | | |
|---|---|---|---|
| គ្មានមុខរបរចិញ្ចឹមជីវិត ( ជនពិការ ) | ភូមិស្ទឹងវែង<br>ភូមិព្រៃកស្វាយ | -ដោយសង្គ្រាម<br>-ពីកំណើត<br>-គ្រោះថ្នាក់ចរាចរណ៍ | -ផ្តល់ឧបករណ៍ទ្រទ្រង់រាងកាយ<br>-ស្វែងរកការគាំទ្រ<br>-ស្វែងរកឥណទាន<br>-ផ្សព្វផ្សាយច្បាប់ចរាចរណ៍ |
| ចាស់ជរា | ភូមិស្ទឹងវែង<br>ភូមិព្រៃកស្វាយ | -គ្មានទីពឹង<br>-ជីវភាពខ្វះខាត | -ផ្តល់ស្បៀងអាហារ និងប្រាក់ ឧបត្ថម្ភ |
| ខ្វះពូជមាន់ទា | ភូមិស្ទឹងវែង<br>ភូមិព្រៃកស្វាយ | -ខ្វះទុន | -ទិញពូជមាន់ទា |
| ក្មេងមិនចូលរៀន មានអ្នកមិនចេះអក្សរច្រើន | ភូមិស្ទឹងវែង<br>ភូមិព្រៃកស្វាយ | -សាលានៅឆ្ងាយពីផ្ទះ<br>-កិច្ចអភិវឌ្ឍន៍មានភាពយឺតយ៉ាវ | -សង់សាលារៀនថ្មី សុំគ្រូបន្ថែម អប់រំផ្សព្វផ្សាយពីសារៈសំខាន់នៃការសិក្សាបើកបង្រៀនថ្នាក់ អក្ខរកម្ម |
| ខ្វះបង្គន់អនាម័យ | ភូមិស្ទឹងវែង<br>ភូមិព្រៃកស្វាយ | -មានជំងឺច្រើន | -សាងសង់បង្គន់អនាម័យបានគ្រប់ គ្រួសារ<br>-ផ្សព្វផ្សាយអំពីការថែរក្សាអនាម័យក្នុងមូលដ្ឋាន |
| ខ្វះទឹកស្អាតប្រើប្រាស់ | ភូមិស្ទឹងវែង<br>ភូមិព្រៃកស្វាយ | -សុខភាពមិនល្អ | ជីកអណ្តូងលូមានបណ្តាញទឹក ស្អាត |
| ខ្វះមណ្ឌលសុខភាព | ភូមិស្ទឹងវែង<br>ភូមិព្រៃកស្វាយ | -មន្ទីរពេទ្យបង្អែកនៅឆ្ងាយពី ផ្ទះ | សាងសង់មណ្ឌលសុខភាព |
| នៅមានការកាប់ | ភូមិស្ទឹងវែង | -ខូចបរិស្ថាន និងបាត់បង់ធម្មជាតិ | -បង្កើតក្រុមការពារបរិស្ថានតាម ភូមិ |

| | | | |
|---|---|---|---|
| បំផ្លាញព្រៃឈើ | ភូមិព្រែកស្វាយ | | -ផ្សព្វផ្សាយច្បាប់ការពារបរិស្ថាន |
| មានសំរាមពាសវាលកាល | ភូមិស្ទឹងវែង<br>ភូមិព្រែកស្វាយ | -ខ្វះការយល់ដឹងពីអនាម័យ<br>-បរិស្ថាន<br>-ខ្វះមធ្យោបាយដឹកជញ្ជូន | -ផ្សព្វផ្សាយនិងធ្វើមានទិវាពល កម្មមានមធ្យោបាយដឹកជញ្ជូន សំរាម ជាប្រចាំ<br>-មានធុងសំរាមដាក់តាមផ្ទះ<br>-បង្កើតក្រុមដឹកជញ្ជូនសំរាម |
| នៅមានការបាត់បង់ទ្រព្យសម្បត្តិប្រជាពលរដ្ឋ | ភូមិស្ទឹងវែង<br>ភូមិព្រែកស្វាយ | -មានចោរកម្មពេលយប់<br>-មានល្បែងស៊ីសងមានឥទ្ធិពល គ្រឿងញៀន | -បង្កើតប្រជាការពារ |
| គ្មានរថយន្តពន្លត់អគ្គីភ័យ | ភូមិស្ទឹងវែង<br>ភូមិព្រែកស្វាយ | -មានភ្លើងឆេះព្រៃជារៀងរាល់ ឆ្នាំក្បែរផ្ទះប្រជាពលរដ្ឋ | ទិញរថយន្តពន្លត់អគ្គីភ័យ |
| ខ្វះការយល់ដឹងពីសុខភាពបន្តពូជ និងយុវវ័យ | ភូមិស្ទឹងវែង<br>ភូមិព្រែកស្វាយ | -ភាពក្រីក្រកើនឡើង | -បើកវគ្គផ្សព្វផ្សាយបន្តគោលនយោបាយប្រជាជនសុខភាព បន្តពូជនិងយុវវ័យ |
| នៅមានអ្នកកើតមេរោគអេដស៍ | ភូមិស្ទឹងវែង<br>ភូមិព្រែកស្វាយ | -មានភាពក្រីក្របែកបាក់ គ្រួសារ កូនៗគ្មានអនាគត | -ផ្សព្វផ្សាយពីការទប់ស្កាត់អំពី ហឹង្សាក្នុងគ្រួសារ |
| ជួញដូរស្ត្រី និងកុមារ | ភូមិស្ទឹងវែង<br>ភូមិព្រែកស្វាយ | -ទៅរកការងារធ្វើនៅឆ្ងាយពីផ្ទះ | -ផ្សព្វផ្សាយពីការទប់ស្កាត់ការ ជួញដូរស្ត្រីនិងកុមារ |
| ប្រើប្រាស់គ្រឿងញៀន | ភូមិស្ទឹងវែង<br>ភូមិព្រែកស្វាយ | -ឥទ្ធិពលថ្នាំញៀនពីអ្នកទៅរក ស៊ីនៅប្រទេសជិតខាង | -ផ្សព្វផ្សាយពីច្បាប់ស្ដីពីការទប់ស្កាត់គ្រឿងញៀន |
| មុខរបរនេសាទ | ភូមិស្ទឹងវែង | -ធនធានជលផលកើនឡើង | -ផ្សព្វផ្សាយច្បាប់ទប់ស្កាត់បទ ល្មើស |

| | | | |
|---|---|---|---|
| មានការកើនឡើង | ភូមិព្រែកស្វាយ | | -បង្កើតក្រុមការពារធម្មជាតិ |
| អ្នកធ្វើចំណាកស្រុកច្រើន | ភូមិស្ទឹងវែង<br>ភូមិព្រែកស្វាយ | -ខ្វះមុខរបរក្នុងស្រុក<br>ជីវភាពខ្វះខាត<br>-ខ្វះជំនាញកែច្នៃផលិតផល | -ផ្សព្វផ្សាយអំពីផលវិបាកនៃ<br>ការធ្វើចំណាកស្រុក<br>-បណ្តុះបណ្តាលវិជ្ជាជីវៈកាត់ដេរ<br>និងអេឡិចត្រូនិច<br>-បណ្តុះបណ្តាលការកែច្នៃផលិត ផលក្នុងស្រុក<br>-បណ្តុះបណ្តាលពីការធ្វើ កសិកម្មចំរុះ |
| ទឹកលិចផ្លូវ និង លំនៅដ្ឋានប្រជាពលរដ្ឋ | ភូមិស្ទឹងវែង | -ដាក់ក្នុងព្រែកលុបដីបង្រួមផ្លូវទឹក | -បើកវគ្គផ្សព្វផ្សាយស្តីពីធន ធានធម្មជាតិ<br>និងបរិស្ថាន<br>-ស្តារប្រឡាយ |
| ខ្វះបណ្តាញអគ្គិសនី | ភូមិស្ទឹងវែង<br>ភូមិព្រែកស្វាយ | -អគ្គិសនីឯកជនឡើងថ្លៃត្រូវ កាត់ផ្តាច់<br>-បណ្តាញរដ្ឋទៅមិនដល់ | -អោយបណ្តាញអគ្គិសនី |
| ទិន្នផលស្រូវទាប | ភូមិស្ទឹងវែង<br>ភូមិព្រែកស្វាយ | -ខ្វះបច្ចេកទេសកសិកម្ម<br>-ប្រើពូជតាមទំលាប់ចាស់<br>-ទឹកប្រៃហូរចូលស្រែ<br>-ប្រឡាយចាស់រាក់<br>-ដីខ្សោះជីវជាតិ<br>-ខ្វះពូជស្រូវដែលមាន ទិន្នផល ខ្ពស់<br>-ទ្វារទឹកខូច | -បណ្តុះបណ្តាលបច្ចេកទេស កសិកម្ម<br>-ប្រើពូជស្រូវដែលមានទិន្នផល ខ្ពស់<br>-ជួសជុលទំនប់ទឹកប្រៃ<br>-ស្តារប្រឡាយ<br>-ប្រើជីគីមី និងជីធម្មជាតិ<br>-ជួសជុលទ្វារទឹក<br>-ធ្វើទ្វារទឹក |

| | | | |
|---|---|---|---|
| | | -ខ្វះទ្វារទឹក | -បើកវគ្គបណ្ដុះបណ្ដាលការធ្វើ ជីកំប៉ុស្តិ៍ |
| ខ្វះបង្គន់អនាម័យ | ភូមិស្ទឹងវែង<br>ភូមិព្រៃកស្វាយ | -មិនយល់ដឹងពីសារៈសំខាន់នៃ ការអនាម័យ | -ផ្សព្វផ្សាយអោយយល់ដឹងពី<br>សារៈសំខាន់នៃការអនាម័យ<br>-សង់បង្គន់អនាម័យ |

## ឧបសម្ព័ន្ធ ៤

# ក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ និងជំរើសនៃការប្រើប្រាស់ដីធ្លីអនាគត

| ២.១ កំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និងយុទ្ធសាស្ត្រ | | | | | |
|---|---|---|---|---|---|
| តំរូវការនៃការអភិវឌ្ឍន៍ | ប្រភពឯកសារ | គោលដៅនៃការអភិវឌ្ឍន៍ | យុទ្ធសាស្ត្រនៃ ការអភិវឌ្ឍន៍ | សកម្មភាព ជាអទិភាព | លេខរៀង នៅលើផែនទី |
| -មានស្បៀងហូបគ្រប់គ្រាន់ | សង្កាត់ស្ទឹងរំង | | -ជំរុញការកសាងផែនការហេដ្ឋារចនាសម្ព័ន្ធ បង្កើនបច្ចេកទេសធ្វើជីកំប៉ុស្តិ៍ និងបច្ចេកទេសកសិកម្មចំរុះ | -សាងសង់ទំនប់ការពារទឹកប្រៃស្ដាប្រឡាយ<br>-ជួសជុលទំនប់ការពារទឹកប្រៃ<br>-បើកវគ្គបណ្ដុះបណ្ដាលបច្ចេកទេសកសិកម្ម<br>-ផ្ដល់ស្រូវដែលមានទិន្នផលខ្ពស់<br>-ជួសជុលទ្វារទឹក និងធ្វើទ្វារទឹក<br>-ជួសជុលទ្វារទឹក និងធ្វើទ្វារទឹកប្រៃ | ទំព័រ ២០ |
| - អោយមានមុខរបរគ្រប់គ្នាដោយមានជំនាញកែច្នៃផលិត ផលក្នុងស្រុក និងមានជំនាញ កសិកម្មចំរុះ | | | -ជំរុញការបណ្ដុះបណ្ដាលវិជ្ជាជីវៈកាត់ដេរ គ្រឿងអេឡិចត្រូនិចការកែច្នៃផលិតផលក្នុងស្រុកផលនេសាទ និងការធ្វើចំណាកស្រុក | -បណ្ដុះបណ្ដាលវិជ្ជាជីវៈកាត់ដេរ និងជួសជុលគ្រឿងអេឡិចត្រូនិច<br>-បណ្ដុះបណ្ដាលការកែច្នៃផលិតផលក្នុងស្រុក<br>-ទប់ស្កាត់ការធ្វើចំណាកស្រុក<br>-បើកវគ្គបណ្ដុះបណ្ដាលអំពីការធ្វើ | |

| | | | | | |
|---|---|---|---|---|---|
| | | | | កសិកម្ម ចំរុះ និងការផ្តល់គ្រប់ដំណាំរួមផ្សំគ្រប់មុខ | |
| -ការធ្វើដំណើរ និងដឹកជញ្ជូនផលិតផលមាន ភាពងាយស្រួល | | -លើកកំពស់ជីវភាពរស់នៅរបស់ប្រជាជន | -ជំរុញការជួសជុលក្រាលគ្រួសក្រហម និង ធ្វើផ្លូវបេតុង | -ជួសជុលផ្លូវក្រាលគ្រួសក្រហម<br>-សាងសង់ផ្លូវបេតុង<br>-បង្កើតគណៈកម្មការថែទាំ | |
| -កុំអោយទឹកលិចលំនៅដ្ឋានប្រជាជន និងលិចផ្លូវ | | -លើកកំពស់ជីវភាពរស់នៅរបស់ប្រជាជន | -ជំរុញការដាក់លូរបង្ហូរទឹក | -ជួសជុលលូ និងសាងសង់លូបង្ហូរទឹកថ្មី<br>-ជួសជុលប្រឡាយ | |
| -ស្តារដីដាំដុះអោយធំទូលាយ | | -លើកកំពស់ជីវភាពរស់នៅរបស់ប្រជាជន | -ជំរុញកំលាំងអូសទាញ | -ទិញត្រាក់ទ័រ គោយន្តនិងផ្តល់ពូជគោក្របី | |
| -អោយប្រជាពលរដ្ឋមានពូជមាន់ទា | | -លើកកំពស់ជីវភាពរស់នៅរបស់ប្រជាជន | -បង្កើនការចិញ្ចឹមសត្វមាន់ទាតាមគ្រួសារ | -ទិញពូជមាន់ទាចិញ្ចឹម | |
| -អោយប្រជាពលរដ្ឋយល់ដឹងពីអនាម័យគ្រប់គ្នា និងបរិស្ថានល្អនិងរក្សាបាននូវធនធានធម្មជាតិ | | -រក្សាបាននូវបរិស្ថានល្អ និង ធនធានធម្មជាតិ គង់វង្ស | -បង្កើនការផ្សព្វផ្សាយពីការថែរក្សាអនាម័យនិងការការពារបរិស្ថាន | -សាងសង់បង្គន់អនាម័យគ្រប់គ្រួសារ<br>-បង្កើតក្រុមការពារបរិស្ថានតាមភូមិ | |

# ឧបសម្ព័ន្ធ ៥

## បញ្ជីគំរោងឬសកម្មភាពសំខាន់របស់សង្កាត់ក្នុងរយៈពេល ១៥ ឆ្នាំ

| ល.រ | គំរោង ឬសកម្មភាព | លទ្ធផលគំរោង | | ផែនការប្រើប្រាស់ដីធ្លី ១៥ ឆ្នាំ | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ចំនួន | ឯកត្តា | ៥ឆ្នាំទី ១ (១) | ៥ឆ្នាំទី ២ (២) | ៥ឆ្នាំទី ៣ (៣) | |
| ២៦១ | គំរោងផ្នែកហេដ្ឋារចនាសម្ព័ន្ធ | | | | | | |
| | ២.៦.១.១ គំរោងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត | | | | | | |
| | ១.១ ផ្លូវថ្នល់ | | | | | | |
| | ១.១.១ សាងសង់ផ្លូវកៅស៊ូ | ១២៩៩៦ | ម៉ែត្រ | ៥១០៣ | ១៧១០ | ៦១៨៣ | |
| | ១.១.២ សាងសង់ផ្លូវបេតុង | ៦៨២៣ | ម៉ែត្រ | ២៤០៥ | ២២០៤ | ២២១៤ | |
| | ១.១.៣ សាងសង់ផ្លូវគ្រួសក្រហម | ៤៣៩០ | ម៉ែត្រ | ១៦៩៣ | ១៥៦០ | ១១៣៧ | |
| | ១.១.៤ ជួសជុលផ្លូវគ្រួសក្រហម | ១៥២៥៨ | ម៉ែត្រ | ១៥២៥៨ | 0 | 0 | |
| | ១.១.៥ សាងសង់ផ្លូវដីស | 0 | 0 | 0 | 0 | 0 | |
| | ១.២ ផ្នែកធារាសាស្ត្រ | | | | | | |
| | ១.២.១ ជួសជុលទំនប់ការពារទឹកប្រៃ | ៣៨៩0 | ម៉ែត្រ | ៣៥៩0 | ៣00 | 0 | |
| | ១.២.២ សាងសង់ទំនប់ការពារទឹកប្រៃ | ១៨0 | ម៉ែត្រ | ១៨0 | 0 | 0 | |
| | ១.២.៣ សាងសង់ទ្វារទឹកការពារទឹកប្រៃ | ៤ | កន្លែង | ២ | ២ | 0 | |
| | ១.២.៤ ជួសជុលទ្វារទឹកការពារទឹកប្រៃ | ៥ | កន្លែង | ២ | ២ | 0 | |
| | ១.២.៥ ស្តារប្រឡាយរំដោះទឹកភ្លៀង | ៣៥៩៣ | ម៉ែត្រ | ៧៩៥ | ១៣៥0 | ១៤៤៨ | |
| | ១.២.៦ ដាក់លូរបង្ហូរទឹក ( ឆ្លងផ្លូវ) | ១៦ | កន្លែង | ៥ | ៥ | ៦ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | ២.៦.១.២ ហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេវាកម្មផ្សេងៗ | | | | | | |
| | ២.៦.១.២.១ ការសិក្សា និងអប់រំ | | | | | | |
| | ២.៦.១.២.២ សាលាមត្តេយ្យ | | | | | | |
| | ២.៦.១.២.៣ សាលាបឋមសិក្សា | 0 | 0 | 0 | 0 | 0 | |
| | ២.៦.១.២.៤ អនុវិទ្យាល័យ | ១ | កន្លែង | 0 | ១ | 0 | |
| | ២.៦.១.២.៥ វិទ្យាល័យ | 0 | 0 | 0 | 0 | 0 | |
| | ២.៦.១.៣.១ សុខភាព និងអនាម័យ | | | | | | |
| | ២.៦.១.៣.២ មណ្ឌលសុខភាព | 0 | 0 | 0 | 0 | 0 | |
| | ២.៦.១.៣.៣ ប៉ុស្តិ៍សុខភាព | ១ | កន្លែង | 0 | ១ | 0 | |
| | ២.៦.១.៣.៤ ស្រះទឹកស្អាត | ២ | ស្រះ | ១ | ១ | 0 | |
| | ២.៦.១.៣.៥ អណ្តូងលូ | ៧៧ | អណ្តូង | ២១ | ២៨ | ២៨ | |
| | ២.៦.១.៣.៦ រៀបចំកែលំអរកន្លែងចាក់សំរាម | ១ | កន្លែង | ១ | 0 | 0 | |
| | ២.៦.១.៤ សន្តិសុខ និងសណ្តាប់ធ្នាប់ | | | | | | |
| | ២.៦.១.៤.១ ប៉ុស្តិ៍នគរបាល | ១ | កន្លែង | ១ | 0 | 0 | |
| | ២.៦.១.៤.២ ទីតាំងផ្សារ | 0 | 0 | 0 | 0 | 0 | |
| | ២.៦.១.៥ ទីកន្លែងបូជា | | | | | | |
| | ២.៦.១.៥.១ ទីកន្លែងសក្ការៈបូជា | 0 | 0 | 0 | 0 | 0 | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ២.៦.១.៥.២ វត្តអារាម | 0 | 0 | 0 | 0 | 0 | |
| | ២.៦.១.៤.៣ សាលាឆទាន | 0 | 0 | 0 | 0 | 0 | |
| ២.៦.២ | គំរោងផ្នែកប្រើប្រាស់ដីធ្លី | | | | | | |
| | ២.៦.២.១ គំរោងប្រើប្រាស់ដីតាមវិស័យធំៗ | | | | | | |
| | ២.៦.២.១.១ ដីសហគមន៍នេសាទ | ១ | កន្លែង | ១ | 0 | 0 | |
| | ២.៦.២.១.២ ដីដែនជំរកសត្វព្រៃពាមក្រសោប | ២៦៩៤ | ហត | 0 | 0 | 0 | មានការកែសំរួល |
| | ២.៦.២.២ គំរោងប្រើប្រាស់ដីលក្ខណៈសហគមន៍ភូមិ-សង្កាត់ | | | | | | |
| | ២.៦.២.២.១ ដីលំនៅដ្ឋាន | ៨៥ | ហត | ២៦ | ២៩ | ៣0 | |
| | ២.៦.២.២.២ ដីកប់ខ្មោច | 0,៨៤ | ហត | 0.៨៤ | 0 | 0 | |
| | ២.៦.២.២.៣ ដីវាលស្រែ | ១២៦.៩៤ | ហត | ៧0.៣៤ | ៣0.៦0 | ២៦.00 | |
| | ២.៦.២.២.៤ ដីចាក់សំរាម | ១៥.៨៦ | ហត | ១0 | ៥.៨៦ | 0 | |
| | ២.៦.២.២.៥ សហគមន៍នេសាទ | ៦២0.៩0 | ហ.ត | ៦២0.៩0 | | | |
| | ២.៦.២.៣ គំរោងផ្នែកបង្កើនជំនាញ និងមុខរបរ | | | | | | |
| | ២.៦.២.២.៣.១ វគ្គបណ្ដុះបណ្ដាលអំពីការប្រើប្រាស់ដី | | | | | | |
| | ២.៦.២.២.៣.២ វគ្គបណ្ដុះបណ្ដាលអំពីការកែប្រែគុណភាពដី | | | | | | |